ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២១ លេខ ២ ខែមិថុនា ២០១៧ តម្លៃ ១.៥០០៛

# ថាមពលគុណឡើង និងការដោះដូរគ្នា ក្នុងប្រពលវប្បកម្មផលិតកម្មស្រូវ និងសត្វចិញ្ចឹមនៅកម្ពុជា

## សេចក្ដីផ្ដើម

កសិកម្មមានអាទិភាពយ៉ាងខ្ពស់នៅក្នុង កម្មវិធីអភិវឌ្ឍជាតិរបស់រដ្ឋាភិបាល (MAFF 2015)។ សកម្មភាពកសិកម្មចម្បងៗ រួមមាន ការដាំដុះស្រូវ ដំណាំបន្ទាប់បន្សំ ដំណាំឧស្សាហកម្ម និងការចិញ្ចឹមមាន់ទានិងសត្វចិញ្ចឹមផ្សេងៗទៀត។ កម្ពុជាមានស្រូវជាដំណាំចម្បងគេដោយមានប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ៤ ពោលគឺ តំបន់ខ្ពង់រាបពឹងលើទឹកភ្លៀង តំបន់ទំនាបពឹងលើទឹកភ្លៀង តំបន់ស្រែប្រាំងមានទឹកស្រោចស្រពនិងតំបន់ដាំស្រូវឡើងទឹកនិងស្រូវប្រដេញទឹក (Ros, Chhim and Nang 2011)។ លក្ខណៈទឹកជំនន់ទៀងទាត់ ដែលជន់លិចវាលទំនាបក្នុងអាងទន្លេមេគង្គនៅកម្ពុជា បានជួយទ្រទ្រង់ដល់ ការធ្វើកសិកម្មប្រដេញទឹកដែលរួមមាន កសិករខ្នាតតូចដាំដំណាំប្រចាំឆ្នាំ ដូចជាស្រូវជាដើម ក៏ដូចជា ការនេសាទ និងការប្រមូលផលិតផលព្រៃអាចហូបបានផ្សេងៗ។


សកម្មភាពរៀបចំស្រូវសម្រាប់នាំចេញទៅ វៀតណាម តាកែវ ខែកុម្ភៈ ឆ្នាំ២០១៧

លំហូរតាមធម្មជាតិនៃទឹកជំនន់ កំពុងតែផ្លាស់ប្ដូរ ជាពិសេសដោយសារទំនប់វារីអគ្គិសនីដែលមានស្រាប់ និងគម្រោងសាងសង់ទំនប់បន្ថែមក្នុងអាងទន្លេមេគង្គ។ រដ្ឋាភិបាលកម្ពុជា មានគម្រោងពង្រីកយ៉ាងធំនូវកសិកម្មមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់ស្រោចស្រពជាពិសេស ដើម្បីអាចដាំស្រូវបាន ២-៣ ដងក្នុងមួយឆ្នាំ និងបង្កើនការនាំចេញអង្ករ។ ពីឆ្នាំ២០០៩ ដល់ ២០១៣ ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) បានពង្រីកដែនស្រោចស្រពដើម្បីផ្ដល់ទឹកដល់ ដីកសិកម្ម ៣៨៧.៩០៧ ហិកតាថែមទៀត។ នៅត្រឹមឆ្នាំ២០១៣ ផ្ទៃដីមានការស្រោចស្រពសរុប ឡើងដល់ ១.៤៨៥.៦៧០ ហិកតា (NSDP 2014-18)។

សម្រាប់ការផ្លាស់ប្ដូរដូចខាងលើ ក្រុមស្រាវជ្រាវបានបង្កើតសម្មតិកម្មថា វាអាចហុចលទ្ធផលជា កំណើនផលិតកម្មអង្ករ ប៉ុន្តែមានការថយចុះផលិតកម្មស្បៀងអាហារផ្សេងទៀត ដែលសំខាន់នៅក្នុងរបបអាហាររបស់ប្រជាជនកម្ពុជា។ តាមនេះ វាអាចអំណោយផលដល់កសិករដែលផលិតសម្រាប់ការធ្វើពាណិជ្ជកម្ម

---

អត្ថបទនេះរៀបរៀងដោយ ផុន ដារី និង ស៊ឹម សុខចេង ជាអ្នកស្រាវជ្រាវក្នុងផ្នែកកសិកម្ម នៃវិទ្យាស្ថាន CDRI ។ សូមយោងឯកសារនេះថា៖ Phon Dary and Sim Sokcheng. 2017. "Synergies and Trade Offs with Intensification of Rice and Livestock Production in Cambodia." *Cambodia Development Review 21 (2)*: 1-7. ភ្នំពេញ វិទ្យាស្ថាន CDRI។

## មាតិកា

ថាមពលគុណឡើង និងការដោះដូរគ្នាក្នុងប្រពលវប្បកម្មផលិតកម្មស្រូវ និងសត្វចិញ្ចឹមនៅកម្ពុជា.......................... ១
ការវិវត្ត និងបញ្ហាប្រឈម នៃវិមជ្ឈការនៅប្រទេសកម្ពុជា៖ ករណីការគ្រប់គ្រងសំរាមនៅតាមទីក្រុង .......................... ៨
ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្សក្នុងការអប់រំ៖ ការសិក្សាប្រៀបធៀបលើបួនប្រទេស .......................... ១២
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស .......................... ១៧
— ស្ថានភាពក្នុងប្រទេស.......................... ១៩
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI .......................... ២៨

ជាជាងជួយលើកស្ទួយជីវភាព និងសន្តិសុខអាហារូបត្ថម្ភរបស់កសិករជីវព្រឹត្តិ (កសិករចិញ្ចឹមពោះ)។ ការពង្រីកកសិកម្មមានការស្រោចស្រព ក៏ត្រូវមានការប្រើប្រាស់កាន់តែច្រើននូវធនធានដូចជា ថាមពល និងទឹក ជាដើម ដែលមិនទាន់មានម៉ូដែលសម្រាប់សិក្សាទេ ហើយដែលអាចមានផលប៉ះពាល់អវិជ្ជមានទៅលើកត្តាផ្សេងទៀត។ ការពង្រីកកសិកម្មប្រភេទនេះ ពិតជានឹងបង្កើនការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វចង្រៃ ពីព្រោះពូជស្រូវដែលមានការលូតលាស់លឿន និងទិន្នផលខ្ពស់ជាងមុន ក៏ត្រូវការធាតុចូលទាំងនេះកាន់តែច្រើនដែរ។

សំណួរស្រាវជ្រាវសម្រាប់ការសិក្សានេះ គឺ តើការផ្លាស់ប្តូរផលិតកម្មស្បៀង ចេញពីកសិកម្មប្រដេញទឹក ទៅជា កសិកម្មមានការស្រោចស្រពនិងការគ្រប់គ្រងទឹក វាមានអត្ថប្រយោជន៍ បន្ទុកចំណាយ និងហានិភ័យប៉ុណ្ណា ចំពោះផលិតកម្មស្បៀង ដីធ្លី ទឹក ថាមពល និង សន្តិសុខអាហាររូបត្ថម្ភក្នុងគ្រួសារ?

## វិធីសាស្ត្រ

ការស្រាវជ្រាវនេះបានប្រើគួបផ្សំគ្នានូវ វិធីសាស្ត្រសិក្សាតាមបែបបរិមាណ និងតាមបែបគុណភាព។ ការវិភាគសេណារីយ៉ូបានធ្វើសំយោគ និងបកស្រាយទិន្នន័យប្រភពទី២ ដែលប្រមូលបានពីប្រភពជាច្រើន ដើម្បីប៉ាន់ស្មាន និងប្រៀបធៀប ការផ្គត់ផ្គង់ស្បៀងអាហារនិងអាហាររូបបត្ថម្ភ ទិន្នផល តម្រូវការធាតុចូល (ទឹក ថាមពល ជី កម្លាំងពលកម្ម ថ្នាំសម្លាប់សត្វចង្រៃ) ជាមួយនឹងអត្ថប្រយោជន៍ បន្ទុកចំណាយ ហានិភ័យ នៃ ប្រព័ន្ធដាំស្រូវពីរដងតែមួយមុខ និង ប្រព័ន្ធដាំស្រូវចិញ្ចឹមត្រីចូលគ្នាពីរមុខ។ លទ្ធផលនៃការស្រាវជ្រាវតាមបែបបរិមាណ ត្រូវបានបំពេញបន្ថែមដោយភស្តុតាងបានពីការស្រាវជ្រាវ និងការសង្កេតផ្សេងៗទទួលបានពីគម្រោងផ្សព្វផ្សាយកសិកម្ម និងករណីសិក្សានានានៅកម្ពុជាស្តីពី ពេលវេលាដែលកសិករអាចទទួលបានជំនួយទ្រទ្រង់ល្អ ការបណ្តុះបណ្តាល របៀបអនុវត្តន៍ល្អ និងបច្ចេកវិទ្យាថ្មីៗ ពោលគឺប្រព័ន្ធប្រពលវប្បកម្មស្រូវ (system of rice intensification: SRI) (Tech 2014; Anthofer 2004) និងជម្រកត្រីរបស់សហគមន៍ (community fish refuges: CFR) (Broks and Sieu. 2016; Thouk 2009)។ ទិន្នន័យលើកសិករដាំបន្លែគំរូមិនអាចរកបានទេ ដូច្នេះការសិក្សានេះ បានប្រើទិន្នន័យស្តីពីទិន្នផលបន្លែខ្ពស់បំផុតដែលសម្រេចបានក្នុងឆ្នាំ២០១៥ (MAFF 2016) ដោយផ្អែកលើការសន្មតថា កសិករអាចសម្រេចបានទិន្នផលខ្ពស់ដោយសារមានការបណ្តុះបណ្តាល និងជំនួយទ្រទ្រង់ពិសេស។ វិធីសាស្ត្រតាមបែបបរិមាណ មានជំហានជាច្រើនដូចតទៅ៖

***ការគណនាការផ្គត់ផ្គង់ ស្បៀងអាហារ និងអាហាររូបត្ថម្ភ៖*** រូបមន្តខាងក្រោមនេះ បានកែសម្រួលចេញពី FAO (2011) ដោយផ្អែកលើទិន្នន័យអាចរកបាន ដើម្បីកំណត់ពីការផ្គត់ផ្គង់ អង្ករ សាច់គោ ត្រីស្រែ សត្វទឹកផ្សេងទៀត(other aquatic animals: OAA) និង បន្លែ។ ការផ្គត់ផ្គង់ស្បៀងអាហារ ត្រូវយកមកចែកជាមួយនឹង ផ្ទៃដីប្រមូលផល/វាលស្មៅ ដើម្បីកំណត់នូវ ការផ្គត់ផ្គង់ស្បៀងអាហារក្នុងមួយហិកតា។

ការផ្គត់ផ្គង់អាហារ = ផលិតកម្ម + ការនាំចូល - ការនាំចេញ +/- ស្តុក - ចំណីសត្វ - គ្រាប់ពូជ - ការផលិតអាហារ - កាកសំណល់ - ការប្រើប្រាស់ផ្សេងទៀត

ការផ្គត់ផ្គង់ស្រូវ បន្លែ និងសាច់គោ បានគណនាឡើងដោយប្រើ FAOSTAT data (2016) ។ ត្រីស្រែ សត្វទឹកផ្សេងៗ(OAA) បានគណនាឡើងដោយផ្អែកលើ ទិន្នន័យបានពីការសិក្សាចំនួន ៦ នៅកម្ពុជា (Gregory, Guttman and Kekputhearith 1996; Nesbitt 1997; Guttman 1999); Troeung et al. 2003; Hortle, Troeung and Lieng 2008; Thouk 2009) ។

ការសិក្សានេះផ្អែកជាសំខាន់លើ តារាងផ្សំស្បៀងអាហារ របស់ FAO (1953, 1981) ដើម្បីប៉ាន់ស្មានពី ការផ្គត់ផ្គង់អាហាររូបត្ថម្ភជា ប្រូតេអ៊ីន កាឡូរី និង លីស៊ីន ក្នុងមួយហិកតាដីផលិត ស្រូវ សាច់គោ ត្រីស្រែ សត្វទឹកផ្សេងៗ និង បន្លែ (តារាង១)។

តារាង១៖ បរិមាណមធ្យមនៃ ប្រូតេអ៊ីន កាឡូរី និង លីស៊ីន ក្នុង ១០០ ក្រាម នៃស្បៀងអាហារប្រភេទនីមួយៗ

| ស្បៀងអាហារ | ប្រូតេអ៊ីន (ក្រាម/100ក្រាម) | កាឡូរី (កាឡូរី/100ក្រាម) | លីស៊ីន (មីលីក្រាម/100ក្រាម) |
|---|---|---|---|
| ត្រីស្រែ (ត្រីគ្រប់មុខគ្មានកំណត់ឈ្មោះ) | 18,80[a] | 132[b] | 1713[a] |
| សត្វទឹកផ្សេងៗ | 16.00[c] | 103[b] | 1262[c] |
| សាច់គោ (ក្រៅពីខ្លាញ់តម្រងនោម [1.8%]) | 17.70[a] | 256[b] | 1573[a] |
| អង្ករ (សម្រិត ឬសំរូប) | 7.50[a] | 357[b] | 299[a] |
| បន្លែ | 2.03[d] | 27[b] | 100[d] |

ប្រភព៖ [a] FAO 1981; [b] FAO 1953; [c] Nurhasan et al. 2010; [d] Pittock, Dumaresq and Orr 2015

***ការគន់គូរផ្ទៃដីផលិតកម្ម ជាសក្ដានុពល៖*** ដោយប្រើប្រព័ន្ធព័ត៌មានភូមិសាស្ត្រ Arc-GIS និងផែនទីតំបន់ដំណាំ (IRRA 2010; ODC2015,2016) ក្រុមស្រាវជ្រាវបានជ្រើសយកតំបន់ដាំស្រូវមួយដងមានការស្រោចស្រពបច្ចុប្បន្ន មកធ្វើជាតំបន់មានសក្ដានុពលសម្រាប់ការដាំស្រូវពីរដងមានការស្រោចស្រព (រូបភាព១)។

***ការប៉ាន់ស្មានផលិតកម្ម/ទិន្នផល៖*** របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) មានផ្ដល់ទិន្នន័យសម្រាប់ ទិន្នផលស្រូវទាំងពីររដូវ (១៩៨០-២០១១) ទិន្នផលស្រូវប្រាំង (១៩៨០-២០១៥) ទិន្នផលស្រូវវស្សា (១៩៨០-២០១៥) ផលិតកម្មត្រីស្រែ (២០០៨-២០១៥) ផ្ទៃដីប្រមូលផលស្រូវវស្សា (២០០៨-២០១៥) ទិន្នផលបន្លែ (១៩៩៦-២០១៥) និង ការផ្គត់ផ្គង់អង្ករ (២០០៨-២០០៩)។ ទិន្នន័យនេះបានយកមកប្រើដើម្បីគណនា ប្រូតេអ៊ីន កាឡូរី និង លីស៊ីន។

***ការប៉ាន់ស្មានធាតុចូល៖*** ទិន្នន័យបានចងក្រងចេញពីប្រភពជាច្រើន ដើម្បីប៉ាន់ស្មានពី ការប្រើប្រាស់ទឹក (Abrams 2015), ការប្រើប្រាស់ថាមពលសម្រាប់ផលិតកម្មស្រូវ (Islam et al. 2011) និងផលិតកម្មបន្លែ (Canakci et al. 2005), ការប្រើប្រាស់ជី (Theng et al. 2014), បន្ទុកចំណាយលើថ្នាំសម្លាប់សត្វចង្រៃ និងពលកម្ម (World bank 2015)។

***ការបង្កើតម៉ូដែលតាមសេណារីយ៉ូ៖*** ក្រុមសាវជ្រាវបានកំណត់សេណារីយ៉ូ ៣ ដើម្បីប្រៀបធៀបស្ថានភាពបច្ចុប្បន្ននៃ ការផ្គត់ផ្គង់ស្បៀងអាហារ, ការគន់គូរពីផលិតកម្ម ប្រូតេអ៊ីន កាឡូរី និងលីស៊ីន, ការប្រើប្រាស់ទឹក,ការប្រើប្រាស់ជី, ការប្រើប្រាស់ថាមពល, បន្ទុកចំណាយលើថ្នាំសម្លាប់សត្វចង្រៃ និងកម្លាំងពលកម្ម, នៅក្នុងតំបន់ផលិតកម្មមានសក្ដានុពល នៅក្រោមប្រព័ន្ធកសិកម្ម ៣យ៉ាង។

- សេណារីយ៉ូ១: ការដាំស្រូវពីរដង (ស្រូវប្រាំង និងស្រូវវស្សា)
- សេណារីយ៉ូ២: ស្រូវវស្សា/ត្រីស្រែ/សត្វទឹកផ្សេងៗ/សាច់គោ
- សេណារីយ៉ូ៣: ស្រូវវស្សា/ត្រីស្រែ/សត្វទឹកផ្សេងៗ/បន្លែ

សេណារីយ៉ូ១ ត្រូវបានជ្រើសយក ដើម្បីឆ្លុះបញ្ចាំងពីប្រពលវប្បកម្មកសិកម្មតាមធម្មតា ហើយសេណារីយ៉ូពីរផ្សេងទៀតគឺសម្រាប់ឆ្លុះបញ្ចាំងពី ប្រព័ន្ធកសិកម្មចម្រុះដែលអាចមានចីរភាពជាងសម្រាប់កសិករ ព្រោះបន្ទាប់ពីប្រមូលផលហើយ វាលស្រែគេទុកឲ្យគោក្របីស៊ីស្មៅ និងទុកដាំបន្លែផ្សេងៗ។ សេណារីយ៉ូទាំង ៣ នេះ គេយកមកប្រើជាលើកទី២ ដើម្បីប្រៀបធៀបលើលក្ខណៈវិនិច្ឆ័យដដែល ប៉ុន្តែមាន ឬក៏គ្មាន ការទទួលយកមកប្រើនូវរបៀបអនុវត្តន៍ល្អៗ និងបច្ចេកទេសថ្មីៗ។

## លទ្ធផលសំខាន់ៗ

តារាង២ បង្ហាញ តួលេខប៉ាន់ស្មាននៃការផ្គត់ផ្គង់ស្បៀងអាហារក្នុងមួយហិកតានាពេលបច្ចុប្បន្ន ក្នុងសេណារីយ៉ូនីមួយៗ។ ដូចការរំពឹងទុក សេណារីយ៉ូ២ ផ្ដល់ផលបានតិចជាងសេណារីយ៉ូផ្សេង

រូបភាព១៖ តំបន់មានសក្ដានុពលសម្រាប់ការដាំស្រូវពីរដងមានការស្រោចស្រព




ប្រភព៖ IRRA 2010

ទៀត។ ថ្វីបើ ត្រីស្រែ សត្វទឹកផ្សេងៗ និងសាច់គោ ផ្តល់នូវសារធាតុចិញ្ចឹម បានច្រើនជាងអង្ករក្តី ប៉ុន្តែផលិតកម្មរបស់វា គួបផ្សំនឹងស្រូវវស្សា នៅមានកម្រិតទាប។ សេណារីយ៉ូ១ ផ្តល់កាឡូរីបានច្រើនបំផុតក្នុងចំណោមសេណារីយ៉ូទាំងបី ព្រោះអង្ករផ្តល់កាឡូរីច្រើនណាស់។ ប៉ុន្តែសេណារីយ៉ូ៣ ប្រសើរជាងគេវិញ បើគិតពី ប្រូតេអ៊ីន និងលីស៊ីន។ ដោយឡែកសម្រាប់លីស៊ីន វាផ្តល់បានច្រើនជាងសេណារីយ៉ូ២ ជិតពីរដង។

តំបន់ដាំដុះស្រូវបច្ចុប្បន្ន ដែលមានសក្តានុពលអាចដាំស្រូវមានការស្រោចស្រពបានពីរដង មានដល់ ១២៥.៧២៤ហិកតា (រូបភាព១)។ តារាង៣ បង្ហាញពីនិន្នាការនៃផលិតកម្មស្បៀងអាហារតាមការគន់គូរជា ប្រូតេអ៊ីន កាឡូរី និងលីស៊ីន នៅក្នុងតំបន់មានសក្តានុពលទាំងមូល។[1]

1 ក្នុងការគន់គូរ ក្រុមស្រាវជ្រាវបានប៉ាន់ស្មានតែផលិតកម្មស្បៀងអាហារប៉ុណ្ណោះ ព្រោះមិនអាចគន់គូរពីតួលេខនាំចេញ និងនាំចូលដែលចាំបាច់សម្រាប់ការគណនាពីការផ្គត់ផ្គង់ស្បៀងអាហារ។

តារាង២៖ ការផ្គត់ផ្គង់ប្រចាំឆ្នាំសរុបក្នុងមួយហិកតានូវប្រូតេអ៊ីន កាឡូរី និងលីស៊ីន គិតតាមប្រភេទស្បៀងអាហារ

| ប្រភេទស្បៀងអាហារ | សេណារីយ៉ូ១ | | | សេណារីយ៉ូ២ | | | សេណារីយ៉ូ៣ | | |
|---|---|---|---|---|---|---|---|---|---|
| | ប្រូតេអ៊ីន (តោន) | កាឡូរី (គីឡូកាឡូរី) | លីស៊ីន (តោន) | ប្រូតេអ៊ីន (តោន)) | កាឡូរី (គីឡូកាឡូរី) | លីស៊ីន (តោន) | ប្រូតេអ៊ីន (តោន) | កាឡូរី (គីឡូកាឡូរី) | លីស៊ីន (តោន) |
| អង្ករ | 0.12 | 5880 | 0.005 | 0.060 | 2940 | 0.0020 | 0.060 | 2940 | 0.0020 |
| សាច់គោ | - | - | - | 0.009 | 0.136 | 0.0010 | - | - | - |
| ត្រីស្រែ | - | - | - | 0.020 | 0.150 | 0.0020 | 0.020 | 0.15 | 0.0020 |
| សត្វទឹកផ្សេងៗ | - | - | - | 0.004 | 0.030 | 0.0003 | 0.004 | 0.03 | 0.0003 |
| បន្លែ | - | - | | | - | - | 0.100 | 1.35 | 0.0050 |
| សរុប | 0.12 | 5880 | 0.005 | 0.093 | 3256 | 0.0053 | 0.184 | 4470 | 0.0093 |

តារាង៣៖ លទ្ធផលនៃការបង្កើតសេណារីយ៉ូសម្រាប់តំបន់មានសក្តានុពល (១២៥.៧២៤ ហិកតា)

| | សេណារីយ៉ូ១ | សេណារីយ៉ូ២ | សេណារីយ៉ូ៣ |
|---|---|---|---|
| *ការគន់គូរប្រចាំឆ្នាំនូវ ផលិតកម្មស្បៀងអាហារ, ការប្រើប្រាស់ទឹក ថាមពល និងជី, ចំណាយលើថ្នាំសម្លាប់សត្វចង្រៃ និងពលកម្ម* | | | |
| ប្រូតេអ៊ីន (តោន) | 29475 | 15363 | 29898 |
| លីស៊ីន (តោន) | 900 | 729 | 1398 |
| កាឡូរី (លានគីឡូកាឡូរី) | 1403 | 559 | 751 |
| ការប្រើប្រាស់ទឹក (លានម៉ែត្រគូប) | 3017 | 1508 | 2451 |
| ការប្រើប្រាស់ថាមពល (ពាន់ megajoules) | 6726 | 3363 | 11059 |
| ការប្រើប្រាស់ជី (តោន) | 39176 | 13484 | 43938 |
| ចំណាយលើថ្នាំសម្លាប់សត្វចង្រៃ (ដុល្លារ) | 2.01 លាន | 503000 | 10.81 លាន |
| ចំណាយលើពលកម្ម (៤,៥៦ដុល្លារ/ថ្ងៃ) | 43.59 លាន | 15.91 លាន | 113.28 លាន |
| *ការគន់គូរប្រចាំឆ្នាំនូវផលិតកម្មស្បៀងអាហារ ដោយមានការបណ្តុះបណ្តាល ការទទួលយកបច្ចេកវិទ្យា/របៀបអនុវត្តន៍ល្អ* | | | |
| | +SRI | +CFR | +CFR + ទិន្នផលបន្លែខ្ពស់ |
| ប្រូតេអ៊ីន (តោន) | 90521 | 170976 | 192842 |
| លីស៊ីន (តោន) | 2764 | 14908 | 15939 |
| កាឡូរី (លានគីឡូកាឡូរី) | 4309 | 1652 | 1942 |

កំណត់សំគាល់៖ SRI = ប្រព័ន្ធប្រពលវប្បកម្មស្រូវ, CFR = ជម្រកត្រីសហគមន៍

តារាង៤៖ ចំណាត់ថ្នាក់នៃសេណារីយ៉ូដោយមាន និងដោយគ្មាន ការបណ្តុះបណ្តាល និងការទទួលយករបៀបអនុវត្តន៍ល្អ និងបច្ចេកវិទ្យា។

| សេណារីយ៉ូ | ការផលិតប្រូតេអ៊ីន | | ការផលិតកាឡូរី | | ការផលិតលីស៊ីន (lysine) | |
|---|---|---|---|---|---|---|
| | គ្មានការកែសម្រួល | ការបណ្តុះបណ្តាល និងការកែសម្រួលតាមបច្ចេកវិទ្យា | គ្មានការកែសម្រួល | ការបណ្តុះបណ្តាល និងការកែសម្រួលតាមបច្ចេកវិទ្យា | គ្មានការកែសម្រួល | ការបណ្តុះបណ្តាល និងការកែសម្រួលតាមបច្ចេកវិទ្យា |
| សេណារីយ៉ូ១ | 2 | 3 | 1 | 1 | 2 | 3 |
| សេណារីយ៉ូ២ | 3 | 2 | 3 | 3 | 3 | 2 |
| សេណារីយ៉ូ៣ | 1 | 1 | 2 | 2 | 1 | 1 |

## ការពិភាក្សា

### *អត្ថប្រយោជន៍ បន្ទុកចំណាយ និង ហានិភ័យ*

*សេណារីយ៉ូ១៖* តាមការគន់គូរសម្រាប់តំបន់សក្តានុពល ការដាំដុះស្រូវពីរដងផ្តល់អត្ថប្រយោជន៍ជាច្រើន មានជាអាទិ៍ ចំណូលបានពីការនាំចេញអង្ករ, ការផ្គត់ផ្គង់ស្បៀងអាហារកម្រិតខ្ពស់បំផុត បើគិតតាមការផលិតកាឡូរី, និង ការផ្គត់ផ្គង់ស្បៀងអាហារកម្រិតខ្ពស់បំផុតលំដាប់ទី២ បើគិតតាមការផលិតប្រូតេអ៊ីន និងលីស៊ីន។ ប៉ុន្តែវាមាន បន្ទុកចំណាយលើការផ្គត់ផ្គង់ទឹកកម្រិតខ្ពស់បំផុត, បន្ទុកចំណាយលើថាមពល ជី និងកម្លាំងពលកម្ម កម្រិតខ្ពស់បំផុតលំដាប់ទី២ ក្នុងចំណោមសេណារីយ៉ូទាំង ៣។

តម្រូវការទឹកកម្រិតខ្ពស់បំផុតក្នុងសេណារីយ៉ូ១ នាំឲ្យវាមានហានិភ័យធំជាងគេ ជាពិសេសដោយសារផលប៉ះពាល់អវិជ្ជមាននៃទំនប់វារីអគ្គិសនី និងការប្រែប្រួលអាកាសធាតុ ទៅលើបរិមាណ និងគុណភាពធនធានទឹក។ ការធានាឲ្យការផ្គត់ផ្គង់ទឹកមានស្ថិរភាពល្អ និងការកាត់បន្ថយហានិភ័យលើ ការផ្គត់ផ្គង់ទឹកក្នុងកសិកម្មមានការស្រោចស្រព វាមានតម្លៃខ្ពស់ព្រោះត្រូវមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការស្រោចស្រព និងយន្តការផ្នែកស្ថាប័ន។ ម្យ៉ាងទៀត ដំណើរការប្រព័ន្ធស្រោចស្រព និងម៉ាស៊ីនបូមទឹក ត្រូវចំណាយថាមពលអស់ច្រើន ទោះបីតម្រូវការថាមពលសរុបនៅមានកម្រិតទាបជាងក្នុង សេណារីយ៉ូ៣ ក្តី។ ដូច្នេះ ត្រូវពិចារណាពីប្រភពថាមពលផ្សេងទៀតដែលអាចយកមកប្រើជំនួសបាន។

ការប្រើប្រាស់ជីកម្រិតខ្ពស់ ក្នុងប្រពលវប្បកម្មដំណាំតាមធម្មតា អាចនាំឲ្យ ប្រែប្រួលដល់ធាតុផ្សំគីមីនៃដី ខូចខាតដល់រចនាសម្ព័ន្ធនៃដី និងបង្កឧបសគ្គដល់ប្រព័ន្ធអេកូឡូស៊ីនៃដី។ ទោះយ៉ាងនេះក្តី កំណើនការប្រើជីអសរីរាង្គក្នុងសេណារីយ៉ូ១ មានហានិភ័យតិចជាងក្នុងសេណារីយ៉ូ៣។ ស្រដៀងគ្នាដែរ ការប្រើថ្នាំសម្លាប់សត្វចង្រៃកាន់តែច្រើន អាចបំពុលដល់បរិស្ថាន (ទឹក ដី ខ្យល់) ធ្វើឲ្យដីរេចរឹល នាំឲ្យខូចខាតដល់រុក្ខជាតិ និងសរីរាង្គមិនមែនគោលដៅផ្សេងៗនិងប៉ះពាល់អវិជ្ជមានដល់មនុស្ស សត្វ និងសុខភាពប្រព័ន្ធអេកូឡូស៊ី។ ការបំភាយឧស្ម័នផ្ទះកញ្ចក់ មេតាន ($CH_4$) និងនីត្រូសែនឌីអុកស៊ីត ($N_2O$) ដែលមានសក្តានុពលបង្កើនកំដៅសកល (global warming potential: GWP) អាចនឹងកើនឡើងតាមរយៈការដាំស្រូវពីរដងនេះ។ GWP អាចខ្ពស់ជាងក្នុងសេណារីយ៉ូ៣ បើសិនមានការប្រើជី ឬក៏ស្មើគ្នានឹងសេណារីយ៉ូ៣ បើសិនគ្មានប្រើជី។

ប្រសិនបើកសិករទទួលយកវិធីសាស្ត្រ ប្រព័ន្ធប្រពលវប្បកម្មស្រូវ (system of rice intensification: SRI) នោះ ការដាំដុះស្រូវពីរដងអាចផលិតស្បៀងអាហារបានកាន់តែច្រើន គិតជាប្រូតេអ៊ីន កាឡូរី និងលីស៊ីន ប៉ុន្តែប្រើទឹកអស់តិចជាងមុន ៥០% ហើយបន្ទុកចំណាយលើថាមពលក៏ថយចុះដែរ ការប្រើជីអសរីរាង្គចុះទាបបំផុត គុណភាពដីត្រូវបានបំប៉នឡើង រីឯទឹកក្នុងដីក៏អាចរក្សាបានល្អ។

*សេណារីយ៉ូ២៖* ផ្អែកលើការប៉ាន់ស្មានការផ្គត់ផ្គង់ស្បៀងអាហារក្នុងដីមួយហិកតាបច្ចុប្បន្ន សេណារីយ៉ូ២ ផ្តល់លីស៊ីនបានច្រើនជាងសេណារីយ៉ូ១ ប៉ុន្តែតិចជាងសេណារីយ៉ូ៣។ តាមការគន់គូរផលិតកម្មស្បៀងអាហារ ក្នុងតំបន់មានសក្តានុពល សេណារីយ៉ូ២ ផ្តល់លីស៊ីន បានតិចបន្តិចជាងសេណារីយ៉ូ១ និងសេណារីយ៉ូ៣ និងផ្តល់ប្រូតេអ៊ីន និងកាឡូរី បានតិចជាងគេជាខ្លាំង។ សេណារីយ៉ូ២ មានបន្ទុកចំណាយទាបជាងគេបំផុត។ វាមានហានិភ័យប្រភេទដូចគ្នា ប៉ុន្តែក្នុងកម្រិតទាបជាងគេ ព្រោះវាត្រូវការទឹកនិងថាមពលតិចជាងគេ ហើយតម្រូវការប្រើជី និងថ្នាំសម្លាប់សត្វចង្រៃក៏មានកម្រិតទាបបំផុតដែរ។ប្រសិនបើកសិករទទួលយកមកអនុវត្តនូវជម្រកត្រីសហគមន៍ (community fish refuges: CFR) ផលិតកម្មតាមការគន់គូរនូវប្រូតេអ៊ីន កាឡូរី និងលីស៊ីន នឹងកើនឡើងក្នុងតំបន់សក្តានុពល។

*សេណារីយ៉ូ៣៖* តាមការគន់គូរ ការផលិតចម្រុះចូលគ្នានូវស្រូវវស្សា/ត្រីស្រែ/សត្វទឹកផ្សេងៗ/បន្លែ ផ្តល់នូវការផ្គត់ផ្គង់ស្បៀងអាហារកម្រិតខ្ពស់បំផុត បើគិតតាមការផលិតប្រូតេអ៊ីន និងលីស៊ីន ហើយផ្តល់នូវ ការផ្គត់ស្បៀងអាហារកម្រិតខ្ពស់បំផុតលំដាប់ទី២ បើគិតតាមការផលិតកាឡូរី។ ប្រភពទាំងបួននៃប្រូតេអ៊ីន អាចរួមចំណែកជួយកាត់បន្ថយបញ្ហាកុមារក្រិន និងកុមារខ្វះទម្ងន់ នៅក្នុងប្រទេសកម្ពុជា។ ចំណែកដុលនៃបន្លែនៅក្នុងសេណារីយ៉ូ៣ វាខ្ពស់ជាងទាំងចំណែករបស់ស្រូវវស្សា និងរបស់ស្រូវប្រាំង ហើយការ

ផលិតបន្លែក្នុងសេណារីយ៉ូនេះអាចជួយបំពេញតម្រូវការក្នុងស្រុកទៀតផង។ ប៉ុន្តែសេណារីយ៉ូ៣ មានបន្ទុកចំណាយខ្ពស់បំផុតលើថាមពល ជី ថ្នាំសម្លាប់សត្វចង្រៃ និងពលកម្ម និងបន្ទុកចំណាយខ្ពស់បំផុតលំដាប់ទី២ លើការផ្គត់ផ្គង់ទឹក។

ការប្រើទឹក និងថាមពល ក៏មានកម្រិតខ្ពស់ដែរ ដូច្នេះ សេណារីយ៉ូ៣ មានហានិភ័យស្រដៀងគ្នានឹងសេណារីយ៉ូ១ ប៉ុន្តែក្នុងកម្រិតទាបជាងបន្តិច ព្រោះសេណារីយ៉ូ៣ មានតម្រូវការទឹកតិចជាង។ ទោះយ៉ាងនេះក្តី សេណារីយ៉ូ៣ ត្រូវប្រើថាមពលអស់ច្រើនជាងគេ។ ផលពាក់ព័ន្ធនៃកសិកម្មប្រើថាមពលកម្រិតខ្ពស់នៅក្នុងតំបន់មានសក្តានុពល គឺជាបញ្ហាសំខាន់មួយដែលត្រូវគិតគូរពិចារណា។

ការប្រើជី និងថ្នាំសម្លាប់សត្វចង្រៃ នៅក្នុងសេណារីយ៉ូ៣ មានហានិភ័យដូចគ្នានឹង សេណារីយ៉ូ១ និង ២ ប៉ុន្តែក្នុងកម្រិតខ្ពស់ជាង ព្រោះដំណាំបន្លែត្រូវមានការប្រើជី និងថ្នាំសម្លាប់សត្វចង្រៃច្រើនជាង។ ស្រដៀងគ្នាដែរ កំណើនការបំភាយ $CH_4$ និង $N_2O$ ដោយសារការដាំស្រូវវស្សា និងបន្លែ អាចបង្កហានិភ័យដូចគ្នានឹងប្រព័ន្ធកសិកម្មក្នុងសេណារីយ៉ូ១ និង ២ ប៉ុន្តែក្នុងកម្រិតខ្ពស់ជាង។ ទោះយ៉ាងនេះក្តី ប្រសិនបើគ្មានការដាក់ជីអសរីរាងទេនោះ គឺគ្មានហានិភ័យអ្វីខុសគ្នាទេរវាងសេណារីយ៉ូទាំងនេះ។ ម្យ៉ាងទៀត ប្រសិនបើកសិករទទួលយកមកអនុវត្តនូវ ជម្រកត្រីសហគមន៍ ហើយផលិតបន្លែបានទិន្នផលខ្ពស់ សេណារីយ៉ូ៣ អាចផលិតស្បៀងអាហារបានច្រើនជាងបើគិតតាមបរិមាណប្រូតេអ៊ីន កាឡូរី និង លីស៊ីន។

## ការប្រៀបធៀបពីការទទួលយកបច្ចេកវិទ្យា និងរបៀបអនុវត្តន៍ល្អ ក្នុងសេណារីយ៉ូទាំង៣

ក្នុងផ្នែកនេះ មានការបៀបធៀបលទ្ធផលសម្រាប់ សេណារីយ៉ូ១+SRI, សេណារីយ៉ូ២+CFR, និង សេណារីយ៉ូ៣+CFR+ទិន្នផលបន្លែខ្ពស់។ ផលិតកម្មប្រចាំឆ្នាំតាមការគន់គូរនូវ ប្រូតេអ៊ីន និង លីស៊ីន(lysine) ក្នុងតំបន់មានសក្តានុពល មានកម្រិតខ្ពស់បំផុតក្នុងសេណារីយ៉ូ៣៖ ផលិតកម្មប្រូតេអ៊ីនបានប្រហែល ១០២.៣២១ តោនច្រើនជាងសេណារីយ៉ូ១ និងប្រហែល ២១.៨៦៦ តោនច្រើនជាងសេណារីយ៉ូ២ រីឯ ផលិតកម្មលីស៊ីនបានប្រហែល ១៣.១៧៥ តោនច្រើនជាងសេណារីយ៉ូ១ និងប្រហែល ១.០៣០ តោនច្រើនជាងសេណារីយ៉ូ២ ។ សេណារីយ៉ូ៣ ផលិតបានប្រហែល ២៨៩ លានគីឡូកាឡូរី/ឆ្នាំ ច្រើនជាងសេណារីយ៉ូ២ ប៉ុន្តែបានប្រហែល ២.៣៦៧ លានគីឡូកាឡូរី/ឆ្នាំ តិចជាងសេណារីយ៉ូ១ ។

ការសិក្សានេះមិនអាចប្រៀបធៀបបានទេនូវ តម្រូវការទឹកនិងថាមពល រវាងសេណារីយ៉ូទាំងបី ដោយមាន ឬក៏គ្មាន ការបណ្តុះបណ្តាលនិងការទទួលយកបច្ចេកវិទ្យាថ្មី ព្រោះមិនអាចរកទិន្នន័យបែបនេះបាន។ ទោះយ៉ាងនេះក្តី សិក្សាបានបង្ហាញថា ការទទួលយក SRI ក្នុងសេណារីយ៉ូ១ អាចជួយកាត់បន្ថយការប្រើប្រាស់ទឹករហូតដល់៥០%ហើយការទទួលយកSRIក្នុងសេណារីយ៉ូ២និង៣ អាចជួយរក្សាសំចៃទឹកនិងថាមពល ព្រោះវិធីសាស្រ្តនេះជួយកាត់បន្ថយទឹកជំនន់ក្នុងរដូវវស្សា និងជួយរក្សាសំចៃទឹកទុកក្នុងរដូវប្រាំង។

## សេចក្តីសន្និដ្ឋាន

ការប្រៀបធៀបរវាងសេណារីយ៉ូទាំង ៣ ដោយមាន ឬគ្មានការគាំទ្រ ការបណ្តុះបណ្តាល ការទទួលយកបច្ចេកវិទ្យា និងរបៀបអនុវត្តន៍ល្អៗ បង្ហាញថា ១)ផលិតកម្មប្រូតេអ៊ីនតាមការគន់គូរមានកម្រិតខ្ពស់បំផុតក្នុងសេណារីយ៉ូ៣ ទាំងក្នុងករណីមាន និងគ្មាន ការបណ្តុះបណ្តាល និងការទទួលយកបច្ចេកវិទ្យា រីឯសេណារីយ៉ូ១ ត្រូវធ្លាក់ទៅលំដាប់ទី៣ ហើយសេណារីយ៉ូ២ ឡើងដល់លំដាប់ទី២ វិញ ២)ការធ្វើចំណាត់ថ្នាក់ផលិតកម្មកាឡូរីតាមការគន់គូរ នៅតែគ្មានការផ្លាស់ប្តូរ គឺ សេណារីយ៉ូ១ ស្ថិតនៅលំដាប់ទី១ហើយសេណារីយ៉ូ៣ស្ថិតនៅលំដាប់ទី២ ៣)ផលិតកម្មលីស៊ីនតាមការគន់គូរ មានកម្រិតខ្ពស់បំផុតក្នុងសេណារីយ៉ូ៣ ទាំងក្នុងករណីមាន និងគ្មាន ការបណ្តុះបណ្តាល និងការទទួលយកបច្ចេកវិទ្យា ហើយសេណារីយ៉ូ២ ឡើងទៅលំដាប់ទី២ រីឯសេណារីយ៉ូ១ ធ្លាក់ទៅលំដាប់ទី៣។ សរុបមក សេណារីយ៉ូ៣ មានសក្តានុពលខ្លាំងជាងគេ ក្នុងការបង្កើនផលិតកម្មស្បៀងអាហារបើគិតតាមបរិមាណប្រូតេអ៊ីន កាឡូរី និងលីស៊ីន នៅក្នុងតំបន់មានសក្តានុពល។

សេណារីយ៉ូ ឬគោលនយោបាយខុសៗគ្នាក្នុងការអភិវឌ្ឍកសិកម្មនាពេលអនាគត មានផលពាក់ព័ន្ធខុសៗគ្នា។ ប្រសិនបើគោលដៅចម្បងគេ គឺ ការបង្កើតប្រាក់ចំណូលពីការនាំចេញអង្ករ និងកំណើនការផ្គត់ផ្គង់កាឡូរីនោះ សេណារីយ៉ូ១ ដែលមានការដាំស្រូវពីរដង វាផ្តល់លទ្ធផលបានច្រើនជាអតិបរមា។ ប្រសិនបើគោលដៅចម្បង គឺ ប្រាក់ចំណេញច្រើនជាអតិបរមាសម្រាប់កសិករ និងកំណើនការផ្គត់ផ្គង់ស្បៀងអាហារមានសារធាតុចិញ្ចឹមច្រើន (ដើម្បីកាត់បន្ថយបញ្ហាកុមារក្រិន ជាដើម) គឺ សេណារីយ៉ូ៣ (ស្រូវ ត្រី បន្លែ) ដែលប្រសើរបំផុត។ នាពេលអនាគតដែលមានការកសាងទំនប់នៅតំបន់ខ្សែទឹកខាងលើ និងការប្រែប្រួលអាកាសធាតុនោះ ការផ្គត់ផ្គង់ទឹក គឺកាន់តែមិនអាចទុកចិត្តបានខ្លាំងឡើង។ ក្នុងស្ថានភាពនេះ សេណារីយ៉ូ១ ដែលមានតម្រូវការទឹកច្រើនបំផុត វាមានហានិភ័យខ្លាំងជាងគេ ចំណែកឯសេណារីយ៉ូ៣ គឺមានហានិភ័យកម្រិតមធ្យម។ គុណវិបត្តិចម្បងនៃសេណារីយ៉ូ៣ គឺវាត្រូវការថាមពលច្រើនជាងសេណារីយ៉ូពីរផ្សេងទៀត។

ការស្រាវជ្រាវនេះបានបង្ហាញពី បន្ទុកចំណាយ និងអត្ថប្រយោជន៍នៃ ជម្រើស ៣ ខុសៗគ្នា សម្រាប់ការអភិវឌ្ឍកសិកម្មនៅកម្ពុជា។វិទ្យាស្ថាន CDRI ត្រៀមខ្លួនជាស្រេចដើម្បីផ្តល់ការជួយគាំទ្រដល់ស្ថាប័នកម្ពុជានានា ដែលចង់ស្វែងយល់កាន់តែច្បាស់ពីជម្រើសទាំងនេះ ដើម្បីជួយលើកកម្ពស់គោលនយោបាយរបស់រដ្ឋាភិបាល និងកម្មវិធីកំពុងដំណើរការផ្សេងៗ។

## ឯកសារយោង


Abrams, Julian Hilton. 2015. *Climate Resilient Irrigation Training: Promoting Climate Resilient Water Management and Agriculture Practice in Rural Cambodia.* Phnom Penh: MAFF Project Support Unit.

Anthofer, Jürgen. 2004. An Evaluation of the System of Rice Intensification in Cambodia. Report to the German Agency for Development Cooperation (GTZ). Phnom Penh.

Brooks, Alan, and Celine Sieu. 2016. The Potential of Community Fish Refuges (CFRs) in Rice Field Agro-ecosystems for Improving Food and Nutrition Security in the Tonle Sap Region. Penang, Malaysia: WorldFish

Bühler, Dorothee, Ulrike Grote, Rebecca Hartje, Bopha Ker, Do Truong Lam, Loc Duc Nguyen, Trung Thanh Nguyen and Kimsun Tong. 2015. *Rural Livelihood Strategies in Cambodia: Evidence from a Household Survey in Stung Treng.* Working Paper 137. Bonn: Center for Development Research, University of Bonn.

Canakci, M., M. Topakci, I. Akinci and A. Ozmerzi. 2005. "Energy Use Pattern of Some Field Crops and Vegetable Production: Case Study for Antalya Region, Turkey." *Energy Conversion and Management* 46(4), 655-666.

FAO (Food and Agriculture Organization). 1953. *Food Composition Tables for International Use.* 2nd edition. www.fao.org/docrep/x555 7e/x5557e00.htm.

FAO. 2001. *Food Balance Sheets: A Handbook.* www.fao.org/3/a-x9892e.pdf.

FAOSTAT. 2016. "Food and Agriculture Data." http://faostat3.fao.org/home/E.

Gregory, R., H. Guttman and T. Kekputhearith. 1996. *Poor in All but Fish: A Study of the Collection of Rice Field Foods from Three Villages in Svay Theap District, Svay Rieng.* AIT Aqua Outreach (Cambodia) Working Paper(4). Bangkok: Asian Institute of Technology.

Guttman, H. 1999. "Rice-field Fisheries — A Resource for Cambodia." AIT Aqua Outreach. Unpublished Paper.

Hortle, K., R.Troeung and S. Lieng. 2008. Yield and Value of the Wild Fishery of Rice Fields in Battambang Province, Near the Tonle Sap Lake, Cambodia. MRC Technical Paper No. 18. Vientiane: Mekong River Commission.

IRRA. 2010. Crop Area Map of Cambodia in 2010.

Islam, A.K.M.S., M.M. Hossain, R.I. Sarker, M.A. Saleque, M.A. Rahman, M.E. Haque and R.W. Bell. 2011. "Energy Utilization in Unpuddled Transplanting of Wet Season Rice." In *Proceedings of the 5th World Congress on Conservation Agriculture*, 133-136, 26-29 September, Brisbane, Australia.

MAFF (Ministry of Agriculture, Forestry and Fisheries). 2015. *Agricultural Sector Strategic Development Plan 2014-2018*. Phnom Penh: MAFF.

MAFF. 2016. *Annual Report for Agriculture Forestry and Fisheries 2015-2016*. Phnom Penh: MAFF.

McKenney, Bruce, and Prom Tola. 2002. *Natural Resources and Rural Livelihoods in Cambodia: A Baseline Assessment*. Working Paper No. 23. Phnom Penh: CDRI.

Nesbitt, Harry J., ed. 1997. *Rice Production in Cambodia*. Manilla: International Rice Research Institute.

Nurhasan, Mulia, Hanne K. Maehre, Marian Kjellevold Malde, Svein K. Stormo, Matthias Halwart, David James and Edel O. Elvevoll. 2010. "Nutritional Composition of Aquatic Species in Laotian Rice Field Ecosystems." *Journal of Food Composition and Analysis* 23:205-213.

ODC (Open Development Cambodia). 2015. Rice Ecosystem Map for Cambodia. https:// opendevelopmentcambodia.net/layers/rice-ecosystem-map-for-cambodia/.

ODC. 2016. Soil Fertility of Cambodia. https://opendevelopmentcambodia.net/ layers/soil-fertility-map-.

Pittock, Jamie, David Dumaresq and Stuart Orr. 2015. "The Mekong River: Trading Off Hydropower, Fish and Food." *Regional Environmental Change:*1-11 doi: 10.1007/s 10113-017-1175-8.

RGC (Royal Government of Cambodia). 2015. *National Strategic Development Plan 2014-2018*. Phnom Penh: Council for the Development of Cambodia.

Ros Bansok, Chhim Chhun and Nang Phirun. 2011. *Agricultural Development and Climate Change: The Case of Cambodia*. Working Paper Series No. 65. Phnom Penh: CDRI.

Tech Chey. 2004. "Ecological System of Rice Intensification (SRI) Impact Assessment. CEDAC Field Document." Phnom Penh: Cambodian Center for Agricultural Studies and Development.

Theng Vuthy, Khiev Pirom and Phon Dary. 2014. *Development of the Fertiliser Industry in Cambodia: Structure of the Market, Challenges in the Demand and Supply Sides, and the Way Forward*. Working Paper Series No. 91. Phnom Penh: CDRI.

Thouk N. 2009. "Community Fish Refuge Husbandry in Lowland Agriculture Ecosystem." Doctoral thesis, Build Bright University, Phnom Penh.

Troeung, R., Aun, S., Lieng, S., Deap, L. and N. van Zalinge. 2003. "A Comparison of Fish Yields and Species Composition between One Fishing Lot in Battambang Province and Two Fishing Lots in Prey Veng Province." *MRC Conference Series* 4: 9-16.

Uphoff, Norman. 2006. "The System of Rice Intensification (SRI) as a Methodology for Reducing Water Requirements in Irrigated Rice Production." Paper presented at the International Dialogue on Rice and Water: Exploring Options for Food Security and Sustainable Environments, Los Baños, Philippines, 7-8 March. http://citeseerx.ist.psu.edu/ viewdoc/download?doi=10.1.1.512.7440&rep=rep1&type=pdf.

World Bank. 2015. *Cambodian Agriculture in Transition: Opportunities and Risks*. Washington, DC: World Bank.

# ដំណើរការ និងបញ្ហាប្រឈមនៃវិសហមជ្ឈការនៅកម្ពុជា៖ ករណីសិក្សាលើការគ្រប់គ្រងកាកសំណល់រឹងទីប្រជុំជន

## សេចក្ដីផ្ដើម

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាបានឈានចូលដំណាក់កាលថ្មីមួយ ទោះបីកន្លងមកទទួលបានលទ្ធផលចម្រុះក្ដី។ ការសង្កត់ធ្ងន់ឡើងវិញលើកំណែទម្រង់ស៊ីជម្រៅដោយគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ បានជួយជំរុញកំណែទម្រង់វិមជ្ឈការទៅមុខទៀត។ ចាប់ពីឆ្នាំ២០១៥ មក នៅថ្នាក់ស្រុក និងថ្នាក់ក្រុងមានការរៀបចំប្រព័ន្ធរដ្ឋបាលឡើងវិញ តាមរយៈ ការផ្ទេរមុខងារផ្សេងៗពីក្រសួងជំនាញ ទៅឲ្យរដ្ឋបាលស្រុក និងរដ្ឋបាលក្រុង។ ដូចរដ្ឋាភិបាលបានប្រកាសឡើង ការផ្ទេរមុខងារមានគោលដៅធ្វើឲ្យ ស្ថាប័នទទួលបន្ទុកផ្ដល់សេវាកាន់តែខិតទៅជិតប្រជាជន ដើម្បីលើកកម្ពស់គំនិតផ្ដួចផ្ដើមនៅថ្នាក់មូលដ្ឋាន និងពង្រឹងគណនេយ្យភាព (Sar 2015)។ ក្នុងស្ថានភាពនេះ ដំណាក់កាលថ្មីនៃកំណែទម្រង់វិមជ្ឈការ គឺជា កិច្ចប្រឹងប្រែងសម្រេចឲ្យបានគោលដៅរំពឹងទុកនៃការផ្ដល់សេវាតាមបែបវិមជ្ឈការ។

ចំណុចប្លែកពីមុននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមួយរយៈចុងក្រោយនេះ គឺការបង្ហាញច្បាស់ជាសាធារណៈនូវឆន្ទៈនយោបាយ។ តួយ៉ាង អនុប្រធានលេខាធិការដ្ឋាន គជអប បានកំណត់យកការផ្ទេរមុខងារ[១] ធ្វើជាចំណុចស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយប្រកាសថា "បើនិយាយពីកម្មវិធីកំណែទម្រង់ គឺនិយាយពីការផ្ទេរមុខងារ និង ធនធាន ប្រសិនបើគ្មានការផ្ទេរមុខងារ និងធនធាន គឺគ្មានកម្មវិធីកំណែទម្រង់" (NCDD 2015)។ ឧបនាយករដ្ឋមន្ត្រី និងជាប្រធាន គជអប ក៏បានថ្លែងថា ការយឺតយ៉ាវក្នុងដំណាក់កាលមុននៃកំណែទម្រង់ បណ្ដាលមកពីភាពរារែករបស់ក្រសួងជំនាញនានា ហើយក៏បានជំរុញក្រសួងទាំងនោះ ឲ្យយកចិត្តទុកដាក់ ទៅលើការងារកំណែទម្រង់ (Sar 2015)។ តាមរយៈការពន្លឿនការផ្ទេរមុខងារ រាជរដ្ឋាភិបាលហាក់ដូចបានទុកមួយឡែកនូវ ក្ដីបារម្ភពីភាពមិនស៊ីគ្នារវាងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងទំនួលខុសត្រូវកាន់តែធំឡើង ហើយរាជរដ្ឋាភិបាលក៏កាន់តែមានឆន្ទៈទទួលស្គាល់ពីធាតុផ្សំចាំបាច់ សម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចជា សិទ្ធិអំណាចធ្វើការសម្រេចចិត្ត និងធនធាន ជាដើម។ ផ្អែកលើការប្ដេជ្ញាចិត្តនេះ គេអាចនិយាយបានថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅពេលនេះ លែងគ្រាន់តែជាវិមជ្ឈការផ្នែកនយោបាយ ដូចវិមជ្ឈការកម្រិតឃុំសង្កាត់ កាលពីមុនទៀតហើយ ប៉ុន្តែវាក៏ជា វិមជ្ឈការផ្នែករដ្ឋបាល ផងដែរ។

## សាវតា: បញ្ហាកាកសំណល់ និងតម្រូវការឲ្យមានការផ្ទេរមុខងារ

ទន្ទឹមគ្នានឹងកំណើនប្រជាជន និង នគរូបនីយកម្មយ៉ាងឆាប់រហ័ស បញ្ហាកាកសំណល់នៅទីប្រជុំជន និងបញ្ហាសុខភាពសាធារណៈផ្សេងៗក៏កើនឡើង ដោយចោទខ្លាំងជាពិសេសនៅរាជធានីភ្នំពេញដែលជាទីក្រុងធំជាងគេនៅកម្ពុជា និងមានការផលិតកាកសំណល់រឹងជាង ១000តោនជារៀងរាល់ថ្ងៃ (Blue Media Cambodia 2015)។ ដោយសារបញ្ហាប្រឈមទាំងនេះ និងគោលដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្រោយពេលបោះឆ្នោតឆ្នាំ២០១៣ ក្រសួងបរិស្ថាន បានសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញនូវប្រកាសអន្តរក្រសួង ក្នុងឆ្នាំ២០១៥ ស្ដីពី ការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ នៅតាមទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ថវិកា ៥ លានដុល្លារ ត្រូវបានវិភាជទៅឲ្យ ២៦ ក្រុង ទូទាំងប្រទេស ដោយផ្អែកទៅតាមចំនួនប្រជាជននៃក្រុងនីមួយៗ។ ការវិភាជថវិកានេះ បានបើកផ្លូវឲ្យមានការផ្ទេរមុខងារគ្រប់គ្រងកាកសំណល់រឹង ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ទាប់មកទៀត រាជរដ្ឋាភិបាល បានចេញ អនុក្រឹត្យស្ដីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ដើម្បីដាក់ឲ្យដំណើរការថវិកានេះ ដោយកំណត់ភារកិច្ចទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ពោលគឺ រដ្ឋបាលរាជធានី ក្រុង និងស្រុក ។ ការសិក្សានេះផ្ដោតតែលើការគ្រប់គ្រងកាកសំណល់រឹងនៅថ្នាក់ក្រុង ពីព្រោះនៅពេលបច្ចុប្បន្នថវិកាត្រូវបានវិភាជឲ្យតែរដ្ឋបាលក្រុងប៉ុណ្ណោះ។

## សំណួរស្រាវជ្រាវ

ការផ្ទេរមុខងារដែលចាប់ផ្ដើមឡើងក្នុងឆ្នាំ២០១៥ ជាសញ្ញាបង្ហាញថា វិសហមជ្ឈការដែលគេទន្ទឹងរង់ចាំនោះបានចូលមកដល់ហើយ។ ដោយផ្អែកលើការវិភាគឯកសារ និងការធ្វើសម្ភាសន៍ស៊ីជម្រៅ ការសិក្សានេះមានគោលដៅលើកកម្ពស់ការយល់ដឹងពីស្ថានភាពនៃវិសហមជ្ឈការ ដោយព្យាយាមឆ្លើយនឹងសំណួរស្រាវជ្រាវដូចខាងក្រោម៖

---

អត្ថបទនេះរៀបរៀងឡើងដោយ វង់ ម៉ាន់ ជាអ្នកស្រាវជ្រាវក្នុងផ្នែកអភិបាលកិច្ចនៃវិទ្យាស្ថាន CDRI ។ សូមយោងឯកសារនេះថា៖ Vong Mun. 2017. “Progress and Challenges of Deconcentration in Cambodia: The Case of Urban Solid Waste Management.” *Cambodia Development Review* 21 (2): 8-11។

១ ពាក្យនេះក៏ឃើញមានប្រើនៅក្នុងឯកសារនានារួមមាន ការផ្ទេរមុខងារ និងការកំណត់មុខងារឡើងវិញ។

***តើមានសិទ្ធិ និងទំនួលខុសត្រូវអ្វីខ្លះសម្រាប់ការគ្រប់គ្រងកាកសំណល់រឹង ដែលត្រូវបានផ្ទេរវិសហមជ្ឈការទៅឲ្យរដ្ឋបាលក្រុង។ តើរដ្ឋបាលក្រុងប្រឈមមុខនឹងបញ្ហាអ្វីខ្លះ ក្នុងការអនុវត្តសិទ្ធិ និងទំនួលខុសត្រូវទាំងនោះ។***

## គោលគំនិតសំខាន់ៗ

វិសហមជ្ឈការ ជាបែបផែនមួយ សម្រាប់ធ្វើការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយបែបផែនមួយទៀតគឺ វិមជ្ឈការ។ នៅពេលមុខងារអ្វីមួយត្រូវបានធ្វើវិសហមជ្ឈការ គឺក្រសួងរក្សាទុកនូវសិទ្ធិអំណាចធ្វើ សេចក្តីសម្រេចផ្សេងៗផ្នែកគោលនយោបាយ និងថវិកា រីឯរដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវលើការអនុវត្តមុខងារ និងត្រួតពិនិត្យលើបុគ្គលិកដែលផ្ទេរមកពីក្រសួង។ មុខងារគឺជា សកម្មភាពជាសំណុំ ដូចជា ការគ្រប់គ្រងកាកសំណល់រឹង ការគ្រប់គ្រងមណ្ឌលសុខភាព ឬការថែទាំការផ្គត់ផ្គង់ទឹកស្អាតជនបទជាដើម ដែលរួមចំណែកដល់ដំណើរការនៃប្រព័ន្ធអភិបាលកិច្ច (Pak 2011)។ ការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងកំណែទម្រង់បច្ចុប្បន្ន រួមមាន ការប្រគល់មុខងារ និងការធ្វើប្រតិភូកម្មមុខងារ។ ការប្រគល់មុខងារ សំដៅដល់ "ការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិទាំងអស់ដែលចាំបាច់ដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារ"។ ការធ្វើប្រតិភូកម្មមុខងារ សំដៅដល់ "ការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម" (RGC 2012, 3)។ ជារួម ការប្រគល់មុខងារគឺជា វិសហមជ្ឈការក្នុងទម្រង់ស៊ីជម្រៅជាងការធ្វើប្រតិភូកម្មមុខងារ។ ការប្រគល់មុខងារផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិអំណាចច្រើនជាង ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនដូចមានកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់។

## លទ្ធផលសិក្សា

### *ក្របខ័ណ្ឌច្បាប់: ទំនួលខុសត្រូវ សិទ្ធិ និងធនធាន*

ដំណើរការផ្ទេរមុខងារបាននាំមកនូវការផ្លាស់ប្តូរធំៗមួយចំនួន។ អនុក្រឹត្យឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងកាកសំណល់រឹងទីប្រជុំជន បានកំណត់ឲ្យរដ្ឋបាលក្រុងនូវ ទំនួលខុសត្រូវធំៗ ៥ សម្រាប់ការគ្រប់គ្រងកាកសំណល់រឹង គឺ ១) រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាព និង ថវិកាប្រចាំឆ្នាំ ២) រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ៣) បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ៤) ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំណល់រឹងទីប្រជុំជន ៥) អប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំរាម និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

ដើម្បីជួយទ្រទ្រង់ដល់ការអនុវត្តមុខងារ រដ្ឋបាលក្រុងត្រូវបានអនុញ្ញាតឲ្យ ១) ចេញជាដីកា ឬលិខិតបទដ្ឋាននានា ២) រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ៣) ធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់ជាប់គ្នាក្នុងការផ្តល់សេវារួមគ្នា ៤) ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ទៅឲ្យរដ្ឋបាលសង្កាត់ ឬប្រគល់សិទ្ធិទៅឲ្យសហគមន៍អនុវត្តមុខងារណាមួយ ឬមួយចំនួន ៥) កំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ៦) ប្រើប្រាស់ថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ៧) អនុម័តលើសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ (RGC 2015)។

ចំពោះធនធានវិញ នៅឆ្នាំ២០១៥ ក្រុងនានាក្នុងការសិក្សានេះបានទទួលមូលនិធិពី ៤៥.០០០ដុល្លារ ទៅ ៩០.០០០ដុល្លារ អាស្រ័យទៅលើចំនួនប្រជាជននៅក្នុងក្រុងនីមួយៗ។ ថវិកានេះគឺជាការផ្លាស់ប្តូរមួយយ៉ាងសំខាន់ បើធៀបនឹងថវិកាដ៏តិចតួចរបស់អាជ្ញាធរខេត្តសម្រាប់ការគ្រប់គ្រងសំណល់រឹង នៅមុនពេលមានការផ្ទេរមុខងារ (Pak and Craig 2008)។ ម៉្យាងទៀត រដ្ឋបាលក្រុងនឹងអាចបង្កើតប្រាក់ចំណូលផ្ទាល់ តាមរយៈ កម្រៃសេវាប្រមូលសំរាម សំណល់រឹង។ ដោយផ្អែកលើ កម្រៃសេវាអតិបរមារៀបចំឡើងដោយក្រសួងជំនាញ រដ្ឋបាលក្រុងអាចកំណត់ កម្រៃសេវាសម្រាប់តំបន់របស់ខ្លួន ដោយផ្អែកលើប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល និងបរិមាណកាកសំណល់។ មុននឹងឈានដល់សេចក្តីសម្រេចនេះ រដ្ឋបាលក្រុងត្រូវពិគ្រោះយោបល់ជាមួយអ្នកប្រើប្រាស់សេវា និងភាគីពាក់ព័ន្ធផ្សេងៗ។ រដ្ឋបាលក្រុងក៏មានភារកិច្ចរៀបចំយន្តការផ្សេងៗ សម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់ កម្រៃសេវា ផងដែរ។ ថ្វីបើមានការវិភាជថវិកាទៅឲ្យរដ្ឋបាលក្រុងក្តី ប៉ុន្តែនៅមិនទាន់មានការផ្ទេរបុគ្គលិកសម្រាប់មុខងារនេះទេ។

រដ្ឋបាលក្រុងបានប្រើប្រាស់កញ្ចប់ថវិកា សម្រាប់សកម្មភាពផ្សេងៗ ដើម្បីលើកសោភណភាពក្រុង រួមមាន ការប្រមូលសំរាម ការបោសសម្អាតផ្លូវសំខាន់ៗ ការកាត់តម្រឹមដើមឈើ ការដាក់ធុងសំរាម និងការដាក់បដាអប់រំផ្សេងៗ។ មានក្រុងមួយបានប្រើប្រាស់ថវិកាមួយភាគ ដើម្បីជួសជុលផ្លូវចូលទៅទីលានចាក់សំរាម។ លើកលែងតែក្រុងមួយនេះ ដែលប្រើប្រាស់ទម្រង់ចម្រុះរដ្ឋ-ឯកជន ក្នុងការអនុវត្តមុខងារ ក្រុងឯទៀតៗបានជ្រើសយកវិធី ម៉ៅការទៅឲ្យអ្នកផ្តល់សេវាឯកជន ដែលក្រុងបានជ្រើសរើសតាមរយៈគណៈកម្មការលទ្ធកម្មរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពដូចបានរៀបរាប់ខាងលើ។ ក្នុងករណីនេះ រដ្ឋបាលក្រុងផ្តោតជាសំខាន់ទៅលើ ការត្រួតពិនិត្យលទ្ធផលការងាររបស់អ្នកម៉ៅការឯកជន។ នៅក្រុងមួយក្រុមប្រឹក្សាសង្កាត់ ត្រូវបានស្នើឲ្យជួយធ្វើការត្រួតពិនិត្យ ហើយ

ព័ត៌មានត្រូវរាយការណ៍ទៅឲ្យរដ្ឋបាលក្រុងតាមទូរស័ព្ទ។

### *ទំនាក់ទំនងរវាងស្ថាប័នរបស់ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ៖ ជំនួយគាំទ្រ និងការត្រួតពិនិត្យ*

នៅក្រោមរចនាសម្ព័ន្ធថ្មី តួនាទីថ្មីរបស់មន្ទីរបរិស្ថានខេត្តក្នុងការគ្រប់គ្រងកាកសំណល់រឹង រួមមាន៖ ១) លើកកម្ពស់ការយល់ដឹងពីបញ្ហាបរិស្ថាន ២) ចូលរួមកសាងផែនការគ្រប់គ្រងកាកសំណល់រឹង ៣) ជួយផ្តល់មតិណែនាំផ្នែកបច្ចេកទេសលើគម្រោង ឬសំណើគ្រប់គ្រងកាកសំណល់រឹង ៤) តាមដានត្រួតពិនិត្យ និងវាយតម្លៃដំណើរការ គ្រប់គ្រងកាកសំណល់រឹង ៥) រៀបចំរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ អំពីស្ថានភាព និងដំណើរការគ្រប់គ្រងកាកសំណល់រឹង (RGC 2015)។ ដោយសារទំនួលខុសត្រូវទាំងនេះ រដ្ឋបាលក្រុង អាចចូលរួមកាន់តែមានប្រយោជន៍ជាមួយមន្ទីរ បើធៀបនឹងកាលពីមុនដែលទំនាក់ទំនងរវាងភាគីទាំងពីរ មានត្រឹមតែការចូលរួមម្តងម្កាលក្នុងព្រឹត្តិការណ៍សាធារណៈទាក់ទងនឹងបរិស្ថានតែប៉ុណ្ណោះ។

ជាក់ស្តែងរហូតមកទល់បច្ចុប្បន្ន ទំនាក់ទំនងរវាងរដ្ឋបាលក្រុងជាមួយនឹង មន្ទីរបរិស្ថាន មិនមានការប្រែប្រួលគួរឲ្យកត់សម្គាល់ទេ នៅតាមក្រុងដែលបានចុះសិក្សា។ នៅក្រុងមួយ អ្នកឆ្លើយតបម្នាក់នៅមន្ទីរបរិស្ថាន បានបង្ហាញពីការមិនពេញចិត្តជាមួយនឹងរដ្ឋបាលក្រុង ដោយត្អូញត្អែរថា រដ្ឋបាលក្រុងកាន់តែមានស្វ័យភាព និងសិទ្ធិអំណាចសម្រេចអារកាត់ច្រើនឡើង។ គាត់មានប្រសាសន៍ថា៖ "ពួកគេមិនស្តាប់មន្ទីរជំនាញ ឬខេត្តទេ"។ គាត់ក៏រារែកក្នុងចិត្តចំពោះផែនការជ្រើសរើសអ្នកផ្តល់សេវាថ្មីដែរ ព្រោះគាត់គិតថា អ្នកផ្តល់សេវាសព្វថ្ងៃបានជួយច្រើនណាស់ ដោយបានឆ្លើយតបតាមសំណើផ្សេងៗរបស់មន្ទីរ ហើយគាត់មិនទុកចិត្តថាអ្នកថ្មីអាចធ្វើបានដូចគ្នាទេ។ គាត់ថែមទាំងបានលើកមតិថា មន្ទីរបរិស្ថាន គួរតែទទួលបានកញ្ចប់ថវិកា មិនមែនរដ្ឋបាលក្រុងទេ។ រហូតមកដល់ពេលថ្មីៗនេះ មន្ទីរបរិស្ថាននៅខេត្តនោះ គឺជាអ្នកត្រួតពិនិត្យលើ អ្នកផ្តល់សេវាឯកជន ដែលត្រូវបានជ្រើសរើសដោយអតីតប្រធានមន្ទីរ។

នៅក្រុងមួយទៀត មន្ទីរបរិស្ថាន មិនសូវបានពាក់ព័ន្ធច្រើនក្នុងការផ្ទេរមុខងារនេះទេ។ ការត៉ៅ គឺមានពីរដ្ឋបាលក្រុងមកវិញ។ អ្នកឆ្លើយតបម្នាក់នៅរដ្ឋបាលក្រុងបានត្អូញត្អែរថា មន្ទីរបរិស្ថានខេត្តមិនបានជួយអ្វីច្រើនទេក្នុងការគ្រប់គ្រងកាកសំណល់ ទាំងនៅមុនពេល និងក្រោយពេល ផ្ទេរមុខងារ។ គាត់មានប្រសាសន៍ថា "ខ្ញុំធ្លាប់សួរពួកគេថា តើថវិកាអាចយកទៅប្រើសម្រាប់សកម្មភាពលើកកម្ពស់ការយល់ដឹងនិងទិញធុងសំរាមបានដែរឬទេពីព្រោះប្រកាសមិនបានចែងច្បាស់ ហើយពួកគេប្រាប់ថា ពួកគេក៏មិនដឹងដែរ"។

នៅក្រុងមួយផ្សេងទៀត មន្ទីរបរិស្ថាន មានភាពតឹងតែង។ អ្នកឆ្លើយតបម្នាក់នៅរដ្ឋបាលក្រុងបាននិយាយថា សំណើរបស់គាត់លើការប្រើប្រាស់ថវិកា ដើម្បីលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន ត្រូវបានខាងមន្ទីរច្រានចោលដោយអះអាងថា ថវិកានេះគឺប្រើសម្រាប់តែការផ្តល់សេវា និងធ្វើអន្តរាគមន៍ប៉ុណ្ណោះ ថ្វីបើសាមីខ្លួនគាត់យល់ឃើញថា អនុក្រឹត្យបានអនុញ្ញាតក្តី។ គាត់បានសារភាពថា ធ្វើតាមអ្វីដែលបុគ្គលនិយាយ វាសំខាន់ជាងធ្វើតាមអ្វីដែលមានចែងលើក្រដាស ពីព្រោះ ពួកគេមានសិទ្ធិអំណាចអនុម័តលើសំណើថវិកា។ តាមរយៈប្រសាសន៍នេះ គាត់ហាក់បង្ហើបឲ្យដឹងពី ឥទ្ធិពលនៃមន្ទីរបរិស្ថាន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅលើដំណើរការផ្ទេរថវិកា។ តាមច្បាប់កំណត់ រដ្ឋបាលក្រុងត្រូវដាក់សំណើថវិកា ព្រមទាំងផែនការសកម្មភាព សម្រាប់គ្រប់គ្រងកាកសំណល់រឹង ជូនទៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈមន្ទីរបរិស្ថាន ។

សម្រាប់ក្រសួងបរិស្ថានវិញ តួនាទីចម្បងគឺ ធ្វើអធិការកិច្ចជាទៀងទាត់លើការអនុវត្តមុខងារ។ ក្នុងករណីមានការរំលោភលើសេចក្តីណែនាំពីការគ្រប់គ្រងកាកសំណល់រឹង ក្រសួងអាចស្នើទៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យផ្អាកការផ្ទេរថវិកាទៅឲ្យរដ្ឋបាលក្រុង។ ក្រសួងបរិស្ថានក៏អាចស្នើទៅក្រសួងមហាផ្ទៃឲ្យធ្វើការព្រមានទៅដល់រដ្ឋបាលក្រុងណា ដែលអនុវត្តការងារមិនមានប្រសិទ្ធភាព ឬមិនអនុវត្តតាមការណែនាំបច្ចេកទេសរបស់ក្រសួងបរិស្ថាន (MOE, MOI and MEF 2015)។

### *សមត្ថភាពនៅថ្នាក់ក្រោមជាតិ*

ដូចបានចង្អុលបង្ហាញពីខាងដើម ការផ្ទេរមុខងារនេះមិនរួមបញ្ចូលការផ្ទេរបុគ្គលិកឡើងវិញទេ ហើយរដ្ឋបាលក្រុងប្រឈមនឹងបញ្ហានេះខុសៗគ្នា។ ដោយសារអ្នកម៉ៅការឯកជនទទួលធ្វើការងារភាគច្រើនក្នុងការប្រមូលកាកសំណល់រឹង ដូច្នេះទំនួលខុសត្រូវចម្បងរបស់រដ្ឋបាលក្រុងគឺការត្រួតពិនិត្យ។ មានក្រុងពីរបានបង្កើត ក្រុមការងារដែលដឹកនាំដោយអភិបាលក្រុងរងម្នាក់ និងមានមន្ត្រីមកពីអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង និងអង្គភាពអភិវឌ្ឍន៍ក្រុង ជួយធ្វើការងារផង។ មានក្រុងមួយ បានអនុវត្តតាមវិធីសាស្ត្រចូលរួម ដោយបានបង្កើតក្រុមការងារមួយដែលដឹកនាំដោយអភិបាលរងក្រុងម្នាក់ និងមានសមាជិកជាមន្ត្រីមកពីមន្ទីរបរិស្ថានខេត្ត និងការិយាល័យបរិស្ថានក្រុង។ ដោយសារមានកម្រិតអភិវឌ្ឍន៍ខ្ពស់ ក្រុងមួយទៀតមានលទ្ធភាពបង្កើតអង្គភាពជំនាញមួយ ដែលធ្វើការលើការគ្រប់គ្រងកាកសំណល់ និងសោភណភាពទីក្រុង តាំងពីមុនពេលមានការផ្ទេរមុខងារម្លេះ។ ដូច្នេះហើយរដ្ឋបាលក្រុងនោះ មានសមត្ថភាពខ្ពស់ជាងគេក្នុងការអនុវត្តមុខងារដែលផ្ទេរមក។ អ្នកឆ្លើយតបម្នាក់នៅក្រុងផ្សេងមានបំណងធ្វើសំណើទៅក្រសួងមហាផ្ទៃបង្កើតអង្គភាពស្រដៀងគ្នាមួយ ដើម្បីសម្រាលបន្ទុកការងារមន្ត្រីរបស់គាត់។ ស្រដៀងគ្នាដែរ អ្នកឆ្លើយតបម្នាក់ទៀតនៅ ក្រុងមួយទៀត បានលើកនូវក្តីបារម្ភពីបន្ទុកការងារមមាញឹករបស់មន្ត្រីគាត់ ហើយគិតថា គួរមានការផ្ទេរបុគ្គលិក រាល់ពេលមានការផ្ទេរមុខងារថ្មីអ្វីមួយ។ តបនឹងក្តីបារម្ភអំពីបន្ទុកងារងារនេះ អ្នកឆ្លើយតបនានានៅមន្ទីរបរិស្ថាន បាននិយាយថា កង្វះបុគ្គលិកនៅថ្នាក់ក្រោមជាតិគឺជាបញ្ហាទូទៅមួយដែលពុំមានដំណោះស្រាយងាយស្រួលទេ ដោយពួកគាត់បានលើកឡើងពីបញ្ហាដូចគ្នានៅក្នុងមន្ទីររបស់គាត់។

ទោះបីមានផលលំបាកផ្នែកធនធានមនុស្សដូច្នេះក្តី ក៏អ្នកឆ្លើយតបគ្រប់គ្នានៅរដ្ឋបាលក្រុង បានទទួលស្វាគមន៍មុខងារថ្មីនិងច្រានចោលទស្សនៈដែលថា រដ្ឋបាលថ្នាក់ក្រោមជាតិខ្វះសមត្ថភាព។ អ្នកឆ្លើយតបម្នាក់នៅរដ្ឋបាលក្រុងមួយបានលើកសំណួរថា៖

បើសិនមិនផ្ទេរមុខងារឲ្យខ្ញុំទេ តើធ្វើយ៉ាងណាអាចដឹងថា ខ្ញុំអាចធ្វើបាន ឬក៏អត់? មិនត្រូវចេះតែគិតថា ថ្នាក់ក្រោមមិនអាចធ្វើបាននោះទេ។ ប្រសិនបើពួកគេពិតជាមិនអាចធ្វើបានមែន អ្នកត្រូវកសាងសមត្ថភាពរបស់ពួកគេ។ រឿងនេះគ្មានអ្វីខុសសោះ។

អ្នកឆ្លើយតបម្នាក់ទៀត នៅរដ្ឋបាលក្រុងមួយទៀតបាននិយាយថា ការផ្ទេរមុខងារបានអនុញ្ញាតឲ្យរដ្ឋបាលក្រុងបំពេញភារកិច្ចរបស់ខ្លួន ជាជាងបន្ទោសអ្នកដទៃពីបញ្ហាផ្សេងៗ ហើយលើកទឹកចិត្តពួកគេឲ្យខំធ្វើការកាន់តែខ្លាំង ដើម្បីកុំឲ្យ "គេមើលងាយ"។

## ការពិភាក្សា និងសេចក្តីសន្និដ្ឋាន

ផ្អែកលើករណីសិក្សាពីការគ្រប់គ្រងកាកសំណល់រឹងទីប្រជុំជនអត្ថបទនេះជាការព្យាយាមដំបូងគេមួយ ដើម្បីវាយតម្លៃពីដំណើរការ និងបញ្ហាប្រឈមនៃវិសហមជ្ឈការ។ ការផ្ទេរមុខងារពិតជាបានជួយផ្តល់សិទ្ធិអំណាចដល់ រដ្ឋបាលក្រុង ក្នុងការផ្តល់សេវាគ្រប់គ្រងកាកសំណល់រឹង ដោយផ្តល់ឲ្យពួកគេនូវទំនួលខុសត្រូវកាន់តែធំ សិទ្ធិ និងថវិកាដែលចាំបាច់ ថ្វីបើការផ្ទេរបុគ្គលិក មិនស្ថិតក្នុងការផ្ទេរនេះក្តី។ ការផ្ទេរមុខងារបានបង្វែរភារកិច្ចគ្រប់គ្រងកាកសំណល់រឹង ពីកម្រិតខេត្ត មកកម្រិតក្រុង ដោយមានអមមកមួយនូវ កញ្ចប់ថវិកាផ្តល់ដោយក្រសួង ដែលកើនឡើងជារៀងរាល់ឆ្នាំ ហើយជំនួយគាំទ្របែបនេះអាជ្ញាធរខេត្តពុំធ្លាប់មានទេ នៅមុនពេលមានការផ្ទេរ។ កញ្ចប់ថវិកាមានទំហំធំគួរសម ប៉ុន្តែត្រូវមានច្រើនជាងនេះប្រសិនបើសេវាគ្រប់គ្រងកាកសំណល់រឹងត្រូវអភិវឌ្ឍបន្ថែម។ សិទ្ធិអំណាចរបស់រដ្ឋបាលក្រុង ក្នុងការបង្កើតប្រាក់ចំណូល តាមរយៈ ការយកកម្រៃលើការប្រមូលកាកសំណល់រឹងក្នុងពេលខាងមុខនេះ អាចជួយពង្រីកកញ្ចប់ថវិការបស់ក្រុង។

ករណីសិក្សានេះ បង្ហាញថា មកទល់សព្វថ្ងៃរដ្ឋបាលក្រុងមិនទាន់ជួបឧបសគ្គអ្វីធំដុំ ក្នុងការអនុវត្តមុខងារនោះទេ ទោះបីជាមានបញ្ហាប្រឈមខ្លះៗក្តី។ ចំពោះទំនាក់ទំនងរវាងស្ថាប័នរបស់ក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិវិញ ទំនាក់ទំនងរវាងរដ្ឋបាលក្រុង ជាមួយនឹងមន្ទីរបរិស្ថានខេត្ត មិនសូវផុលផុសឡើយ សម្រាប់ក្រុងដែលបានចុះសិក្សា។ ប៉ុន្តែគេអាចរំពឹងថា នឹងមានទំនាក់ទំនងកាន់តែច្រើនឡើង នៅពេលក្រសួងចាប់ផ្តើមធ្វើអធិការកិច្ចលើការអនុវត្តមុខងារ។ ទោះជាយ៉ាងនេះក្តី ករណីសិក្សានេះបានរកឃើញ ករណីអនុវត្តសិទ្ធិអំណាចវេតូមួយដោយមន្ទីរបរិស្ថានទៅលើសំណើរបស់រដ្ឋបាលក្រុង ដោយសារពួកគេមិនយល់ស្របគ្នានឹងសកម្មភាពដែលអាចយកថវិកាទៅចាយបាន។ ប៉ុន្តែការប្រើវេតូនោះ ផ្អែកលើការបកស្រាយរបស់មន្ទីរជំនាញពី ខ្លឹមសារនៃបទបញ្ញត្តិច្បាប់ គឺមិនមែនជាសកម្មភាពជ្រៀតជ្រែកក្រៅផ្លូវច្បាប់ ឬ ការប្រើអំណាចរំលោភច្បាប់នោះទេ។ ព្រឹត្តិការណ៍នេះមានអត្ថន័យសំខាន់ចំពោះទំនាក់ទំនងរវាងបទបញ្ញត្តិច្បាប់នឹងអំណាចនៅថ្នាក់មូលដ្ឋាន។ ថ្វីបើការមានបទបញ្ញត្តិច្បាប់ទូលាយ អាចផ្តល់ឱកាសច្រើនដល់ រដ្ឋបាលថ្នាក់ក្រោមជាតិឲ្យធ្វើការផ្តួចផ្តើមគំនិត ប៉ុន្តែវាក៏បង្កើតភាពមិនច្បាស់លាស់ ដែលបើកឱកាសឲ្យមានការបកស្រាយដើម្បីបម្រើផលប្រយោជន៍ណាមួយ។ ក្នុងបរិបទដែលស្ថាប័នសម្រាប់ដោះស្រាយការខ្វែងគំនិតគ្នា ក្នុងការធ្វើសេចក្តីសម្រេច នៅទន់ខ្សោយ ឬមិនទាន់មាននោះ សេចក្តីសម្រេចចិត្តរបស់ថ្នាក់លើ នឹងមានអាទិភាពជាងសេចក្តីសម្រេចចិត្តរបស់ថ្នាក់ក្រោម។ ចំពោះសមត្ថភាពវិញ រដ្ឋបាលក្រុង មានការតាំងចិត្តខ្ពស់និងត្រៀមខ្លួនជាស្រេចដើម្បីបង្ហាញឲ្យឃើញច្បាស់ពីសមត្ថភាពរបស់ខ្លួន ទោះបីមានក្តីបារម្ភខ្លះៗពីកំណើនបន្ទុកការងារក្តី។ ជំហរសុទិដ្ឋិនិយមនេះ ផ្ទុយនឹងទស្សនៈដែលថា រដ្ឋបាលថ្នាក់ក្រោមជាតិ ខ្វះសមត្ថភាព។ ការលើកឡើងថា ការកសាងសមត្ថភាពគ្មានអ្វីខុសទេបើសិនវានៅខ្វះខាត បង្ហាញពីការចង់បានរបស់ រដ្ឋបាលក្រុងឲ្យចាត់ទុកការខ្វះសមត្ថភាពជារឿងធម្មតាជាជាងចាត់ទុកវាជាបញ្ហាដែលរាំងស្ទះដល់ការផ្ទេរមុខងារ។

សរុបមក ករណីសិក្សានេះសន្និដ្ឋានថា ការផ្តល់ សិទ្ធិ ទំនួលខុសត្រូវ និងធនធនច្រើនជាងមុន អាចជួយពង្រឹងតួនាទីរបស់រដ្ឋបាលក្រុង ក្នុងការអភិវឌ្ឍមូលដ្ឋាន និងលើកកម្ពស់គណនេយ្យភាព របស់រដ្ឋបាលក្រុង។ ប៉ុន្តែចំណុចនេះពិបាកសម្រេចបាន ប្រសិនបើនិន្នាការប្រមូលផ្តុំសិទ្ធិអំណាចនៅថ្នាក់ជាតិមិនបានថយចុះព្រមគ្នាទេ។ ទោះជាយ៉ាងណាក្តី នេះគ្រាន់តែជាសេចក្តីសន្និដ្ឋានដំបូងប៉ុណ្ណោះ។ គេអាចមានសេចក្តីសន្និដ្ឋានខុសគ្នា នៅពេលកំណែទម្រង់ដំណើរការទៅមុខទៀត។ វិស័យផ្សេងទៀតដែលមានភាពរសើបផ្នែកនយោបាយច្រើន ដូចជា អប់រំ និងសុខាភិបាល ជាដើម ក៏គួរធ្វើការសិក្សាដែរ ដើម្បីទទួលបានចំណេះដឹងបន្ថែមអំពីដំណើរការវិសហមជ្ឈការ។

## ឯកសារយោង


Blue Media Cambodia. 2015. “Environmental Sanitation Service Budget.”

MOE, MOI and MEF (Ministry of Environment, Ministry of Interior and Ministry of Economy and Finance). 2015. *Joint Ministerial Prakas on the Usage of Sanitation Service Fund for the Implementation of Urban Solid and Liquid Waste Management of Subnational Administrations*.

NCDD (National Committee for Democratic Development). 2015. “H.E Ngoeun Chamroeun: Subnational administrations must prepared to accept functional transfer,” 22 October. http://ncdd.gov.kh/news-kh/sna_must_ready_enough_to_receive_functional_transfer/.

Pak Kimchoeun. 2011. *Fiscal Decentralisation in Cambodia: A Review of Progress and Challenges*. Working Paper Series No. 50. http://cdri.org.kh/webdata/download/ wp/wp50e.pdf.

Pak Kimchoeun and David Craig. 2008. *Accountability and Public Expenditure Management in Decentralised Cambodia*. Working Paper Series No. 38. www.cdri.org.kh/webdata/download/wp/wp38e.pdf.

RGC (Royal Government of Cambodia). 2012. *Sub-decree on the General Process of Transfer of Functions and Resources to Subnational Administrations.*

RGC. 2015. *Sub-decree on Urban Solid Waste Management.*

Sar Kheng. 2015. “Closing Remarks” at the National Workshop on 2015 Activity and Budget Plan of the National Committee for Democratic Development (NCDD-S), Phnom Penh, 4-5 February.

# ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ក្នុងការអប់រំ៖ ការសិក្សាប្រៀបធៀបរវាងបួនប្រទេស

## សេចក្តីផ្តើម

ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស (tracking) គឺការអនុវត្តដាក់សិស្សចូលទៅក្នុងផ្នែកសិក្សា កម្មវិធីសិក្សា ឬ សាលាខុសៗគ្នា ដោយផ្អែកលើសមត្ថភាព លទ្ធផលសិក្សា និង ចំណាប់អារម្មណ៍របស់ពួកគេ។ ការអនុវត្តបែបនេះ ផ្តល់លទ្ធភាពឲ្យគ្រូអាចរៀបចំការបង្រៀន ស្របទៅតាមតម្រូវការរបស់សិស្ស (Chmielewski, Dumont and Trautwein 2013, 926) ដោយមិនសូវបារម្ភថា ទៅចោលសិស្សដែលរៀនយឺត ឬក៏មិនបានជួយជំរុញគ្រប់គ្រាន់ដល់សិស្សដែលរៀនលឿន ។

ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស (tracking) ត្រូវគេអនុវត្តតាមទម្រង់ខុសៗគ្នា ទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍ។ ក្នុងនោះ ប្រទេសអាឡឺម៉ង់ និង ហុងគ្រី ធ្វើការបែងចែកសិស្ស តាំងពីអាយុ ១០ឆ្នាំ រីឯប្រទេសអង់គ្លេស ជប៉ុន និងសហរដ្ឋអាមេរិកវិញ ច្រើនទុកឲ្យសិស្សរៀនគ្រប់មុខវិជ្ជាទូទៅរហូតដល់ កម្រិតអនុវិទ្យាល័យ ទើបធ្វើការបែងចែកសិស្សនៅថ្នាក់វិទ្យាល័យ។ អត្ថបទនេះ ធ្វើការប្រៀបធៀបការអនុវត្តការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ក្នុងប្រទេសចំនួនបួននៅអាស៊ី រួមមាន៖ សិង្ហបុរី កូរ៉េខាងត្បូង វៀតណាម និង កម្ពុជា ដើម្បីរៀនសូត្រពីបទពិសោធន៍ផ្សេងៗ សម្រាប់យកមកកែលំអរបៀបអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស នៅកម្ពុជា។

## វិធីសាស្ត្រ

អត្ថបទនេះ ផ្អែកជាចម្បងលើឯកសារផ្សេងៗ ដូចជា របាយការណ៍ស្រាវជ្រាវដែលមានស្រាប់ និងគោលនយោបាយអប់រំរបស់ប្រទេសដែលយកមកសិក្សា។ បន្ថែមលើឯកសារសិក្សាស្រាវជ្រាវមានស្រាប់ មានព័ត៌មានផ្សេងទៀតដែលទទួលបានពីកិច្ចសន្ទនាក្រៅផ្លូវការរបស់អ្នកស្រាវជ្រាវជាមួយ គ្រូគីមីវិទ្យាម្នាក់នៅវិទ្យាល័យមួយនៅកម្ពុជា និងសហសេវិករបស់អ្នកស្រាវជ្រាវនៅ វៀតណាម និង កូរ៉េខាងត្បូង។

សិង្ហបុរី និងកូរ៉េខាងត្បូង បានទទួលជោគជ័យក្នុងការរៀបចំប្រព័ន្ធអប់រំបែបទំនើបរបស់ខ្លួន ដូច្នេះបទពិសោធន៍របស់ប្រទេសទាំងពីរ ក្នុងការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស មានអត្ថប្រយោជន៍សម្រាប់កម្ពុជា។ ទោះបីជាស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍក្តី វៀតណាមសម្រេចបានគុណភាពអប់រំ លើសពីការរំពឹងទុករបស់ពិភពលោក ដោយទទួលបានពិន្ទុមធ្យម (mean score) ៥១១ ក្នុងការចូលរួមធ្វើតេស្តលើកដំបូងនៅឆ្នាំ២០១២ ក្នុងកម្មវិធីសម្រាប់ការវាយតម្លៃសិស្សអន្តរជាតិ (PISA) ធៀបនឹង ពិន្ទុមធ្យម (average score) ៤៩៤ របស់បណ្តាប្រទេសនៃ អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD 2014) ។

## និន្នាការទូទៅក្នុងការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្សនៅក្នុងប្រទេសនីមួយៗ

### *សិង្ហបុរី*

សិង្ហបុរីបានអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស តាំងពីឆ្នាំ១៩៧៩ មក ដោយបែងចែកសិស្សតាំងពីថ្នាក់បឋមសិក្សាឡើងទៅ ឲ្យចូលក្នុងផ្នែកសិក្សាខុសៗគ្នា តាមរយៈការប្រឡង ការធ្វើតេស្ត និង របាយការណ៍ របស់សាលារៀន (Kam and Gopinathan 1999, 103)។ ដោយយល់ច្បាស់ពីភាពខុសគ្នាក្នុងការលូតលាស់ និងលទ្ធភាពទទួលបានលទ្ធផលអប់រំ គោលគំនិតក្នុងការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស លើសិស្សថ្នាក់ទី៥ និង ៦ នេះ គឺដើម្បីឲ្យសិស្សអាចប្រើសក្តានុពលរបស់ខ្លួនយ៉ាងពេញលេញ (OECD 2011)។

ការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស បច្ចុប្បន្ននេះ ត្រូវបានកែលំអទៅជាការដាក់ចូលក្រុមតាមមុខវិជ្ជា (subject-based banding)។ ការដាក់តាមមុខវិជ្ជានេះ អាចជួយឲ្យសិស្សស្វែងយល់ពីសក្តានុពល តាមរយៈចំណូលចិត្ត និង ចំណុចខ្លាំងរបស់ខ្លួន ហើយវិធីនេះក៏ផ្តល់លទ្ធភាពអាចបត់បែនបានច្រើន តាមរយៈការផ្តល់ជម្រើសដល់សិស្សក្នុងការជ្រើសរើសមុខវិជ្ជាគួបផ្សំមូលដ្ឋានគ្រឹះ និងមុខវិជ្ជាស្តង់ដា (MOEofSingapore 2016a)។ ឧទាហរណ៍ សិស្សពូកែខាងភាសា (អង់គ្លេស ចិន ម៉ាឡេ ឬតាមិល) ប៉ុន្តែខ្សោយខាងគណិតវិទ្យា និង វិទ្យាសាស្ត្រ អាចជ្រើសយកមុខវិជ្ជាភាសាពីរមករៀនតាមកម្រិតស្តង់ដា ហើយយកគណិតវិទ្យា និងវិទ្យាសាស្ត្រមករៀនតាមកម្រិតមូលដ្ឋានគ្រឹះ។ សាលារៀនជួយផ្តល់យោបល់ពីការគួបផ្សំមុខវិជ្ជា ដោយផ្អែកលើលទ្ធផលប្រឡងនៅថ្នាក់ទី៤ ហើយឪពុកម្តាយ អាចបំពេញនូវទម្រង់ឯកសារមួយ ដើម្បីបញ្ជាក់ពីមុខវិជ្ជាដែលគាត់ចង់ជ្រើសរើសឲ្យកូនរៀន។ នៅថ្នាក់ទី៥ សិស្សរៀនតាមមុខវិជ្ជាគួបផ្សំដែលឪពុកម្តាយបានជ្រើសរើស។ នៅចុងឆ្នាំថ្នាក់ទី៥នោះ សាលារៀនវាយតម្លៃលើសមត្ថភាពសិស្ស ក្នុងការរៀនតាមមុខវិជ្ជាដែលបាន

---

អត្ថបទនេះរៀបរៀងឡើងដោយ អេង សុខា អ្នកហាត់ការក្នុងផ្នែកអប់រំ នៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា Eng Sokha. 2017. “Tracking in Education: A Four Country Comparative Study.” *Cambodia Development Review* 21(2) 12-16. ភ្នំពេញ វិទ្យាស្ថាន CDRI។

ជ្រើស។ នៅថ្នាក់ទី៦ សិស្សត្រូវរៀនតាមមុខវិជ្ជាគួបផ្សំដែលសាលារៀនបានផ្តល់យោបល់ ហើយប្រឡងបញ្ចប់បឋមសិក្សាថ្នាក់ជាតិ (PSLE) (MOE of Singapore 2016a)។

នៅថ្នាក់មធ្យមសិក្សា ដោយផ្អែកតាមលទ្ធផលប្រឡង PSLE គេដាក់សិស្ស ចូលក្នុងផ្នែកសិក្សាមួយក្នុងចំណោម ផ្នែកសិក្សាទាំង ៣ គឺ ផ្នែកលឿន ផ្នែកធម្មតា (ការសិក្សាអប់រំទូទៅ) និងផ្នែកធម្មតា (បច្ចេកទេស)។ ភាពខុសគ្នារវាង ផ្នែកលឿន នឹងផ្នែកធម្មតា (សិក្សាអប់រំទូទៅ) គឺផ្នែកលឿនបង្រៀនមុខវិជ្ជាកម្រិតខ្ពស់ជាងដោយប្រើភាសាកំណើត។ សិស្សនៅក្នុងផ្នែកធម្មតា (បច្ចេកទេស) ត្រូវរៀនពីការប្រើប្រាស់កុំព្យូទ័រជាមុខវិជ្ជាចាំបាច់ព្រមទាំងភាសាអង់គ្លេស ភាសាកំណើតមួយ និងគណិតវិទ្យា (MOE of Singapore 2016b)។ ប្រព័ន្ធអប់រំថ្នាក់មធ្យមសិក្សារបស់សិង្ហបុរី ផ្តល់លទ្ធភាពបត់បែនបានច្រើន ដោយអនុញ្ញាតឲ្យសិស្សអាចផ្លាស់ប្តូរពីផ្នែកសិក្សាមួយ ទៅផ្នែកមួយផ្សេងទៀត ដោយផ្អែកតាមលទ្ធផលសិក្សា និងការវាយតម្លៃរបស់គ្រូ និងនាយកសាលា។

### *កូរ៉េខាងត្បូង*

ប្រព័ន្ធអប់រំកូរ៉េខាងត្បូង ផ្តល់នូវការសិក្សាគ្រប់មុខវិជ្ជាទូទៅរហូតដល់ថ្នាក់ទី១០ (Nuffic 2013) ដើម្បីធានាថា សិស្សទាំងអស់ទទួលបានចំណេះដឹងនិងជំនាញជាមូលដ្ឋានដែលខ្លួនត្រូវការសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ។ ចាប់ពីថ្នាក់ទី១១ ឡើងទៅ មានការបែងចែកវិទ្យាល័យជា ២ប្រភេទគឺ វិទ្យាល័យទូទៅ សម្រាប់អ្នកចង់បន្តទៅថ្នាក់ឧត្តមសិក្សា និងវិទ្យាល័យបណ្តុះបណ្តាលវិជ្ជាជីវៈ[1] សម្រាប់អ្នកចង់ចូលធ្វើការ ក្រោយពេលបញ្ចប់វិទ្យាល័យ (Kim, J-H. Lee and Y. Lee 2003, 5)។ នៅវិទ្យាល័យទូទៅ មានការបែងចែកជា ផ្នែកវិទ្យាសាស្ត្រ និងផ្នែកមនុស្សសាស្ត្រ ហើយការបែងចែកនេះ ធ្វើឡើងដោយមិនផ្អែកលើសមត្ថភាពសិស្សនោះទេ តែធ្វើឡើងទៅតាមមុខវិជ្ជា ដើម្បីត្រៀមខ្លួនសិស្សដែលចង់រៀនបន្តខាងវិទ្យាសាស្ត្រ វិស្វកម្ម ឬវិទ្យាសាស្ត្រសង្គមនៅសាកលវិទ្យាល័យ។ សិស្សនៅតាមផ្នែកសិក្សាខុសៗគ្នាក្នុងសាលាតែមួយ និងសិស្សម្នាក់ៗ ត្រូវរៀនតាមផ្នែកសិក្សាដែលបានកំណត់ជាមុនទាំងនេះដូចៗគ្នា ដោយគ្មានការផ្លាស់ប្តូរថ្នាក់រៀនទេ (Kim, J-H. Lee and Y. Lee 2003, 5)។ កូរ៉េខាងត្បូងក៏មានវិទ្យាល័យពិសេស សម្រាប់ផ្តល់កម្មវិធីសិក្សាដល់សិស្សឆ្នើមខាងវិទ្យាសាស្ត្រធម្មជាតិ និងគណិតវិទ្យា ដែរ។ ឧទាហរណ៍ សិស្សទាំងនេះអាចប្រឡងជាប់ក្នុងកម្មវិធីសិក្សារយៈពេល២ឆ្នាំនៅវិទ្យាល័យ Seoul Science ហើយបន្តការសិក្សានៅតាមសាកលវិទ្យាល័យ ឬវិទ្យាស្ថានល្បីៗបាន (Choi and D-S.Hon 2009, 45)។[2]

កម្មវិធីសិក្សា អនុញ្ញាតឲ្យសិស្សជ្រើសរើសផ្នែកសិក្សាបាននៅថ្នាក់ទី១១។ សិស្សដែលជ្រើសយកផ្នែកមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម អាចជ្រើសយកមុខវិជ្ជា ដូចជា ភាសាកូរ៉េ ការអប់រំសីលធម៌ និងការសិក្សាសង្គម ហើយសម្រាប់សិស្សខាងផ្នែកវិទ្យាសាស្ត្រ អាចជ្រើសរៀនមុខវិជ្ជា ដូចជា គណិតវិទ្យា វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា។ ម៉្យាងទៀត សិស្សគ្រប់គ្នាត្រូវរៀនចប់មុខវិជ្ជាស្នូលចាំបាច់មួយចំនួន (MOEST Korea 2008) ។ ដូច្នេះ ការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស នៅកូរ៉េខាងត្បូង អនុញ្ញាតឲ្យមានភាពលាយចម្រុះគ្នាមួយកម្រិតនៅក្នុងថ្នាក់រៀន និងការផ្ទេរ ឬការចែករំលែកចំណេះដឹងរវាងសិស្សនានា។ ទោះយ៉ាងណា ការផ្លាស់ប្តូរគំនិត ឬការចែករំលែក/ផ្ទេរចំណេះដឹង អាចកើតមានតែក្នុងថ្នាក់រៀនមុខវិជ្ជាចាំបាច់ ដូចជាភាសាបរទេស ជាដើម និងក្នុងមុខវិជ្ជាកម្រិតខ្ពស់ៗនៅតាមផ្នែកសិក្សានីមួយៗ។ ឧទាហរណ៍ សិស្សដែលបានជ្រើសយកផ្នែកសិក្សាសង្គម គឺមានឱកាសតិចតួចណាស់ក្នុងការរៀនមុខវិជ្ជាវិទ្យាសាស្ត្រខ្ពស់ៗ។

### *វៀតណាម*

វៀតណាមផ្តល់កម្មវិធីអប់រំ ដែលកំណត់ឲ្យសិស្សរៀនគ្រប់មុខវិជ្ជាទូទៅដល់ថ្នាក់ទី៩ (UNESCO 2007) ហើយវៀតណាមបានដាក់អនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ជាលើកដំបូងនៅឆ្នាំសិក្សា២០០៦/២០០៧ ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។ ដើម្បីផ្តល់ជម្រើសឲ្យបានកាន់តែធំទូលាយ កម្មវិធីសិក្សាត្រូវបានចែកចេញជា ៣ ផ្នែករួមមាន វិទ្យាសាស្ត្រពិត បច្ចេកវិទ្យា និងវិទ្យាសាស្ត្រសង្គមនិងភាសាបរទេស។ នាយក ឬក្រុមប្រឹក្សាសាលារៀន អាចសម្រេចចិត្តថា សាលារៀនគួរផ្តល់ការសិក្សាប៉ុន្មានផ្នែក និងគួរជ្រើសយកផ្នែកណាខ្លះ បន្ទាប់ពីទទួលបានការយល់ព្រមពី មន្ទីរអប់រំ និងបណ្តុះបណ្តាលថ្នាក់ខេត្ត (Fredriksen and Peng 2008)។ លក្ខខណ្ឌលើផ្នែកសិក្សាទាំង ៣ នេះ គឺតម្រូវឲ្យសិស្សមានស្តង់ដានៃចំណេះដឹង ឬជំនាញសម្រាប់មុខវិជ្ជាក្នុងកម្មវិធីសិក្សាទាំងអស់។ ឧទាហរណ៍ ដើម្បីរៀនខាងវិទ្យាសាស្ត្រធម្មជាតិ សិស្សត្រូវសម្រេចបានពិន្ទុ កម្រិតខ្ពស់ខាងរូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និង គណិតវិទ្យា នៅពេលប្រឡងចូល។ សិស្សក្នុងផ្នែកសិក្សានីមួយៗ ត្រូវរៀនដូចគ្នានូវមុខវិជ្ជាកាតព្វកិច្ច (ឧទាហរណ៍ សិល្បៈ ការអប់រំពលរដ្ឋ ភាសាបរទេស ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ អក្សរសាស្ត្រ គណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកវិទ្យា កីឡា និងការអប់រំយោធា) ដោយមានពេល ៦ម៉ោងក្នុងមួយសប្តាហ៍ សម្រាប់រៀនមុខវិជ្ជាដែលខ្លួនបានជ្រើសរើស (WES 2012)។

### *កម្ពុជា*

សាលារៀននៅកម្ពុជា អនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ចាប់ពីថ្នាក់ទី១១ ដោយមានផ្តល់ ២ផ្នែកសិក្សា គឺមាន វិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម។ ប្រព័ន្ធនៃ

1 ក្នុងអត្ថបទនេះ វិទ្យាល័យបណ្តុះបណ្តាលវិជ្ជាជីវៈ មិនមានលើកយកមកពិភាក្សាទេ។

2 វិទ្យាល័យពិសេស ទាំងរដ្ឋ និងឯកជន មានស្វ័យភាពជ្រើសរើសសិស្ស រចនារៀបចំកម្មវិធីសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យក្នុងការចូលរៀន។

ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្សបានអនុវត្តឡើង ដើម្បីផ្តល់ឱកាសឲ្យសិស្ស ពង្រឹងពង្រីកចំណាប់អារម្មណ៍ និង រៀបចំកម្មវិធីសិក្សារបស់ខ្លួន ដោយអាចជ្រើសយកបានដល់ ៤ មុខវិជ្ជា នៅក្នុងផ្នែកសិក្សាទាំង ២ នេះ (MOEYS 2004)។ ខាងផ្នែកវិទ្យាសាស្ត្រមានបង្រៀន គឺមីវិទ្យា រូបវិទ្យា ជីវវិទ្យា ផែនដីវិទ្យា និងការសិក្សាពីបរិស្ថាន ហើយខាងផ្នែកសិក្សាសង្គម មានបង្រៀន ក្រមសីលធម៌ ពលរដ្ឋវិទ្យា ប្រវត្តិវិទ្យា សេដ្ឋកិច្ច និងភូមិវិទ្យា។ សិស្សទាំងអស់ត្រូវសិក្សាមុខវិជ្ជាកាតព្វកិច្ចចំនួន ៤ គឺអក្សរសាស្ត្រខ្មែរ ភាសាបរទេស (អង់គ្លេសឬបារាំង) គណិតវិទ្យាជាមូលដ្ឋាន (៤ ម៉ោង/សប្តាហ៍) ឬគណិតវិទ្យាកម្រិតខ្ពស់ (៨ ម៉ោង/សប្តាហ៍) ហើយនិង ការអប់រំកាយនិងសុខភាព និងកីឡា។

ដូចនៅកូរ៉េខាងត្បូង និងវៀតណាមដែរ កម្ពុជាបានអនុញ្ញាតឲ្យសាលារៀនអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ដូច្នេះសិស្សអាចរៀនថ្នាក់ខុសៗគ្នា ទៅតាមសមត្ថភាព និងមុខវិជ្ជាបានជ្រើសយក។ សិង្ហបុរី និង វៀតណាម បែងចែកសិស្សទៅតាមសមត្ថភាព លទ្ធផលប្រឡង និងពិន្ទុតាមមុខវិជ្ជា រីឯកម្ពុជា គឺដូចគ្នានឹងកូរ៉េខាងត្បូងដែរ បែងចែកជាសំខាន់ទៅតាមចំណាប់អារម្មណ៍របស់សិស្ស។

## ការពិភាក្សា និងការអនុវត្ត

សិង្ហបុរីជាប្រទេសនាំមុខគេមួយក្នុងវិស័យអប់រំ ហើយស្ថិតនៅលំដាប់កំពូលៗ នៅក្នុងចំណាត់ថ្នាក់ការអប់រំសំខាន់ៗក្នុងពិភពលោក។ តាមការវាយតម្លៃលើសមត្ថភាពដោះស្រាយបញ្ហាក្នុងឆ្នាំ២០១២ របស់ PISA សិស្សសិង្ហបុរី បានលទ្ធផលល្អជាពិសេស ក្នុងការទាញយកចំណេះដឹង និងការធ្វើការរួមគ្នានិងទំនាក់ទំនងក្នុងក្រុម (OECD 2014)។ ជោគជ័យប្រកបដោយចីរភាពរបស់ប្រទេសនេះ អាចបណ្តាលមកពីកត្តាជាច្រើន ដូចជាការបន្សីគ្នាយ៉ាងល្អរវាងគោលនយោបាយ នឹងការអនុវត្ត ការជ្រើសរើសគ្រូបង្រៀន និងនាយកសាលាមានគុណភាពខ្ពស់ និងការផ្តោតលើការអភិវឌ្ឍវិជ្ជាជីវៈ និងការបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីឲ្យមានការកែលំអគុណភាពជាប្រចាំ។ ម៉្យាងទៀត ការចាប់បង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រកម្រិតមូលដ្ឋាន តាំងពីថ្នាក់បឋមសិក្សា បានផ្តល់ឲ្យកុមារនូវគ្រឹះដ៏រឹងមាំ សម្រាប់ការទទួលបានជោគជ័យនៅក្នុងសាលារៀន (OECD 2011)។

គួរកត់សំគាល់ថា ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ក្នុងប្រព័ន្ធអប់រំនៅសិង្ហបុរី ដែលអនុញ្ញាតឲ្យសិស្សជ្រើសយកផ្នែកសិក្សាខុសៗគ្នានោះ បានជួយកាត់បន្ថយអត្រាបោះបង់ការសិក្សា កែលំអគុណភាពអប់រំ និងកសាងជំនាញមួយចំនួន ដែលមានតម្រូវការចាំបាច់នៅក្នុងសេដ្ឋកិច្ចប្រើមូលធន និងជំនាញច្រើន (OECD 2016)។ ទោះបី ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស អនុញ្ញាតឲ្យសាលារៀនបង្កើតកម្មវិធីសិក្សាដើម្បីបំពេញតាមតម្រូវការ និងចំណាប់អារម្មណ៍របស់សិស្សក្តី ពីដំបូងមានការរិះគន់ថា អាចមាន "ឥទ្ធិពលអាក្រក់ទៅលើសន្ទុះចិត្ត និងការដឹងស្គាល់ពីខ្លួនឯងរបស់សិស្ស ដែលផុសចេញពីដំណើរការបែងចែកមុខវិជ្ជាសិក្សា" (Kam and Gopinathan 1999, 113)។ សរុបមក ក្នុងការរៀនសូត្រពីប្រព័ន្ធអប់រំនៅសិង្ហបុរី គេត្រូវគិតដល់ឧត្តមភាពរបស់ប្រទេសនេះ ក្នុងលក្ខណៈជាទីក្រុងមួយដ៏តូច ដែលមានរដ្ឋាភិបាលមួយយ៉ាងធំ បណ្តាញសង្គមរឹងមាំ និងអារម្មណ៍ជាផ្នែកមួយនៃសហគមន៍។

កំណើនវិនិយោគនៃរដ្ឋាភិបាលក្នុងការអប់រំ និងការប្រើប្រាស់ជំនួយបរទេសដ៏មានប្រសិទ្ធភាព ដែលជាដំបូងផ្តោតលើការអប់រំកម្រិតបឋមសិក្សាជាសាកល និងបន្ទាប់មកលើមធ្យមសិក្សា ដើម្បីបំពេញតាមតម្រូវការទីផ្សារពលកម្មនោះ បានអនុញ្ញាតឲ្យកូរ៉េខាងត្បូង អាចពង្រឹងជាបណ្តើរៗនូវគុណភាពរបស់គ្រូបង្រៀន ការបង្រៀន និងសាលារៀន។ ក្នុងឆ្នាំ១៩៥៤ រដ្ឋាភិបាលបានចំណាយ ៤,២% នៃថវិកាសរុបរបស់ខ្លួន ទៅលើវិស័យអប់រំ ហើយអត្រានេះឡើងដល់ ១៥,២% ក្នុងឆ្នាំ១៩៦០។ កូរ៉េខាងត្បូងក៏បានបង្កើតមូលនិធិពិសេសមួយ និងបែងចែកចំណូលពន្ធថែមទៀត សម្រាប់ជួយទ្រទ្រង់ដល់ការអភិវឌ្ឍកម្មវិធីសិក្សា នៅក្នុងទសវត្ស៍១៩៨០ និងទសវត្ស៍១៩៩០។ ម៉្យាងទៀត ក្នុងអំឡុងឆ្នាំ១៩៦០ ដល់ ១៩៩០ រដ្ឋាភិបាលបានបែងចែកថវិកាចំនួន ១២,៥% នៃជំនួយអភិវឌ្ឍន៍ ទៅឲ្យវិស័យអប់រំ (Kim et al, 2015) (រូបភាព១)។ ក្រៅពីវិនិយោគជាហិរញ្ញវត្ថុ ផ្នត់គំនិតដែលយល់ឃើញថា វិស័យអប់រំជាឧបករណ៍សម្រាប់ជំរុញឲ្យសង្គមអភិវឌ្ឍ គឺជាកត្តាធំមួយនៃជោគជ័យក្នុងវិស័យអប់រំរបស់កូរ៉េខាងត្បូង (Sorensen 1994, 28)។

រូបភាព១: ចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ
គិតជាភាគរយនៃ ផសស ឆ្នាំ២០០០-១២




ចំណាំ: ទិន្នន័យលើប្រទេសកម្ពុជាអាចរកបានតែសម្រាប់ឆ្នាំ២០០០ ដល់ ២០១០
ប្រភព: TheGlobalEconomy.com;
UNESCO www.theglobaleconomy.com/compare-countries/

កម្មវិធីអប់រំថ្នាក់ជាតិរបស់កូរ៉េខាងត្បូង ត្រូវបានរចនារៀបចំឡើង ដើម្បីផ្តល់ចំណេះដឹងគ្រប់មុខវិជ្ជាទូទៅ រហូតដល់ថ្នាក់ទី១០ ដោយអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ចាប់ពីថ្នាក់ទី១១ ឡើងទៅ។ បើគិតពីលក្ខណៈស្មើភាពវិញ ការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ហាក់ដូច

បានផ្តល់សេរីភាពឲ្យសិស្សក្នុងការជ្រើសរើសផ្នែកសិក្សា រវាងវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រធម្មជាតិ។ ប៉ុន្តែ ការដាក់បញ្ចូលសិស្សទៅក្នុងផ្នែកសិក្សាខុសៗគ្នា ដោយផ្អែកលើចំណាប់អារម្មណ៍ជាជាងលើសមត្ថភាព អាចមិនបានផ្តល់នូវភាពដូចគ្នាដ៏ល្អមួយ ដែលជួយឲ្យគ្រូអាចរចនារៀបចំការបង្រៀន បានកាន់តែប្រសើរ ព្រោះ ឧទាហរណ៍ សិស្សខ្សោយខាងវិទ្យាសាស្ត្រ អាចជ្រើសរើសរៀនមុខវិជ្ជាខាងវិទ្យាសាស្ត្រ។

ទោះបីមិនមានឯកសារបញ្ជាក់គ្រប់គ្រាន់ក្តី តែក៏អាចមើលឃើញដែរថា ការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស នៅវៀតណាម មានលក្ខណៈជាប្រព័ន្ធ។ គេដាក់បញ្ចូលសិស្សទៅក្នុងផ្នែកសិក្សាផ្សេងៗ ដោយផ្អែកលើលទ្ធផលប្រឡង ឬចំណេះដឹងតាមមុខវិជ្ជា ហើយសាលារៀនមានស្វ័យភាពក្នុងការរចនារៀបចំ ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ដើម្បីបំពេញតាមតម្រូវការរបស់សិស្ស។ ការវិភាគលើលទ្ធផលដែលវៀតណាមសម្រេចបាន ក្នុងគុណភាពការអប់រំបង្ហាញនូវកត្តាជោគជ័យដ៏សំខាន់ពីរ។ ទី១ វៀតណាមមានការប្តេជ្ញាចិត្តអស់ជាច្រើនទសវត្សរ៍មកហើយ ក្នុងការធ្វើវិនិយោគលើវិស័យអប់រំ ដើម្បីដោះស្រាយបញ្ហាអនក្ខរកម្ម បង្កើនអត្រាចុះឈ្មោះចូលរៀន និងកំណត់ស្តង់ដាអប្បបរមាសម្រាប់ការអប់រំទូទាំងប្រទេស។ ទី២ គ្រូបង្រៀនវៀតណាមមានគុណសម្បត្តិល្អ ហើយវត្តមានរបស់សិស្សក៏មានកម្រិតខ្ពស់ (Bodewig 2013)។

ដូចនៅកូរ៉េខាងត្បូងដែរ ការអនុវត្តការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្សនៅកម្ពុជា ផ្តល់សេរីភាពឲ្យសិស្សក្នុងការរៀបចំកម្មវិធីសិក្សា និងពង្រឹងពង្រីកចំណាប់អារម្មណ៍របស់ខ្លួន ដោយមានផ្តល់នូវផ្នែកសិក្សាផ្សេងៗសម្រាប់ឲ្យជ្រើសរើស។ វិធីនេះបានសម្រាលបន្ទុកនៃការរៀនមុខវិជ្ជាច្រើនពេក ក្នុងនោះមានមុខវិជ្ជាខ្លះ សិស្សមិនសូវចាប់អារម្មណ៍ទេ នៅឆ្នាំបញ្ចប់ថ្នាក់វិទ្យាល័យ។ សិស្សក៏អាចផ្តោតបានកាន់តែច្រើនថែមទៀត ទៅលើមុខវិជ្ជាជាជំនាញឯកទេសរបស់ខ្លួន។ ជាចំណុចអវិជ្ជមានវិញ កម្ពុជានៅតែខ្វះយន្តការសម្រាប់អនុវត្ត ប្រព័ន្ធនៃការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស របស់ខ្លួន។ ការធានាឲ្យមានធនធានគ្រប់គ្រាន់ និងគ្រូបង្រៀនសមស្របល្អតាមមុខវិជ្ជា នៅតែជាបញ្ហាសំខាន់នៅថ្នាក់មធ្យមសិក្សា ជាពិសេសសម្រាប់មុខវិជ្ជាជំនាញវិជ្ជាជីវៈ ដែលនៅឆ្នាំ១៩៩៩ មានអត្រាសមស្របល្អកម្រិតទាបបំផុតត្រឹម ៥ ទៅ ២០%។ ផ្ទុយទៅវិញ មុខវិជ្ជាស្នូល ដូចជាគណិតវិទ្យា ភាសាខ្មែរ និងវិទ្យាសាស្ត្រ មានអត្រាសមស្របល្អពី ៨៥ ទៅ ៩៥% (UNESCO-IBE 2011)។

ភស្តុតាងពីប្រទេសមួយទៅប្រទេសមួយបង្ហាញថា គោលនយោបាយបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស គួរផ្តល់សារៈសំខាន់ ដល់ការបង្កើនចំណាប់អារម្មណ៍ និងទំនុកចិត្តរបស់សិស្ស ក្នុងមុខវិជ្ជាណាមួយ ព្រមទាំងការវាយតម្លៃជាញឹកញាប់លើការរីកចម្រើន និងចំណេះដឹងរបស់សិស្សក្នុងមុខវិជ្ជានោះ។ ដើម្បីកំណត់ថា ការវាយតម្លៃគួរញឹកញាប់ប៉ុណ្ណា និងអ្នកណាគួរធ្វើការបែងចែកសិស្សទៅតាមផ្នែកសិក្សាផ្សេងៗ គេត្រូវគិតគូរជាសំខាន់ថាតើគោលនយោបាយបែងចែកតាមសមត្ថភាពឬចំណូលចិត្តសិស្ស គួរមានលក្ខណៈយ៉ាងណា និង តើគួរចាប់ផ្តើមអនុវត្តពីថ្នាក់បឋមសិក្សា អនុវិទ្យាល័យ ឬវិទ្យាល័យ។ ឧទាហរណ៍ ដោយសារសិង្ហបុរីអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស តាំងពីបឋមសិក្សា (ថ្នាក់ទី៥) ដូច្នេះ ការចូលរួមពីឪពុកម្តាយសំខាន់ណាស់ ក្នុងការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសមស្របបំផុតទៅនឹងសមត្ថភាព និងទេពកោសល្យរបស់កុមារបន្ថែមទៅលើការវាយតម្លៃរបស់សាលារៀន។ ម្យ៉ាងទៀត ប្រសិនបើ ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ចាប់ផ្តើមនៅអនុវិទ្យាល័យ គឺអាចមិនចាំបាច់មានការចូលរួមពីឪពុកម្តាយទេ ប៉ុន្តែត្រូវមានការវាយតម្លៃលើសមត្ថភាពសិស្ស និងការជួយណែនាំដល់សិស្សក្នុងការជ្រើសរើសមុខវិជ្ជាដែលគួររៀន។

នៅកម្ពុជា បញ្ហាសំខាន់គឺ មិនត្រូវធ្វើឲ្យប៉ះពាល់ដល់សន្ទុះចិត្តរបស់សិស្ស ក្នុងការជ្រើសយកផ្នែកសិក្សាណាមួយនោះទេ។ ឧទាហរណ៍ សិស្សអាចជ្រើសរើសយកការសិក្សាផ្នែកវិទ្យាសាស្ត្រ ព្រោះគិតថា អាចបានពិន្ទុខ្ពស់ក្នុងពេលប្រឡងទូទាំងប្រទេស។ ជាការសមហេតុផលដែលគួរគិតថា ដើម្បីអាចសម្រេចចិត្តជ្រើសរើសប្រកបដោយទំនួលខុសត្រូវ និងទទួលបានព័ត៌មានគ្រប់គ្រាន់លើមុខវិជ្ជាដែលគួររៀន សំដៅពង្រឹងសមត្ថភាពរបស់ខ្លួន សិស្សត្រូវមានព័ត៌មាន និងការណែនាំពីអ្នកមានចំណេះដឹង។ ជាងនេះទៀត គ្រូបង្រៀនក៏ត្រូវចេះបកស្រាយយ៉ាងត្រឹមត្រូវពីចំណេះដឹង និងសមត្ថភាពរបស់សិស្សម្នាក់ៗ ដើម្បីអាចវាយតម្លៃពីសមត្ថភាព និងសក្តានុពលរបស់សិស្ស និងជួយណែនាំសិស្សក្នុងការជ្រើសរើសមុខវិជ្ជាឲ្យបានត្រឹមត្រូវ។

កម្ពុជា គួរវាយតម្លៃលើផ្នែកសិក្សានីមួយៗ ដើម្បីវាស់វែងប្រសិទ្ធភាពក្នុងការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស និងស្វែងរកមធ្យោបាយពង្រឹងគុណភាពការអប់រំជាទូទៅ។ ម្យ៉ាងទៀត គួរមានការពិនិត្យវិភាគលើបទពិសោធន៍របស់ប្រទេសឯទៀត ក្នុងការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស និងកសាងកម្មវិធីសិក្សា ដើម្បីកំណត់កម្រិតគោលនៃគុណភាពអប់រំ និងអាចកែសម្រួលរបៀបអនុវត្តរបស់បរទេស ឲ្យវាសមស្របទៅតាមបរិបទ និងវប្បធម៌របស់កម្ពុជា។ ប្រព័ន្ធអប់រំនៅកម្ពុជា ក៏គួរគិតគូរលើកស្ទួយឲ្យមានសាលារៀនសម្រាប់អ្នកពូកែ ដើម្បីឲ្យសិស្សដែលមានទេព្យកោសល្យ និងសមត្ថភាពល្អខាងវិទ្យាសាស្ត្រ អាចប្រើសក្តានុពលរបស់ខ្លួនបានច្រើនជាអតិបរមា។

សំខាន់បំផុតត្រូវមានការស្រាវជ្រាវថែមទៀត ដើម្បីពិនិត្យពីការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស នៅតាមវិទ្យាល័យនៅកម្ពុជា ដើម្បីកសាងគោលនយោបាយអប់រំឲ្យបានត្រឹមត្រូវ និងពង្រឹងគុណភាពអប់រំ។ ឧទាហរណ៍ ការសិក្សាសាកល្បងសម្រាប់ត្រួតពិនិត្យដោយចៃដន្យ អាចមានប្រយោជន៍សម្រាប់វាយតម្លៃពីប្រសិទ្ធភាពនៃ ការអនុវត្ត ការបែងចែកតាម

សមត្ថភាព ឬចំណូលចិត្តសិស្ស។ ការសិក្សាបន្ថែមគួរពិនិត្យជាសំខាន់លើ ស្វ័យភាពនៃសាលារៀន តួនាទីរបស់នាយកសាលា និងគ្រូបង្រៀន និង ឥទ្ធិពលនៃកត្តាទាំងនេះ ទៅលើគុណភាពការអប់រំដែលប្រើប្រព័ន្ធ ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស។

## ឯកសារយោង


Bodewing, Christian. 2013. "What Explains Vietnam's Stunning Performance in PISA 2012?" http://blogs.worldbank.org/eastasiapacific/what-explains-vietnam-s-stunning-performance-pisa-2012.

Chmielewski, Anna K., Hanna Dumont and Ulrich Trautwein. 2013. "Tracking Effects Depend on Tracking Type: An International Comparison of Students' Mathematics Self-Concept." *American Educational Research Journal* 50(5): 925-957.

Choi, Kyong Mi, and Dea Sik Hon.2009. "Gifted Education in Korea: Thee Korean High Schools for the Mathematically Gifted." *Spring* 32(2): 42-49.

Fredriksen, Birger, and Tan Jee Peng. 2008. "An African Exploration of the East Asian Education Experience." Washington, DC: World Bank.

Hanushek, Eric A., and Ludger Woessmann. 2006. "Does Educational Tracking Affect Performance and Inequality? Differences-in-Differences Evidence across Countries." *The Economic Journal* 116: 63-76.

Kam, Ho W., and S. Gopinathan. 1999. "Recent Developments in Education in Singapore." *School Effectiveness and School Improvement* 10(1): 99-117.

Kim, Jinhee, Woojin Cho, Mugyeong Moon, Hyeyoung Park, Ji Min Cho, Ju-Hyoung Park, Yunjeong Choi and Jieun Song. 2015. *Education for All 2015 National Review Report*: *Republic of Korea.* http://unesdoc.unesco.org/images/0022/002297/229721E.pdf.

Kim, Taejong, Ju-Ho Lee and Young Lee. 2003. *Mixing versus Sorting in Schooling: Evidence from the Equalization Policy in South Korea.* KDI School Working Paper Series 03-07. doi.org/10.2139/ssrn.482962.

Ministry of Education, Singapore. 2016a. "Subject-based Banding: Catering to Your Child's Abilities." www.moe.gov.sg/education/primary/subject-based-banding.

Ministry of Education, Singapore. 2016b. "Secondary School Courses." 2015. www.moe.gov. sg/education/secondary/secondary-school-courses.

MOEST (Ministry of Education, Science and Technology), Korea. 2008. "The School Curriculum of The Republic of Korea." http://gangwonepik.weebly.com/uploads/1/3/8/5/ 13851570/national_school_curriculum-english2008.pdf.

MOEYS (Ministry of Education Youth and Sport), Cambodia. 2004. *Policy for Curriculum Development 2005-2009*. www.moeys.gov.kh/en/press-releases/policy-for-curriculum-development-2005-2009.html#.WEdvWrJ96Uk.

Nuffic (Netherlands Organisation for International Cooperation in Higher Education). 2013. "Country Model – South Korea." Country module: Evaluation of foreign degrees and qualification in the Netherlands. www.epnuffic.nl/en/publications/find-a-publication/ education-system-south-korea.pdf.

OECD (Organisation for Economic Co-operation and Development). 2011. *Lessons from PISA for the United States, Strong Performers and Successful Reformer in Education*. Paris: OECD Publishing. dx.doi.org/10.1787/9789264096660-en.

OECD. 2014. "Singapore." In *PISA 2012 Results: Creative Problem Solving (Volume V)*: *Students' Skills in Tacking Real-Life Problems*. Paris: OECD Publishing. dx.doi.org/10. 1787/9789264208070-16-en.

OECD. 2014. "PISA 2012: Results in Focus." www.oecd.org/pisa/keyfindings/pisa-2012-results-overview.pdf.

OECD. 2016. "PISA High Performers: Singapore." Country Note. www.oecd.org/pisa/PISA-2015-singapore.pdf.

Sorensen, Clark W. 1994. "Success and Education in South Korea." *Comparative Education Review* 38(1): 10-35.

UNESCO. 2007. *Secondary Education Regional Information Base: Country Profile – Viet Nam.* Bangkok: UNESCO. www.uis.unesco.org/Library/Documents/Viet%20Nam.pdf.

UNESCO-IBE. 2011. "World Data on Education." 7th edition, 2010/11. www.ibe.unesco.org/ fileadmin/user_upload/Publications/WDE/2010/pdf-versions/Cambodia.pdf.

WES (World Education Services). 2012. "Secondary Education in Vietnam." http://wenr.wes. org/2012/04/secondary-education-in-vietnam.



## Cambodia Development Review—2017 Subscription Rates

**Domestic subscription (individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........................................................................

**Domestic subscription (discount price for bulk orders—five copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........................................................................

**International subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒ Other ..........................................................................

First name: .................................................... Last name: ........................................................ Position: .........................................................

Organisation / Company: ..........................................................................

Address (CCC Box if applicable): ..........................................................................

City / Province: ........................................................................ Country: ..........................................................................

Telephone: ........................................................................ Fax: ..........................................................................

e-mail: ........................................................................ ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Unit at CDRI if your contact details change.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាពីសូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី១ ឆ្នាំ២០១៧។

នៅត្រីមាសទី១ ឆ្នាំ២០១៧ ផសស ពិត នៅឥណ្ឌូនេស៊ីមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៥,០% ឬ ០,១ ឯកតាភាគរយ ខ្ពស់ជាងកាលពីត្រីមាសមុន ខណៈដែលចំណាយរបស់រដ្ឋាភិបាល និងការនាំចេញ កើនឡើង។ កំណើន ផសស នៅម៉ាឡេស៊ីឡើងដល់ ៥,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ដែលជាកំណើនខ្ពស់បំផុតគិតតាំងពីឆ្នាំ២០១៥ មក ដោយសារតម្រូវការក្នុងស្រុកមានកំណើនខ្លាំង ហើយបានជួយប៉ះប៉ូវដល់ការថយចុះតម្រូវការពីក្រៅប្រទេស។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅសិង្ហបុរីមានត្រឹម ២,៧% ឬ ០,២ ឯកតាភាគរយ ទាបជាងកាលពីត្រីមាសមុន រីឯវិស័យកម្មន្តសាល និង សេវាកម្ម បានថយល្បឿន ធៀបនឹងសន្ទុះកំណើនក្នុងត្រីមាសមុន។ សេដ្ឋកិច្ចថៃមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៣,៣% ឬ ០,៣ ឯកតាភាគរយ ខ្ពស់ជាងកាលពីត្រីមាសមុន ដោយសារ ចំណាយក្នុងគ្រួសារមានលក្ខណៈខ្លាំងក្លា តម្រូវការប្រើប្រាស់មានកម្រិតខ្ពស់ ហើយ ចំណូលនៅតាមជនបទកើនឡើង។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅវៀតណាម មានត្រឹម ៥,១% ឬ ១,៦ ឯកតាភាគរយ ទាបជាងកាលពីត្រីមាសមុន។

សេដ្ឋកិច្ចប្រទេសចិន មានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៦,៩% ដែលជំរុញឡើងដោយសារ ចំណាយរបស់រដ្ឋាភិបាល លើហេដ្ឋារចនាសម្ព័ន្ធ និង ទីផ្សារផ្ទះសម្បែងមានសកម្មភាពខ្លាំង។ សេដ្ឋកិច្ចក្នុងតំបន់រដ្ឋបាលពិសេសក្រុងហុងកុងនៃ ប្រទេសចិន មានកំណើន ៤,៣% ធៀបនឹងកាលពីមួយឆ្នាំមុន ដែលជាកំណើនខ្ពស់បំផុតគិតតាំងពីឆ្នាំ២០១២ មក។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅកូរ៉េខាងត្បូងមានដល់២,៨%ឬ០,៥ឯកតាភាគរយខ្ពស់ជាងកាលពីត្រីមាសមុន ហើយជំរុញឡើងដោយសារវិស័យក្រៅប្រទេស និង វិនិយោគជាប់លាប់។ ផសស នៅតៃវ៉ាន់ កើន ២,៦% ធៀបមួយឆ្នាំមុន ឬ ០,៣ ឯកតាភាគរយ ទាបជាងកាលពីត្រីមាសមុន។

កំណើនផសសពិតពីមួយឆ្នាំទៅមួយឆ្នាំក្នុងតំបន់អឺរ៉ូមានកម្រិត ១,៧% គឺស្មើគ្នានឹងត្រីមាសមុន។ សេដ្ឋកិច្ចជប៉ុនមានកំណើន ១,៦% គឺដូចគ្នានឹងត្រីមាសមុន ព្រោះ ចំណាយប្រើប្រាស់ឯកជន និង វិស័យក្រៅប្រទេសកើនល្បឿន ដោយសារ ប្រាក់យេនចុះថ្លៃ ហើយ តម្រូវការក្នុងពិភពលោកមានលក្ខណៈខ្លាំងក្លា។ សហរដ្ឋអាមេរិកមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ២,១% ឬ ០,២% ឯកតាភាគរយ ខ្ពស់ជាងត្រីមាសមុន ហើយ ចំណាយប្រើប្រាស់ និងវិនិយោគជាប់លាប់មិនមែនលំនៅដ្ឋាន កើនឡើងខ្លាំងជាងការរំពឹងទុក។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

បណ្ដាប្រទេសដៃគូពាណិជ្ជកម្ម ដែលបានជ្រើសរើសទាំងអស់មានអតិផរណា: អតិផរណាមានកម្រិត ៤,២% នៅកម្ពុជា ៣,៦% នៅឥណ្ឌូនេស៊ី ៤,៣% នៅម៉ាឡេស៊ី ០,៧% នៅសិង្ហបុរី ១,១% នៅថៃ និង ៥,០% នៅវៀតណាម។ វាមានកម្រិត ១,៤% នៅចិន ១,០% នៅហុងកុង ២,០% នៅកូរ៉េខាងត្បូង និង ០,៨% នៅតៃវ៉ាន់។ អតិផរណាមាន ដល់ ១,៨% នៅតំបន់អឺរ៉ូ ០,២% នៅជប៉ុន និង ២,៥% នៅសហរដ្ឋអាមេរិក។

នៅត្រីមាសទី១ឆ្នាំ២០១៧ប្រាក់រៀលប្ដូរបាន៤០១៥,៨រៀល/ដុល្លារ។ ប្រាក់បាតថៃ ឡើងថ្លៃ ០,៨% ធៀបនឹងត្រីមាសមុន ដល់ ៣៥,១បាត/ដុល្លារ ហើយប្រាក់ដុងវៀតណាម ឡើងថ្លៃ ០,៣% ដល់២២៤២៩,១ដុង/ដុល្លារ។ធៀបនឹងត្រីមាសមុនប្រាក់យ៉ន់ចិនចុះថ្លៃ ០,៨% ដល់ ៦,៩យ៉ន់/ដុល្លារ ហើយ ប្រាក់យេនជប៉ុនចុះថ្លៃ ៣,៨% ដល់ ១១៣,៧យេន/ដុល្លារ។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០១៧ ទំនិញសំខាន់ៗនៅលើទីផ្សារពិភពលោក បានឡើងថ្លៃ ធៀបនឹងត្រីមាសមុន។ ពោត ឡើងថ្លៃ ៥,៥% ដល់ ១៦០,៦ដុល្លារ/តោន, ប្រេងដូងប្រេង ឡើងថ្លៃ ២,៧% ដល់ ៧៧៣,០ដុល្លារ/តោន, កៅស៊ូ ឡើងថ្លៃ ២៥,១% ដល់ ២.១៤៧,៧ដុល្លារ/តោន, អង្ករ ឡើងថ្លៃ ៤២,៨% ដល់ ៥៣៧.០ដុល្លារ/តោន, ហើយ សណ្ដែកសៀង ឡើងថ្លៃ ១,៨% ដល់ ៤១៩,១ដុល្លារ/តោន ។ ប្រេងឆៅឡើងថ្លៃ ៩,៣% ដល់ ៥២,០ដុល្លារ/ធុង, សាំងឡើងថ្លៃ ៦,៦% ដល់ ០,៤១០ដុល្លារ/លីត្រ ហើយម៉ាសូតឡើងថ្លៃ ៣,០% ដល់ ០,៤១៤ដុល្លារ/លីត្រ។

---

អត្ថបទនេះ រៀបរាងដោយលោក វ៉ែន សីហា ជាអ្នកស្រាវជ្រាវ និង លោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៩-២០១៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 0.1 | 6.0 | 7.1 | 7.3 | 7.4 | 7.1 | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 4.2 | 6.2 | 6.5 | 6.3 | 5.8 | 5.2 | 4.8 | 4.9 | 5.2 | 5.0 | 4.9 | 5.0 |
| ម៉ាឡេស៊ី | -2.4 | 9.0 | 4.9 | 5.4 | 4.6 | 6.0 | 4.9 | 4.2 | 4.0 | 4.3 | 4.5 | 5.6 |
| សិង្ហបុរី | -4.5 | 14.7 | 4.7 | 1.3 | 3.8 | 3.0 | 2.0 | 1.8 | 2.1 | 1.1 | 2.9 | 2.7 |
| ថៃ | 3.3 | 7.9 | 0.0 | 6.7 | 2.8 | 1.6 | 2.8 | 3.2 | 3.5 | 3.2 | 3.0 | 3.3 |
| វៀតណាម | 5.4 | 6.4 | 6.2 | 5.2 | 5.4 | 5.9 | 6.6 | 5.5 | 3.5 | 6.4 | 6.7 | 5.1 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 8.2 | 10.4 | 9.3 | 7.7 | 7.7 | 7.3 | 7.0 | 6.7 | 6.7 | 6.7 | 6.8 | 6.9 |
| ហុងកុង | -3.2 | 6.9 | 4.9 | 2.9 | 3.0 | 2.3 | 2.3 | 0.8 | 1.7 | 1.3 | 3.1 | 4.3 |
| កូរ៉េខាងត្បូង | -1.0 | 6.1 | 3.6 | 2.1 | 2.8 | 3.4 | 2.6 | 2.7 | 3.2 | 2.3 | 2.3 | 2.8 |
| តៃវ៉ាន់ | -3.6 | 11.1 | 4.2 | 1.2 | 2.2 | 3.5 | 0.6 | -0.8 | 0.7 | 2.0 | 2.9 | 2.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | -3.8 | 1.6 | 1.6 | -0.5 | 0.1 | 0.7 | 1.3 | 1.5 | 1.6 | 1.7 | 1.7 | 1.7 |
| ជប៉ុន | -5.4 | 4.1 | -0.8 | 1.7 | 1.7 | 0.6 | 0.3 | 0.2 | 0.8 | 1.1 | 1.6 | 1.6 |
| សហរដ្ឋអាមេរិក | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 2.4 | 2.3 | 2.1 | 1.2 | 1.3 | 1.9 | 2.1 |

Sources: International Monetary Fund, Economist and countries' statistics offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៩-២០១៧ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | -0.5 | 4.1 | 5.5 | 3.0 | 3.0 | 3.9 | 1.2 | 2.4 | 3.1 | 3.0 | 3.6 | 4.2 |
| ឥណ្ឌូនេស៊ី | 4.7 | 5.1 | 5.4 | 4.3 | 7.0 | 6.4 | 6.4 | 4.3 | 3.5 | 3.0 | 3.3 | 3.6 |
| ម៉ាឡេស៊ី | 0.4 | 1.7 | 3.2 | 1.7 | 2.1 | 3.2 | 2.1 | 3.4 | 1.9 | 1.4 | 1.7 | 4.3 |
| សិង្ហបុរី | 0.5 | 2.9 | 5.2 | 4.6 | 2.3 | 1.0 | -0.5 | -0.8 | -0.9 | -1.5 | 0.0 | 0.7 |
| ថៃ | -0.9 | 3.1 | 3.8 | 3.0 | 2.2 | 1.9 | -0.9 | -0.5 | 0.3 | 0.3 | 0.7 | 1.1 |
| វៀតណាម | 7.3 | 9.0 | 18.6 | 9.3 | 6.6 | 4.8 | 0.6 | 1.3 | 2.2 | 2.8 | 4.4 | 5.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | -0.8 | 3.2 | 5.4 | 2.7 | 2.6 | 2.0 | 1.4 | 2.1 | 2.1 | 1.7 | 2.2 | 1.4 |
| ហុងកុង | -0.3 | 2.4 | 5.3 | 4.1 | 4.0 | 4.4 | 3.1 | 2.9 | 2.6 | 3.1 | 1.2 | 1.0 |
| កូរ៉េខាងត្បូង | 2.8 | 3.0 | 4.4 | 2.1 | 1.1 | 1.3 | 0.7 | 0.2 | 0.9 | 0.8 | 1.3 | 2.0 |
| តៃវ៉ាន់ | -1.1 | 1.0 | 1.4 | 1.9 | 0.8 | 1.5 | 0.6 | 1.7 | 1.3 | 0.7 | 1.8 | 0.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.4 | 1.6 | 2.7 | 2.5 | 1.4 | 0.4 | 0.0 | 0.1 | 0.2 | 0.3 | 0.7 | 1.8 |
| ជប៉ុន | -1.3 | -0.7 | 0.1 | -0.03 | 0.4 | 2.8 | 0.9 | 0.2 | -0.4 | -0.5 | 0.3 | 0.2 |
| សហរដ្ឋអាមេរិក | -0.4 | 1.7 | 3.2 | 2.1 | 1.5 | 1.6 | 0.0 | 1.1 | 0.7 | 1.1 | 1.9 | 2.5 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៩-២០១៧ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4140.48 | 4187.1 | 4063.6 | 4037.8 | 4027.2 | 4037.6 | 4060.4 | 4022.4 | 4056.3 | 4094.1 | 4041.9 | 4015.8 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10413.83 | 9089.9 | 8748.0 | 9363.0 | 10419.2 | 11,850.2 | 13394.8 | 13627.3 | 13324.1 | 13136.6 | 13265.3 | 13344.7 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.52 | 3.2 | 3.1 | 3.1 | 3.1 | 3.3 | 3.9 | 4.2 | 4.0 | 4.0 | 4.3 | 4.4 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.45 | 1.4 | 1.3 | 1.2 | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 34.34 | 31.7 | 30.5 | 31.1 | 30.7 | 32.5 | 34.2 | 35.6 | 35.3 | 34.8 | 35.4 | 35.1 |
| វៀតណាម (ដុង) | 17725.24 | 19200.8 | 20574.3 | 20856.9 | 20990.3 | 21138.2 | 21917.7 | 22929.4 | 22314.5 | 22292.2 | 22493.7 | 22429.1 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន់) | 6.83 | 6.8 | 6.5 | 6.3 | 6.1 | 6.2 | 6.3 | 6.5 | 6.5 | 6.7 | 6.8 | 6.9 |
| ហុងកុង (ដុល្លារហុងកុង) | 7.75 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1277.76 | 1156.3 | 1108.6 | 1126.6 | 1095.0 | 1053.6 | 1131.9 | 1200.8 | 1163.4 | 1120.9 | 1159.0 | 1152.4 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.04 | 31.5 | 29.4 | 29.6 | 29.7 | 30.3 | 31.8 | 33.1 | 32.4 | 31.7 | 31.8 | 31.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.72 | 0.8 | 0.7 | 0.8 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 93.6 | 87.8 | 79.9 | 79.8 | 97.6 | 105.9 | 121.0 | 115.3 | 107.9 | 102.4 | 109.5 | 113.7 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៩-២០១៧ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No.2) - (ដុល្លារ/តោន) | 165.5 | 185.9 | 291.7 | 298.4 | 259.4 | 192.9 | 169.8 | 160.0 | 171.1 | 153.5 | 152.2 | 160.6 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 682.8 | 900.8 | 1125.4 | 999.3 | 856.9 | 821.4 | 622.7 | 586.9 | 647.8 | 714.7 | 753.0 | 773.0 |
| កៅស៊ូ SMR 5 ដុល្លារ/តោន) | 1884.8 | 3405.7 | 4630.6 | 3200.7 | 2575.3 | 1755.6 | 1392.7 | 1190.0 | 1408.1 | 1349.4 | 1716.9 | 2147.7 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 524.5 | 506.6 | 558.5 | 594.8 | 533.8 | 434.9 | 395.5 | 385.3 | 465.0 | 430.3 | 376.0 | 537.0 |
| សណ្តែកសៀង (US No.1) - USA (ដុល្លារ/តោន) | 436.9 | 449.8 | 540.7 | 591.4 | 538.4 | 491.8 | 390.4 | 328.0 | 418.7 | 416.7 | 411.7 | 419.1 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 57.7 | 76.8 | 106.2 | 109.5 | 105.9 | 96.2 | 49.6 | 31.2 | 44.7 | 43.3 | 47.9 | 52.0 |
| សាំង - US Gulf Coast (សេន/លីត្រ) | 40.8 | 53.3 | 71.9 | 74.6 | 71.2 | 65.6 | 41.0 | 27.9 | 37.5 | 36.8 | 38.5 | 41.0 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 43.0 | 56.1 | 75.7 | 80.7 | 78.4 | 71.5 | 41.7 | 27.2 | 35.6 | 36.3 | 40.2 | 41.4 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ ឆ្នាំ២០១៧ អនុម័តវិនិយោគជាទ្រព្យសកម្មជាប់លាប់សរុប បានរួមចុះអស់ ៧៤,១% ដល់ ១៣១,៤ លានដុល្លារ ធៀបនឹង ៥០៧,៤ លានដុល្លារ កាលពីត្រីមាសមុន ហើយធៀបនឹងកាលពីមួយឆ្នាំមុន វាបានធ្លាក់ចុះ ៨៥,៨%។ អនុម័តវិនិយោគខាងកសិកម្ម ធ្លាក់ចុះ ៩០,៣% ធៀបនឹងត្រីមាសមុន ដល់ ៨,០ លានដុល្លារ ។ អនុម័តវិនិយោគខាងឧស្សាហកម្មសរុប មានត្រឹម ១១៥,៦ លានដុល្លារ ឬ ៦៤,០% ទាបជាងកាលពីត្រីមាសមុន។ វិនិយោគក្នុងផ្នែកកាត់ដេរ មានដល់ ៥៤,០ លានដុល្លារ ឬ កើន ១៨៤,២% ធៀបនឹងត្រីមាសមុន។ អនុម័តវិនិយោគក្នុងផ្នែកសេវាកម្ម មាន ៧,៨ លានដុល្លារ ឬ ៩២,៥% ទាបជាងកាលពីត្រីមាសមុន។ វិនិយោគខាងសណ្ឋាគារ និងទេសចរណ៍ មាន ៣,៦ លានដុល្លារ ឬធ្លាក់ចុះ ៩៣,៦% ធៀបនឹងត្រីមាសមុន។

នៅត្រីមាសទី១ នេះដែរ ចំនួនទេសចរអន្តរជាតិមកដល់សរុប មាន ១.៥០២.៨៩៦ នាក់ ឬថយចុះ ០,០៣% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើន ១១,៩% ធៀបមួយឆ្នាំមុន។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ១៧.៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ដល់ ៩២១.៤១០ នាក់ ហើយភ្ញៀវមកដល់តាមផ្លូវគោក និងផ្លូវទឹក កើន ៤,៣% ដល់ ៥៨១.៤៨៦ នាក់។

នៅត្រីមាសទី១នេះដែរ ការនាំចេញសរុបមានត្រឹម ២២៩០,៧ លានដុល្លារ ឬធ្លាក់ចុះ ៦,៧% ធៀបត្រីមាសមុន និងធ្លាក់ចុះ ៤,១% ធៀបមួយឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ កើនដល់ ១៨៥៦,៣ លានដុល្លារ ឬកើន ៥,៦% ធៀបនឹងត្រីមាសមុន និងកើន ៥,៥% ធៀបមួយឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក មាន ៤៥២,៣ លានដុល្លារ, ទៅសហភាពអឺរ៉ុប មាន ៥៨៣,០ លានដុល្លារ, ទៅបណ្តាប្រទេសអាស៊ាន ២៤,២ លានដុល្លារ, ទៅជប៉ុន ១៩៦,២ លានដុល្លារ, និងទៅប្រទេសផ្សេងទៀត ៦០០,៦ លានដុល្លារ។ ការនាំចេញផលិតផលកសិកម្ម កើន ១២,០% ដល់ ២០១,០ លានដុល្លារ ធៀបត្រីមាសមុន ឬកើន ៤៦,២% ធៀបមួយឆ្នាំមុន។ ក្នុងនោះការនាំចេញកៅស៊ូ មាន ៦៦,១ លានដុល្លារ, ការនាំចេញឈើ ១១,៧ លានដុល្លារ, ការនាំចេញត្រី ០,២ លានដុល្លារ, ការនាំចេញអង្ករ ៨៣,១ លានដុល្លារ, និងការនាំចេញផលិតផលកសិកម្មផ្សេងទៀត ៣៩,៩ លានដុល្លារ។

នៅត្រីមាសទី៤ ដដែលនេះ ការនាំចូលសរុប កើន ៣,០% ធៀបនឹងត្រីមាសមុន ឬកើន ១៤,២% ធៀបមួយឆ្នាំមុន ដល់ ៣.១៧៣,៥ លានដុល្លារ។ ការនាំចូលសាំង មានដល់ ៧៥,១ លានដុល្លារ, ម៉ាស៊ូត មាន ១៤៦,៤ លានដុល្លារ, សម្ភារសំណង់ ៥៥,៦ លានដុល្លារ, និង ការនាំចូលផ្សេងទៀត ២.៨៩៦,៤ លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ឆ្នាំ២០១៧ ចំណូលរដ្ឋាភិបាលសរុប មាន ៤.២៦១,៩ ប៊ីលានរៀល ឬ ២៥,២% ខ្ពស់ជាងត្រីមាសមុន និង ២០,៦% ខ្ពស់ជាងកាលពីមួយឆ្នាំមុន។ ចំណូលចរន្ត មាន ៣.២៦១,៩ ប៊ីលានរៀល ឬ ៣,០% ទាបជាងត្រីមាសមុន។ ចំណូលពន្ធ មាន ៣.៩០៥,៨ ប៊ីលានរៀល ឬ ៤៣,៥% ខ្ពស់ជាងត្រីមាសមុន រីឯចំណូលមិនមែនពន្ធ មាន ៣៥៦,២ ប៊ីលានរៀល ឬ ៤៤,៣% ទាបជាងត្រីមាសមុន។

ចំណាយសរុប មាន ៣.០៩០,៩ ប៊ីលានរៀល ឬ ៣១,៥% ទាបជាងត្រីមាសមុន ប៉ុន្តែ ៣០,៦% ខ្ពស់ជាងត្រីមាសដូចគ្នាឆ្នាំមុន។ ចំណាយមូលធន មាន ៨៥៩,០ ប៊ីលានរៀល ឬ ២៩,៩% ទាបជាងត្រីមាសមុន ហើយចំណាយចរន្ត មាន ២.២៣១,៩ ប៊ីលានរៀល ឬ ៣២,០% ទាបជាងត្រីមាសមុន។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០១៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុប មានដល់ ៤,២% ឬ ០,៣ ឯកតាភាគរយ ខ្ពស់ជាងត្រីមាសមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈមិនមែនស្រា កើន ៦% ប៉ុន្តែថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ៤,១% ធៀបនឹងមួយឆ្នាំមុន។

ធៀបនឹងត្រីមាសមុន ប្រាក់រៀល ឡើងថ្លៃ ០,៦% ទល់នឹងប្រាក់ដុល្លារ ដល់ ៤០១៥,៨ រៀល/ដុល្លារ, ឡើងថ្លៃ ១,៧% ទល់ នឹង

---

អត្ថបទនេះ រៀបរាងដោយ វ៉ែន សីហា ជាអ្នកស្រាវជ្រាវ និង ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

ប្រាក់ដុងវៀតណាម ដល់ ១៧,៨ រៀល/១០០ ដុង ហើយមានថ្លៃនឹងដដែលទល់នឹងប្រាក់បាតថៃ។

នៅត្រីមាសទី១ នេះដែរ មាសចុះថ្លៃ ១,៩% ដល់ ១៤៥,៥ ដុល្លារ/ជី។ ម៉ាស៊ូតឡើងថ្លៃ ៨,៤% ដល់ ៣.៣៩១,៦ រៀល/លីត្រ ហើយសាំងឡើងថ្លៃ ៧,៦% ដល់ ៣.៦៩៧,០ រៀល/លីត្រ។

## ស្ថានភាពក្រីក្រ

ផ្នែកនេះ ពិពណ៌នាពីស្ថានភាពក្រីក្រ ដោយផ្អែកតាមអង្កេតលើ កម្មកររោងចក្រកាត់ដេរ ១២០នាក់ និងពលករងាយរងគ្រោះផ្សេងទៀត ៣២០នាក់ នៅខែឧសភា ២០១៧។ ក្នុងនេះ ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់ អ្នករត់ស៊ីក្លូ កម្មកររោងចក្រកាត់ដេរ អ្នករត់ម៉ូតូឌុប អ្នកលីសែង អ្នកស៊ីឈ្នួលធ្វើស្រែ អ្នកលក់បន្លែតូចតាច អ្នករត់តុភោជនីយដ្ឋាន និង កម្មករសំណង់គ្មានជំនាញ បានថយចុះ ធៀបនឹងកាលពីមួយឆ្នាំមុន រីឯចំណូលរបស់ អ្នករើសអេតចាយ និង កម្មករសំណង់មានជំនាញ បានកើនឡើង។ បើគិតតាំងពីពេលចាប់ប្រកបរបរចិញ្ចឹមជីវិតរបស់គាត់នេះមក មានពលករងាយរងគ្រោះ ៦៤% ប្រាប់ថា ជីវភាពរបស់គាត់បានប្រសើរឡើង, ៣០,០% ប្រាប់ថា ជីវភាពរបស់គាត់នៅដដែល ហើយ ៦,០% ប្រាប់ថា ជីវភាពរបស់គាត់បានធ្លាក់ចុះ។

ចំណូលរបស់កម្មកររោងចក្រកាត់ដេរ ធ្លាក់ចុះ ៦,៦% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១២.៩១០ រៀល/ថ្ងៃ។ ពួកគាត់ ៦៩% បានរៀបការហើយ។ គិតជាមធ្យម ពួកគាត់មានកម្រិតអប់រំត្រឹមថ្នាក់ទី៦ និងបានធ្វើការនៅរោងចក្រ ចំនួន ៤ ឆ្នាំមកហើយ។ ពួកគាត់ធ្វើការ ៥៤,៤ ម៉ោងក្នុងមួយសប្តាហ៍ ហើយសន្សំទុកបាន ៥០,២%នៃប្រាក់ខែរបស់ខ្លួន។ កម្មករ ៩៣%ផ្ញើប្រាក់សន្សំទៅឲ្យក្រុមគ្រួសារ ហើយអាចជួយទ្រទ្រង់ជីវភាពគ្រួសារបានមួយភាគ។ កម្មករ ៥៤,២% មិនចង់ផ្លាស់ប្តូរការងារទេ, ២៤,១% ចង់ផ្លាស់ប្តូរការងារ ហើយ ២១,៧% មិនទាន់ច្បាស់ក្នុងចិត្តឡើយ។ កម្មករ ៤៦% មានសុទិដ្ឋិនិយមលើ អនាគតនៃរោងចក្ររបស់គាត់, ១៥,០% ប្រាប់ថា រោងចក្រមានអនាគតមិនសូវល្អ ៩,២% ប្រាប់ថា រោងចក្រនឹងនៅដដែលដូចធម្មតា រីឯកម្មករដទៃទៀតប្រាប់ថា គាត់មិនដឹងទេ។

ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើនដល់ ៧.០៤៩ រៀល/ថ្ងៃ ឬកើន ១១,០% ធៀបនឹងកាលពីមួយឆ្នាំមុន។ អ្នកឆ្លើយសម្ភាសន៍ ៧០% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ អ្នកស៊ីឈ្នួលធ្វើស្រែ ៥៥% ប្រាប់ថា ចំណូលរបស់គាត់ធ្លាក់ចុះធៀបនឹងត្រីមាសមុន។ អ្នកស៊ីឈ្នួលធ្វើស្រែ ៨២,៥% ប្រាប់ថាចំណូលរបស់គាត់ក្នុងខែឧសភា អាចទ្រទ្រង់គ្រួសារបានមួយភាគ រីឯ ១៧.៥% ទៀតប្រាប់ថា ចំណូលនោះមិនអាចជួយដល់គ្រួសារទេ។ អ្នកស៊ីឈ្នួលធ្វើស្រែ ៤៧,៥% មានជំពាក់បំណុល ហើយអត្រាការប្រាក់ជាមធ្យមគឺ ២,២% ក្នុងមួយខែ ។

អ្នកលក់បន្លែតូចតាចមានចំណូលចុះដល់ ១៣.៩៨០ រៀល/ថ្ងៃ ឬ ២៦,៣% ទាបជាងកាលពីមួយឆ្នាំមុន ។ អ្នកទាំងនេះមកពី ខេត្តស្វាយរៀង(២៥,០%) កណ្តាល(២០,០%) ព្រៃវែង(២០,០%) កំពង់ស្ពឺ(១២,០%) ក្រុងភ្នំពេញ(៧,៥%) តាកែវ(៧.៥%) កំពត(៥,០%) និង សៀមរាប(២,៥%)។ ពួកគាត់ ៣៥% មិនមានដីកសិកម្មទេ, ៥៥% មានដីកសិកម្មពី ០,៥ ទៅ ១,០ ហិកតា ហើយ ១០% មានដីកសិកម្មពី ១,២ ទៅ ២,០ ហិកតា។ អ្នកឆ្លើយសម្ភាសន៍ ៤០% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ហើយមាន ៧៧,៥% រាយការណ៍ថា មិនមានមូលធនគ្រប់គ្រាន់សម្រាប់បម្រើអាជីវកម្មរបស់ខ្លួនទេ។

ចំណូលរបស់អ្នករើសអេតចាយ កើន ៤២,៣% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១២.៤២៨ រៀល/ថ្ងៃ។ ពួកគាត់ភាគច្រើនប្រាប់ថា ចំនួនអ្នករើសអេតចាយកើនឡើង ប៉ុន្តែប្រភពសំរាម និងថ្លៃរបស់អេតចាយ បានធ្លាក់ចុះ ធៀបនឹងកាលពីបីខែមុន។ អ្នកឆ្លើយសម្ភាសន៍ប្រមាណ ៩២,៥% ជាអ្នករកចំណូលចិញ្ចឹមគ្រួសារ ហើយត្រូវធ្វើការជាមធ្យម ១០,៨ម៉ោង/ថ្ងៃ។ ពួកគាត់ចំណាយជាសំខាន់ទៅលើ ស្បៀងអាហារ(៦៩,៦% នៃចំណាយសរុប) ថ្លៃឈ្នួលកន្លែងស្នាក់នៅ(១៤,៩%) ការថែទាំសុខភាព(៤,១%) និង ចំណាយផ្សេងទៀត(១១,៤%)។

ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ ថយចុះ ២៦,៩% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១៤.៧៩៦ រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ ៦០,០% ប្រាប់ថា ចំនួនកម្មករសំណង់គ្មានជំនាញ បានកើនឡើង ធៀបនឹងកាលពីបីខែមុន។ កម្មករ ៩៧,៥% រាយការណ៍ថា សកម្មភាពសាងសង់ក៏កើនឡើងដែរ។ កម្មករ ៧០% បានធ្វើចំណាកស្រុកតែម្នាក់ឯងមកក្រុងភ្នំពេញ ឬសៀមរាប ដើម្បីរកការងារធ្វើ ហើយ ៣០% ទៀតធ្វើចំណាកស្រុកជាមួយគ្រួសារ។ ជាមធ្យម ពួកគាត់ធ្វើការ ៩,៤ ម៉ោង/ថ្ងៃ។ ចំណូលរបស់ពួកគាត់ ត្រូវចាយវាយទៅលើ ស្បៀងអាហារ(៧៧,៨% នៃចំណាយសរុប) ថ្លៃឈ្នួលកន្លែងស្នាក់នៅ(១៣,៥%) និង ចំណាយផ្សេងទៀត(៨,៧%)។ ចំណូលរបស់ពួកគាត់អាចទ្រទ្រង់ជីវភាពគ្រួសារបានតែមួយភាគប៉ុណ្ណោះ។

ចំណូលរបស់អ្នកលីសែង ថយចុះ ១,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ១៤.៦២៥ រៀល/ថ្ងៃ។ អ្នកលីសែង ៧៧,៥% បានធ្វើចំណាកស្រុកតែម្នាក់ឯងមកក្រុងភ្នំពេញ ឬសៀមរាប ដើម្បីរកការងារធ្វើ ហើយ ២២,៥% ធ្វើចំណាកស្រុកមកជាមួយគ្រួសារ។ ចំណូលរបស់ពួកគាត់ ត្រូវចាយវាយទៅលើ ស្បៀងអាហារ(៧៣,៣% នៃចំណាយសរុប) ថ្លៃឈ្នួលកន្លែងស្នាក់នៅ(១៦,០%) ការថែទាំសុខភាព(០,៨%) និងចំណាយផ្សេងទៀត(៩,៩%)។ អ្នកឆ្លើយសម្ភាសន៍ ៦៧,៥% ប្រាប់ថា តាំងពីចាប់របរធ្វើជាអ្នកលីសែងមក គ្រួសាររបស់គាត់មានជីវភាពប្រសើរជាងមុន, ៣០,០% ប្រាប់ថា គ្រួសារគាត់មានជីវភាពនៅដដែល ហើយ ២,៥% ទៀតប្រាប់ថា មានជីវភាពខ្វះខាតជាងមុន។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់តុភោជនីយដ្ឋាន ធ្លាក់ចុះ ០,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ៨.១៤១ រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នា ទទួលបានកន្លែងស្នាក់នៅពីម្ចាស់ហាង។ ពួកគាត់ធ្វើការនេះបានប្រហែល ៣,៨ ឆ្នាំមកហើយ និងត្រូវបម្រើការក្នុងហាងជាមធ្យម ១២ ម៉ោង/ថ្ងៃ។ ពួកគាត់ចំណាយប្រាក់ចំណូលរបស់ខ្លួនអស់ ៧២,៩%លើស្បៀងអាហារ ៨,០%លើការថែទាំសុខភាព និង ១៩,១%លើចំណាយផ្សេងៗទៀត។

# តាមដានសេដ្ឋកិច្ច - សូចនាករសេដ្ឋកិច្ច

## តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៩-១៧ *

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 615 | 530.7 | 725.0 | 531.6 | 930.5 | 56.5 | 3918.9 | 27.6 | 0.0 | 7.4 | 82.1 | 8.0 |
| ឧស្សាហកម្ម | 818.5 | 403.7 | 2860.1 | 829.3 | 3257.0 | 1002.5 | 3918.9 | 252.4 | 597.0 | 266.1 | 320.8 | 115.6 |
| *កាត់ដេរ* | 90.1 | 122.8 | 393.9 | 497.0 | 324.1 | 393.5 | 3918.9 | 70.8 | 239.9 | 51.1 | 19.0 | 54.0 |
| សេវាកម្ម | 4432 | 1337.3 | 3425.4 | 916.6 | 140.7 | 622.6 | 3918.9 | 643.6 | 234.1 | 681.9 | 104.6 | 7.8 |
| *សណ្ឋាគារ និងទេសចរណ៍* | 3980.1 | 1105.1 | 2850.9 | 691.5 | 106.0 | 446.9 | 3918.9 | 611.1 | 19.8 | 679.8 | 56.3 | 3.6 |
| សរុប | 5865.5 | 2271.7 | 7010.4 | 2278.0 | 4328.0 | 1583.9 | 3918.9 | 923.7 | 831.2 | 955.5 | 507.4 | 131.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | | | | 80.5 | -10.0 | 15.0 | -46.9 | -74.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -44.5 | -61.3 | 209.0 | -67.5 | 90.1 | 63.4 | 147.4 | -67.9 | 226.4 | 242.0 | -0.8 | -85.8 |

*Including expansion project approvals. Source: Cambodian Investment Board

## តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៩-១៧

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1111.7 | 1304.3 | 1480.4 | 1722.1 | 2017.7 | 2273.5 | 2476.0 | 785.0 | 593.5 | 602.2 | 797.4 | 921.4 |
| តាមផ្លូវគោក និងទឹក | 999.7 | 1094.6 | 1401.4 | 1862.2 | 2192.5 | 2229.3 | 2299.2 | 557.4 | 522,7 | 545,3 | 705.9 | 581.5 |
| សរុប | 2111.5 | 2398.9 | 2881.8 | 3584.3 | 4210.2 | 4502.8 | 4775.2 | 1342.5 | 1116.2 | 1147.5 | 1503.3 | 1502.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | | | - | - | - | - | - | -0.6 | -16.9 | 2.8 | 47.6 | -0.03 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | | | 20.1 | 24.4 | 17.5 | 7.0 | - | -2.4 | 12.3 | 9.8 | 5.2 | 11.9 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០០៩-១៧ *

| | 2011 | 2012 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3630.2 | 4929.5 | 4929.5 | 6106.4 | 6982.4 | 8106.0 | 9256.4 | 2388.3 | 2383.4 | 2817.7 | 2454.0 | 2290.7 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 3223.4 | 4259.6 | 4259.6 | 5015.4 | 5386.1 | 5960.5 | 6827.0 | 1759.4 | 1717.8 | 2072.5 | 1758.2 | 1856.3 |
| *- សហរដ្ឋអាមេរិក* | 1853.9 | 2055.3 | 2055.3 | 2143.3 | 2075.2 | 1963.6 | 2009.4 | 423.1 | 440.4 | 554.5 | 413.5 | 452.3 |
| *- សហភាពអឺរ៉ុប* | 809.5 | 1322.2 | 1322.2 | 1716.9 | 1969.6 | 2403.7 | 2903.9 | 789.6 | 776.6 | 733.4 | 629.2 | 583.0 |
| *- អាស៊ាន* | 9.9 | 17.6 | 17.6 | 39.4 | 60.2 | 83.3 | 103.4 | 25.6 | 25.7 | 21.4 | 25.7 | 24.2 |
| *- ជប៉ុន* | 86.5 | 147.0 | 147.0 | 188.6 | 278.7 | 383.1 | 524.2 | 176.0 | 122.5 | 216.0 | 140.9 | 196.2 |
| *- ប្រទេសផ្សេងៗ* | 463.6 | 717.5 | 717.5 | 927.2 | 1002.9 | 1126.8 | 1286.3 | 345.2 | 352.7 | 547.1 | 548.9 | 600.6 |
| កសិកម្ម | 164.9 | 362.1 | 362.1 | 376.7 | 554.5 | 624.4 | 548.8 | 137.5 | 98.9 | 118.1 | 179.5 | 201.0 |
| *- កៅស៊ូ* | 89.1 | 197.6 | 197.6 | 176.6 | 175.2 | 153.9 | 165.4 | 30.7 | 26.8 | 48.3 | 59.6 | 66.1 |
| *- ឈើ* | 34.1 | 48.8 | 48.8 | 36.8 | 73.6 | 132.0 | 46.3 | 4.9 | 12.4 | 11.6 | 18.3 | 11.7 |
| *- ត្រី* | 2.8 | 3.1 | 3.1 | 2.0 | 1.2 | 0.8 | 0.5 | 0.2 | 0.1 | 0.2 | 0.2 | 0.2 |
| *- អង្ករ* | 34.7 | 106.6 | 106.6 | 146.4 | 262.3 | 248.5 | 315.3 | 91.4 | 56.1 | 53.4 | 99.9 | 83.1 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 4.1 | 6.0 | 6.0 | 14.9 | 42.4 | 89.1 | 21.3 | 10.3 | 3.6 | 4.6 | 1.6 | 39.9 |
| ផ្សេងៗ | 242.0 | 307.9 | 307.9 | 714.4 | 1088.2 | 1520.1 | 1880.2 | 491.3 | 566.6 | 627.1 | 516.2 | 233.4 |
| ការនាំចូលសរុប ក្នុងនេះ៖ | 4332 | 5191 | 6375.9 | 8593.3 | 8639.4 | 10,295.4 | 11494.5 | 2784.7 | 6136.6 | 3017.0 | 3080.8 | 3173.5 |
| សាំង | 91.1 | 108.6 | 294.4 | 308.0 | 306.4 | 334.7 | 377.3 | 95.4 | 99.2 | 93.3 | 97.1 | 75.1 |
| ម៉ាស៊ូត | 180.7 | 203.8 | 447.0 | 559.5 | 569.1 | 602.3 | 607.8 | 163.1 | 194.6 | 173.7 | 178.0 | 146.4 |
| សម្ភារសំណង់ | 49.7 | 57.6 | 48.1 | 66.1 | 80.8 | 117.6 | 164.4 | 50.8 | 62.1 | 83.1 | 57.4 | 55.6 |
| ផ្សេងៗ | 4010.0 | 4820.6 | 5586.4 | 7659.1 | 7682.6 | 9240.7 | 10345.1 | 2475.0 | 5780.8 | 2667.0 | 2748.4 | 2896.4 |
| ជញ្ជីងពាណិជ្ជកម្ម | -1429.9 | -1560.5 | -1446.4 | -1341.6 | -1610.9 | -2184.3 | -2238.1 | -390.7 | -3753.3 | -199.4 | -626.8 | 882.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | - | 4.7 | -2.4 | 20.6 | -15.2 | 5.6 |
| ការនាំចេញសរុប | - | - | - | - | - | - | - | 3.4 | -0.2 | 18.2 | -12.9 | -6.7 |
| ការនាំចូលសរុប | - | - | - | - | - | - | - | -5.8 | 120.8 | -50.8 | 2.1 | 3.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | -14.1 | 25.7 | 32.1 | 17.7 | 7.4 | 10.7 | 14.5 | 13.6 | 7.2 | 3.9 | 4.6 | 5.5 |
| ការនាំចេញសរុប | 35.8 | 23.9 | 14.3 | 16.1 | | | 14.2 | 10.1 | 9.2 | 8.6 | 6.3 | -4.1 |
| ការនាំចូលសរុប | 22.8 | 16.8 | 15.4 | 19.7 | 21.4 | 19.2 | 11.7 | 5.0 | 2.5 | 110.1 | 3.8 | 14.2 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៩-១៧ (ប៊ីលានរៀល)

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ចំណូលសរុប | 4885.2 | 5989.0 | 6251.4 | 7691.9 | 8255.2 | 10,543.4 | 11,879.9 | 3533.1 | 3849.7 | 3413.7 | 3405.0 | 4261.9 |
| ចំណូលចរន្ត | 4855.9 | 5859.1 | 6179.3 | 7443.8 | 8233.2 | 10,359.4 | 11,759.0 | 3514.7 | 3836.3 | 3375.9 | 3361.7 | 3261.9 |
| ចំណូលពន្ធ | 4268.0 | 4693.0 | 5277.5 | 6334.8 | 7198.1 | 8995.2 | 10,502.4 | 3255.5 | 3368.1 | 2850.5 | 2722.4 | 3905.8 |
| ពន្ធក្នុងស្រុក | 3088.6 | 3533.6 | 4071.6 | 5002.8 | 5728.1 | 7226.5 | 8591.7 | 2715.3 | 2854.5 | 2378.5 | 2237.4 | 2450.0 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1064.7 | 1159.4 | 1205.9 | 1331.7 | 1470.0 | 1822.7 | 1910.7 | 540.1 | 513.6 | 472.0 | 485.0 | 455.8 |
| ចំណូលមិនមែនពន្ធ | 702.1 | 1166.1 | 901.8 | 1118.2 | 1035.2 | 1310.3 | 1256.6 | 259.3 | 468.2 | 525.4 | 639.4 | 356.2 |
| ចំណូលលើទ្រព្យសម្បត្តិ | 64.6 | 291.1 | 63.8 | 143.0 | 84.0 | 88.5 | 77.3 | 8.1 | 26.1 | 43.2 | 38.5 | 17.4 |
| លក់ទំនិញ និងសេវា | 408.0 | 460.1 | 588.7 | 667.4 | 750.3 | 871.2 | 1047.1 | 198.5 | 315.3 | 294.9 | 439.5 | 272.1 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 228.2 | 408.9 | 249.3 | 298.8 | 200.8 | 350.5 | 132.2 | 52.7 | 126.8 | 187.3 | 161.3 | 66.6 |
| ចំណូលជាមូលធន | 29.3 | 129.9 | 72.1 | 247.9 | 73.4 | 184.0 | 121.0 | 18.3 | 13.4 | 38.4 | 43.3 | 0.0 |
| ចំណាយសរុប | 7383.5 | 8784.6 | 9032.4 | 9660.9 | 12535.7 | 13306.5 | 13849.5 | 2364.3 | 3405.3 | 3460.8 | 4509.2 | 3090.9 |
| ចំណាយជាមូលធន | 2694.9 | 2853.2 | 3546.9 | 3628.3 | 5567.5 | 5590.7 | 5290.3 | 620.9 | 1091.1 | 811.3 | 1225.6 | 859.0 |
| ចំណាយចរន្ត | 4440.0 | 4773.1 | 5341.2 | 6188.4 | 6968.3 | 7715.8 | 8544.6 | 1743.4 | 2314.2 | 2649.1 | 3283.6 | 2231.9 |
| បៀវត្សរ៍ | 2012.0 | 2048.8 | 2170.6 | 2486.6 | 2997.3 | 3755.5 | 4271.9 | 1133.1 | 1418.3 | 1403.6 | 1426.7 | 1567.6 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 871.4 | 1099.4 | 1518.8 | 1586.8 | 1563.0 | 1627.0 | 1742.9 | 259.1 | 439.7 | 447.5 | 628.7 | 312.9 |
| ចំណាយចរន្តផ្សេងទៀត | 1556.6 | 1624.8 | 1651.8 | 2115.1 | 2408.0 | 2333.4 | 2529.8 | 351.2 | 456.2 | 798.1 | 1228.2 | 664.3 |
| សមតុល្យជាទូទៅ | -2498.3 | -2795.7 | -1271.4 | -1969.0 | -4280.6 | -2763.1 | -1969.6 | 1168.8 | 444.4 | -47.0 | -1104.2 | 1171.1 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1746.1 | 1845.2 | -2781.0 | 2457.8 | 4326.2 | 3972.1 | 3729.4 | 266.4 | 775.6 | 141.0 | 661.9 | 598.5 |
| ហិរញ្ញប្បទានក្នុងស្រុក | 474.9 | 938.6 | 2379.2 | -332.9 | 824.4 | -1428.7 | -2034.9 | -1631.4 | -488.5 | 37.5 | 342.7 | -352.8 |

Source: MEF website

## តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៩-១៧

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | -0.7 | 4.1 | 5.4 | 2.3 | 3.0 | 3.9 | 1.2 | 2.5 | 3.0 | 3.0 | 3.9 | 4.2 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | -0.3 | 4.4 | 6.5 | 2.5 | 3.9 | 4.9 | 4.0 | 4.7 | 6.2 | 5.5 | 6.0 | 6.0 |
| - ដឹកជញ្ជូន | -10.7 | 7.0 | 6.9 | 3.3 | -0.6 | -1.0 | -9.2 | -6.5 | -9.9 | -7.9 | -3.4 | 4.1 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4140.5 | 4187.1 | 4063.6 | 4039.2 | 4036.2 | 4060.4 | 4060.4 | 4022.4 | 4056.3 | 4094.1 | 4041.9 | 4015.8 |
| រៀលក្នុង ១ បាតថៃ | 121.1 | 133.1 | 133.2 | 130.0 | 124.9 | 119.4 | 119.4 | 113.4 | 115.7 | 118.1 | 114.9 | 114.9 |
| រៀលក្នុង ១០០ ដុងវៀតណាម | 23.4 | 21.7 | 19.7 | 19.4 | 19.1 | 18.7 | 18.7 | 18.1 | 18.3 | 18.5 | 18.1 | 17.8 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 113.1 | 147.6 | 184.5 | 200.9 | 175.9 | 152.3 | 140.6 | 151.2 | 151.2 | 157.1 | 148.3 | 145.5 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3170.9 | 3859.3 | 4761.2 | 4941.2 | 4852.1 | 4934.1 | 3771.3 | 2903.8 | 2932.8 | 3050.2 | 3129.3 | 3391.6 |
| ថ្លៃសាំង (រៀល/លីត្រ) | 3593.1 | 4368.1 | 5044.5 | 5312.7 | 5083.3 | 5155.7 | 3951.7 | 3310.6 | 3318.2 | 3281.4 | 3437.1 | 3697.0 |

Sources: NIS, NBC and CDRI

## តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៩-១៧ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | | | | 2017 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 14655.0 | 16697.9 | 17893.9 | 18154.5 | 21260.1 | 26699.7 | 26665.5 | 29247.8 | 30138.5 | 32188.4 | 32814.5 | 36490.5 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 1573.0 | 2778.9 | 5760.8 | 10437.4 | 11508.3 | 15859.8 | 22157.6 | 21643.0 | 24399.1 | 24939.2 | 25802.3 | 24057.0 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2252.0 | -2126.6 | -2123.1 | -2486.4 | -2794.9 | -4359.1 | -6428.8 | -7621.2 | -7977.4 | -7916.6 | -8148.5 | -9818.9 |
| ឥណទានដល់វិស័យឯកជន | 10532.0 | 13331.2 | 17552.8 | 23536.6 | 27608.8 | 36244.6 | 46071 | 47627.0 | 52528.6 | 54551.1 | 56458.8 | 57385.9 |
| រូបិយវត្ថុទូទៅ M2 | 16228.0 | 19476.8 | 23654.7 | 28591.9 | 32768.4 | 42559.5 | 48823.1 | 50890.9 | 54537.6 | 57127.5 | 57616.8 | 60547.4 |
| រូបិយវត្ថុ M1 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4878.2 | 6308.4 | 6741.4 | 6717.8 | 6872.0 | 7460.9 | 7273.0 | 7524.7 |
| រូបិយវត្ថុផ្សេងៗ | 13108.0 | 16255.9 | 17893.9 | 18154.5 | 21260.1 | 26699.7 | 42081.7 | 44173.1 | 47665.6 | 49666.6 | 50343.8 | 53022.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 36.9 | 20.0 | 17.8 | 20.9 | 14.6 | 29.9 | 14.7 | 16.5 | 18.2 | 21.7 | 18.0 | 19.0 |
| រូបិយវត្ថុ M1 | 30.1 | 3.2 | 16.9 | 2.3 | 20.6 | 29.3 | 6.9 | 1.4 | 9.2 | 18.7 | 7.9 | 12.0 |
| រូបិយវត្ថុផ្សេងៗ | 38.6 | 24.0 | 17.9 | 44.6 | 13.6 | 30.0 | 16.1 | 19.2 | 19.6 | 22.1 | 19.6 | 20.0 |

Source: National Bank of Cambodia

## តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2012 | 2013 | 2014 | 2015 | 2016 | | | 2017 | | 2016 | 2017 | |
| | | | | | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នករត់ស៊ីក្លូ | 10303 | 10438 | 10774 | 12405 | 11898 | 11302 | 10985 | 11092 | 10916 | -44 | -6.6 | -8.3 |
| អ្នកលីសែង | 12143 | 13247 | 13580 | 15631 | 11774 | 14094 | 13514 | 15171 | 14625 | -4.7 | 1.9 | -1.0 |
| អ្នកលក់បន្លែតូចតាច | 10771 | 11366 | 14751 | 15867 | 18979 | 11903 | 17488 | 18411 | 13980 | 6.1 | -9.5 | -26.3 |
| អ្នករើសអេតចាយ | 8680 | 9819 | 9173 | 12344 | 8737 | 9953 | 11347 | 11478 | 12428 | 0.1 | 2.9 | 42.3 |
| អ្នករត់តុភោជនីយដ្ឋាន* | 6111 | 6697 | 7789 | 8,436 | 8187 | 7895 | 8,015 | 7905 | 8141 | 3.6 | 0.6 | -0.6 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 6151 | 6599 | 7514 | 8,745 | 7916 | 7722 | 8,229 | 8332 | 7049 | -7.5 | -1.8 | -11.0 |
| កម្មកររោងចក្រកាត់ដេរ | 8932 | 10,161 | 11,178 | | 13,828 | 12,900 | 13136 | 14,889 | 12,910 | -10.9 | 0.01 | -6.6 |
| អ្នករត់ម៉ូតូឌុប | 12930 | 13450 | 13386 | 14455 | 15425 | 13653 | 13434 | 14770 | 13888 | -6.7 | -4.9 | -10.0 |
| កម្មករសំណង់គ្មានជំនាញ | 11078 | 13184 | 13336 | 15349 | 20227 | 13894 | 19174 | 16664 | 14796 | 31.1 | 3.1 | -26.9 |
| កម្មករសំណង់មានជំនាញ | 13743 | 15442 | 17420 | 18624 | 21150 | 19184 | 20287 | 21716 | 21924 | 13.8 | 15.2 | 3.7 |

* Waitresses/waiters' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waiters/waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000.

Source: CDRI

## ទើបចេញផ្សាយថ្មីៗ មាននៅក្នុង

https://cdri.org.kh/portfolio-item/synergies-and-trade-offs-with-intensification-of-rice-and-livestock-production-in-cambodia/

CDRI Cambodia Development Resource Institute    Australian National University    Luc Hoffmann Institute    OXFAM Australia

# Synergies and Trade-offs with Intensification of Rice and Livestock Production in Cambodia




Phon Dary, Sim Sokcheng and Khiev Pirom

Special Report 16
June 2017

A CDRI Publication

*តពីទំព័រ ២៨* **ព័ត៌មានថ្មីៗ**...

ដែល ការស្រាវជ្រាវផ្តែកលើភស្តុតាង និងគោលនយោបាយ អាចធ្វើការជាមួយគ្នា ដើម្បីដោះស្រាយបញ្ហារួម និងស្វែងរកដំណោះស្រាយសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ វេទិកានេះជាឱកាសល្អសម្រាប់ឲ្យ CDRI ចែករំលែកបទពិសោធន៍ក្នុងការស្រាវជ្រាវផ្នែកបរិស្ថាន ជាមួយនឹង ដៃគូនានាក្នុងតំបន់ និងក្នុងពិភពលោក។

១២ មិថុនា ២០១៧ ក្រុងភ្នំពេញ

**ការចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀងរវាង វិទ្យាស្ថាន CDRI នឹង សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS):** កិច្ចព្រមព្រៀងនេះបង្កើតទំនាក់ទំនងសហការស្រាវជ្រាវមួយ ដើម្បីធ្វើការស្រាវជ្រាវថ្មីៗអំពី ភាពជាអ្នកវិជ្ជាជីវៈពេទ្យ។

១៥-១៦ មិថុនា ២០១៧ ក្រុងភ្នំពេញ

**សន្និសីទថ្នាក់តំបន់ UNESCO-ICHEI ស្តីពី ការធានាគុណភាពឧត្តមសិក្សានៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក៖** នាយកប្រតិបត្តិនៃ CDRI បានទទួលការតែងតាំងជា ទីប្រឹក្សានៃមជ្ឈមណ្ឌលអន្តរជាតិសម្រាប់នវានុវត្តន៍ ក្នុងឧត្តមសិក្សា (ICHEI) ហើយបានចូលរួមក្នុងការប្រជុំលើកទី១ នៃ គណៈកម្មាធិការប្រឹក្សាអន្តរជាតិ និងសន្និសីទតំបន់អាស៊ី-ប៉ាស៊ីហ្វិកស្តីពី ការធានាគុណភាពឧត្តមសិក្សា។ សន្និសីទនេះបានដំណើរការនៅក្រុង Shenzhen ប្រទេសចិន ដោយមានការចូលរួមពីថ្នាក់ដឹកនាំកំពូលៗខាងអប់រំជាង ១០០ នាក់ មកពីជាង ៣០ ប្រទេស និងជាឱកាសដ៏សំខាន់សម្រាប់ឲ្យ CDRI កសាងបណ្តាញ។

២០ មិថុនា ២០១៧ ក្រុងភ្នំពេញ

**ការពង្រឹងសហប្រតិបត្តិការក្នុងការស្រាវជ្រាវពី បច្ចេកវិទ្យា និងនវានុវត្តន៍៖** CDRI បានចុះកិច្ចសន្យាជាមួយ Swisscontact Cambodia ដើម្បីរួមសហការគ្នាក្នុងការស្រាវជ្រាវពីបច្ចេកវិទ្យា និងនវានុវត្តន៍។ សកម្មភាពរួមគ្នាសំដៅដោះស្រាយបញ្ហាប្រឈមសំខាន់ៗក្នុង កសិកម្ម តម្រូវការទឹក និងវិស័យផ្សេងៗទៀត តាមការលើកកម្ពស់ការស្រាវជ្រាវ បច្ចេកវិទ្យា និងការអប់រំ ដោយប្រើវិធីសាស្ត្រតាមបែបប្រព័ន្ធទីផ្សារ។

## ការស្រាវជ្រាវ

### ផ្នែកកសិកម្ម

ផ្នែកនេះកំពុងអនុវត្ត ៦ គម្រោង។ ការសរសេររបាយការណ៍សម្រាប់គម្រោង *ផលប៉ះពាល់នៃ គោលនយោបាយជំរុញការនាំចេញអង្ករ និងសន្តិសុខស្បៀង* ដែលទទួលជំនួយគាំទ្រពីសាកលវិទ្យាល័យជាតិអូស្ត្រាលី (ANU) បានចប់សព្វគ្រប់ ដោយមានការបង្កើយរបាយការណ៍បច្ចេកទេសមួយ សម្រាប់ចុះផ្សាយជា របាយការណ៍ពិសេស នៅលើវេបសាយរបស់ CDRI។ លទ្ធផលមួយទៀតក្នុងគម្រោងនេះ គឺអត្ថបទស្តីពី ប្រពលវប្បកម្មនៃផលិតកម្មស្រូវ និងសត្វចិញ្ចឹមនៅកម្ពុជា ដែលចុះផ្សាយក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* លេខនេះ។ ក្រុមស្រាវជ្រាវបានបញ្ចប់ដោយជោគជ័យនូវ ការប្រមូលទិន្នន័យចុងក្រោក្នុង ៥ ខេត្ត (កណ្តាល តាកែវ កំពត ព្រៃវែង ស្វាយរៀង) សម្រាប់គម្រោង *ការសាកល្បងគំរូបែបថ្មីនៃ ការផ្សព្វផ្សាយកសិកម្ម នៅក្នុងកម្មវិធីអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច (PADEE)* ដែលទទួលមូលនិធិពី *វិទ្យាស្ថានស្រាវជ្រាវពីគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI)*។ គម្រោងនេះបានទទួលពេលបន្ថែម ដើម្បីធ្វើតេស្តគំរូផ្សព្វផ្សាយថ្មីមួយសម្រាប់ កម្មវិធីសេវាកសិកម្មសម្រាប់នវានុវត្តន៍ ភាពធន់ និងការផ្សព្វផ្សាយ (ASPIRE)។ លទ្ធផលស្រាវជ្រាវសម្រេចបាន រួមមាន ឯកសារផ្នែកគោលនយោបាយមួយ សង្ខេបសម្រាប់គោលនយោបាយមួយ និង ជំពូកមួយនៃឯកសារស្រាវជ្រាវ ដើម្បីផ្សព្វផ្សាយលទ្ធផលរកឃើញនៃការសិក្សាស្តីពី*ការវិភាគពីគោលនយោបាយស្រូវ* ដែលទទួលមូលនិធិពី កម្មវិធីផ្តួចផ្តើមគោលនយោបាយសាធារណៈមេគង្គក្រោម (LMPPI)។ ឯកសារទាំងអស់នេះ បានផ្ញើជូនទៅ LMPPI រួចហើយ។ នាបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងរៀបចំឯកសារគោលគំនិត សម្រាប់សិក្ខាសាលាពិគ្រោះយោបល់គ្រោងធ្វើឡើងនៅខែសីហា ស្តីពី *ការនាំចេញផលកសិកម្មទៅតំបន់មេគង្គមាន ថៃ វៀតណាម ចិន* ក្នុងក្របខ័ណ្ឌនៃគម្រោងភាពជាដៃគូផ្នែកធនធាន CDRI-Sida ឆ្នាំ២០១៦-២១។ កិច្ចការសម្រាប់ *ការសិក្សាវាយតម្លៃចុងក្រោយ* ដែលទទួលកិច្ចសន្យាពី សហព័ន្ធក្រុមប្រឹក្សាអាជ្ញាកណ្តាល (ACF) បានចាប់ផ្តើមនៅខែមេសា។ របាយការណ៍គោលគំនិតទទួលបានការពេញចិត្តពី ACF ហើយសព្វថ្ងៃក្រុមស្រាវជ្រាវកំពុងចុះសិក្សាដល់កន្លែងនៅក្រុងភ្នំពេញ។

### ផ្នែកសេដ្ឋកិច្ច

ការសិក្សាពី *ទំនាក់ទំនងរវាង គោលនយោបាយសាធារណៈនៃប្រទេសជាដៃគូ ចំណាកស្រុក និងអភិវឌ្ឍន៍: ករណីសិក្សា និងការផ្តល់មតិផ្នែកគោលនយោបាយ* បានចប់សព្វគ្រប់ប្រកបដោយជោគជ័យ។ ក្រុមស្រាវជ្រាវ ដោយរួមសហការជាមួយ ក្រសួងមហាផ្ទៃ និងអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ នៅថ្ងៃទី២៧ មេសា នៅក្រុងភ្នំពេញ ដោយមានការចូលរួមយ៉ាងច្រើនពី ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល (NGOs) និង ស្ថាប័នសិក្សាស្រាវជ្រាវនានា។ ជិតបានរួចរាល់ដែរ គឺគម្រោងស្តីពី ការស្រាវជ្រាវពីវិធានការមិនមែនពន្ធគយសម្រាប់អនុវត្តលើការនាំចេញផលផលរបស់កម្ពុជា។ ក្រុមស្រាវជ្រាវបានផ្ញើរបាយការណ៍ជូនម្ចាស់ជំនួយ និងគ្រោងលើកបង្ហាញពីលទ្ធផល

រកឃើញសំខាន់ៗនៅក្នុង កិច្ចសន្ទនានៃបណ្ដាញអាស៊ី-ប៉ាស៊ីហ្វិកនៃការស្រាវជ្រាវនិងបណ្ដុះបណ្ដាលពី ពាណិជ្ជកម្ម (ARTNeT) ស្ដីពី ការវិភាគលើវិធានការមិនមែនពន្ធគយ៖ ការប្រមូលភស្តុតាង និង កំណត់របៀបវារៈស្រាវជ្រាវ នៅថ្ងៃទី ២៦-២៧ មេសា នៅក្រុងបាងកក ប្រទេសថៃ។

បានជឿនលឿនទៅមុខច្រើនដែរ គឺ កម្មវិធីរយៈពេល ៣ឆ្នាំ ស្ដីពី *ការកែលំអលទ្ធភាពមានការងារធ្វើសម្រាប់ជនវ័យក្មេង៖ ទីផ្សារពលកម្ម ការអភិវឌ្ឍជំនាញ និងការអភិវឌ្ឍវិស័យឯកជន ក្នុងតំបន់មេគង្គធំទូលាយ* ក្នុងក្របខ័ណ្ឌនៃ បណ្ដាញស្រាវជ្រាវនៅមហាអនុតំបន់មេគង្គ(GMS-Net) ដែលជាសម្ព័ន្ធស្រាវជ្រាវថ្នាក់តំបន់មួយ សម្របសម្រួលដោយ CDRI និងទទួលបានជំនួយគាំទ្រពី មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានអន្តរជាតិនៃប្រទេសកាណាដា (IDRC)។ ក្រុមស្រាវជ្រាវនៃប្រទេសនីមួយៗ បានប្រគល់របាយការណ៍សម្រេចរបស់ខ្លួននៅខែឧសភា និងលើកបង្ហាញពីលទ្ធផលស្រាវជ្រាវ នៅក្នុងសិក្ខាសាលាបច្ចេកទេសថ្នាក់តំបន់ នៅខែកក្កដា។

គម្រោង ៣ ផ្សេងទៀតក៏បានជឿនលឿនទៅមុខល្អដែរ។ គម្រោងទី១ គឺ *វគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការវិវត្តនៃទីផ្សារពលកម្មៈ ការសិក្សាពិសោធន៍ដោយចៃដន្យក្នុងចំណោមយុវជនពេញវ័យកម្ពុជា* ដែលទទួលបានមូលនិធិពី GMS-Net។ នាបច្ចុប្បន្នក្រុមស្រាវជ្រាវកំពុងរៀបចំរបាយការណ៍សម្រេច ដើម្បីផ្ញើជូនទៅម្ចាស់ជំនួយនៅខែសីហា។ គម្រោងទី២ ស្ដីពី *ការបង្ហាញជាក់ស្ដែងពីការចូលរួមរបស់កម្ពុជានៅក្នុង ខ្សែសង្វាក់តម្លៃសកល (GVCs)*គឺជាការសិក្សាស្រាវជ្រាវក្នុងក្របខ័ណ្ឌនៃកម្មវិធីស្រាវជ្រាវរយៈពេល ៥ឆ្នាំ ផ្ដល់មូលនិធិដោយ Sida ស្ដីពី *ការអភិវឌ្ឍឧស្សាហកម្ម មូលធនមនុស្ស និង ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម(SME) នៅកម្ពុជា*។ ក្នុងនេះ ក្រុមស្រាវជ្រាវបានបង្កើយការសិក្សាឯកសារស្រាវជ្រាវមានស្រាប់ ហើយបច្ចុប្បន្នកំពុងពិនិត្យមូលដ្ឋានទិន្នន័យGVC មុនពេលចាប់ផ្ដើមចុះសិក្សាដល់កន្លែង។ គំរោងទី៣ គឺ *គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា និងគំនិតផ្ដួចផ្ដើមខ្សែក្រវាត់មួយ-ផ្លូវមួយ (OBOR)-ការអភិវឌ្ឍខេត្តព្រះសីហនុ ទៅជា តំបន់សេដ្ឋកិច្ចពិសេសមានទិសដៅច្រើន និងការប្រើប្រាស់គំនិតផ្ដួចផ្ដើម OBOR* ដែលផ្ដល់មូលនិធិដោយ មជ្ឈមណ្ឌលស្រាវជ្រាវផ្លូវសូត្រសមុទ្រសតវត្សរ៍ទី២១ របស់កម្ពុជា។ ក្នុងនេះ ក្រុមស្រាវជ្រាវបានបញ្ចប់ការសិក្សាលើឯកសារស្រាវជ្រាវមានស្រាប់ ហើយគ្រោងចុះសិក្សាដល់កន្លែងនៅខែសីហា។

## ផ្នែកអប់រំ

នៅខែមេសា ផ្នែកនេះបានជួបប្រជុំជាមួយក្រុមជំនាញនៅក្នុងក្រុមនៅ មជ្ឈមណ្ឌលសេអាមេត្រី នៅខេត្តតាកែវ ដើម្បីពិភាក្សាពី ការធ្វើផែនការយុទ្ធសាស្ត្រ ទំនួលខុសត្រូវរំពឹងទុក និងប្រធានបទស្រាវជ្រាវ ដោយមានការឧបត្ថម្ភពីម្ចាស់គម្រោងបីធំៗ សម្រាប់ការស្រាវជ្រាវផ្ដោតលើគោលនយោបាយ គឺ ដូចជា ក្រសួងការបរទេសនិងពាណិជ្ជកម្មប្រទេសអូស្ត្រាលី ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ(SDC) និង ទីភ្នាក់ងារស៊ុយអែតសម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ។

ក្រុមស្រាវជ្រាវ បានរៀបចំសិក្ខាសាលាចាប់ផ្ដើមគម្រោងនៅខែឧសភា ដើម្បីចាប់អនុវត្ត គម្រោងស្រាវជ្រាវរយៈពេលបីឆ្នាំ ដែលផ្ដល់មូលនិធិដោយ SDC ស្ដីពី ការស្រាវជ្រាវ កិច្ចសន្ទនាផ្នែកគោលនយោបាយ និង កម្មវិធីកសាងសមត្ថភាពលើការអប់រំនិងបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ។ សិក្ខាសាលានេះមានគោលដៅ ផ្ដល់ឲ្យអ្នកពាក់ព័ន្ធជាមួយ CDRI នានា នូវព័ត៌មានលើកម្មវិធីស្រាវជ្រាវដែលបានស្នើឡើង និងប្រមូលមតិយោបល់ និងកិច្ចសហការ ដើម្បីជំរុញកម្មវិធី TVET ទៅមុខ។ ក្នុងខែដដែល ផ្នែកនេះបានដកខ្លួនទៅសរសេររបាយការណ៍ចំនួនមួយសប្ដាហ៍ ដើម្បីឲ្យសមាជិកក្រុមមានឱកាសសរសេរឯកសារស្រាវជ្រាវ និងវិភាគទិន្នន័យ។ ឆ្លងតាមសិក្ខាសាលាបណ្ដុះបណ្ដាលមានការអនុវត្តផ្ទាល់ អ្នកស្រាវជ្រាវផ្នែកសេដ្ឋកិច្ច និងអ្នកស្រាវជ្រាវផ្នែកអប់រំបានបង្រៀនអ្នកស្រាវជ្រាវជំនាន់ក្រោយឲ្យចេះវិភាគទិន្នន័យតាមបែបបរិមាណដោយប្រើកម្មវិធី STATA ដើម្បីកសាងសមត្ថភាពបកស្រាយទិន្នន័យអង្កេតលើការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្មនិងគណិតវិទ្យា(STEM)ដែលប្រមូលបានពីស្ថាប័នសិក្សាអប់រំជាន់ខ្ពស់ក្នុង ៥តំបន់ ។

នៅក្នុងខែមិថុនា ផ្នែកនេះបានបំពេញទស្សនកិច្ចសិក្សានៅវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ ដើម្បីស្វែងយល់ពី បរិបទ និងបញ្ហាប្រឈមរបស់ TVET និងពិនិត្យពីវិស័យនានា ដែលអាចចូលរួមសហការជាមួយវិទ្យាស្ថាននេះ។ ក្រុមស្រាវជ្រាវបានបង្កើយការសិក្សាស្រាវជ្រាវ ក្រោមកិច្ចសន្យាជាមួយយូណេស្កូ លើប្រធានបទ "ការបញ្ជ្រាបផ្ទៃក្នុងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤:ការអប់រំឆ្នាំ២០៣០-ការវិភាគពីចំណងតភ្ជាប់ជាមួយ និងការចូលរួមចំណែកនៃវិស័យផ្សេងៗដើម្បីសម្រេចគោលដៅអប់រំឆ្នាំ២០៣០ នៅកម្ពុជា"។ ការងារនេះជាកិច្ចប្រឹងប្រែងដោយសហការគ្នានៃអ្នកស្រាវជ្រាវ ៦ នាក់ មកពីផ្នែកអប់រំ សុខភាព សេដ្ឋកិច្ច និង កសិកម្ម។

សរុបមក ផ្នែកអប់រំមានជោគជ័យក្នុងការ ប្រមូលដៃគូជាប់ពាក់ព័ន្ធនានា និងពិគ្រោះយោបល់គ្នាលើកម្មវិធីស្រាវជ្រាវដែលបានស្នើឡើង ស្វែងរកកិច្ចសហការបន្ថែម បង្កើយការងារក្រោមកិច្ចសន្យា លើកស្ទួយការងារជាក្រុមដែលមានច្រើនវិស័យ និងបង្កើនសមត្ថភាពលើការវិភាគទិន្នន័យ។

## ផ្នែកបរិស្ថាន

ផ្នែកនេះបានបង្កើយរបាយការណ៍មួយ និងអត្ថបទសង្ខេបគោលនយោបាយមួយសម្រាប់គម្រោងស្រាវជ្រាវពី *យេនឌ័រក្នុងការវាយតម្លៃពីផលប៉ះពាល់ផ្នែកបរិស្ថាននៅកម្ពុជា* ដែលផ្ដល់មូលនិធិដោយ ទីភ្នាក់ងារជំនួយអាមេរិក (USAID) ក្នុង

ក្របខ័ណ្ឌនៃ ភាពជាដៃគូនៅតំបន់មេគង្គសម្រាប់បរិស្ថាន។ បានផ្ញើចេញហើយដែរ គឺ ការសិក្សាសំយោគមួយស្ដីពី *ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងកំណើនសម្រាប់គ្រប់គ្នា*។ ផ្នែកនេះបានចូលរួមជាមួយអ្នកស្រាវជ្រាវនៅផ្នែកអភិបាលកិច្ច ដើម្បីអនុវត្តគម្រោងស្រាវជ្រាវពីរ ដែលពាក់ព័ន្ធនឹងជំនាញច្រើនផ្នែក។ គម្រោងទី១ គឺ *MK20: លំហសម្រាប់ការសន្ទនា* ដែលផ្ដោតលើ *យេនឌ័រ និងដំណើរការតាំងលំនៅឡើងវិញ និងវេទិកាមានអ្នកពាក់ព័ន្ធច្រើននាក់នៅតំបន់ទំនប់សេសានក្រោម២* ដែលនឹងគ្រោងចប់រួចរាល់នៅចុងឆ្នាំ២០១៧។ គម្រោងទី២ ស្ដីពី *សេដ្ឋកិច្ចនយោបាយនៃសង្គមស៊ីវិល* ដែលទទួលបានមូលនិធិពី USAID កំពុងស្ថិតក្នុងដំណាក់កាលចងក្រងគោលគំនិត និងធ្វើផែនការ ហើយត្រៀមចុះធ្វើការសិក្សាដល់កន្លែងនៅខែមិថុនា។ ផ្នែកនេះបានសហការជាមួយ វិទ្យាស្ថានបរិស្ថានក្រុងស្តុកខម (SEI) ដើម្បីរៀបចំ និងដំណើរការការប្រជុំថ្នាក់ជាតិមួយស្ដីពី "ការស្រូបចូលសារធាតុអាសេនិកក្នុងស្រូវអង្ករនៅកម្ពុជា" នៅក្រុងភ្នំពេញ នៅថ្ងៃទី២៣ កុម្ភៈ ២០១៧។

ក្រុមស្រាវជ្រាវបានធ្វើសំណើស្រាវជ្រាវជាច្រើន ដើម្បីដាក់ស្នើមូលនិធិទៅដៃគូនានា ក្នុងនោះមានសំណើពីរកំពុងរង់ចាំការពិនិត្យសម្រេចចុងក្រោយពី Forum Syd និង មូលនិធិប្រជាធិបតេយ្យសហប្រជាជាតិ (UNDEF)។ ក្រុមនេះក៏បានចងក្រង ឯកសារគោលគំនិត សម្រាប់សំណើអនុវត្តគម្រោងស្រាវជ្រាវស្ដីពី ការប្រើប្រព័ន្ធថាមពលព្រះអាទិត្យសម្រាប់កែលំអការគ្រប់គ្រងទឹកក្នុងកសិកម្មដំណាំស្រូវ ហើយនាបច្ចុប្បន្ន ខាងមូលនិធិពិសេសនៃសហប្រតិបត្តិការឡានចាង-មេគង្គ (LMC Special Fund) កំពុងពិនិត្យសម្រេចលើរឿងសំណើនោះ។ គម្រោងនេះសំដៅដល់ការបង្កើតសាកល្បងនូវ ប្រព័ន្ធបូមទឹកកសិកម្មប្រើថាមពលព្រះអាទិត្យ រួមទាំងប្រឡាយ និងអាងស្តុកទឹកសម្រាប់ស្រោចស្រពស្រែឲ្យបានយ៉ាងហោចណាស់៣០០ហិកតា ដើម្បីព្យាយាមបំបាត់បញ្ហាកង្វះថាមពលនិងទឹក ដែលរារាំងទៅដល់ផលិតភាពស្រូវ។

## ផ្នែកអភិបាលកិច្ច

ក្រុមស្រាវជ្រាវក្នុងគម្រោងអភិបាលកិច្ចទឹកទន្លេមេគង្គ ជិតបង្ហើយការសិក្សាពីរ តាមការបោះពុម្ពផ្សាយនូវ ឯកសារពិភាក្សា ២ ដែលពិនិត្យពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការសាងសង់ទំនប់សេសានក្រោម២។ ជាក់ស្ដែង ឯកសារមួយពិនិត្យពីបទពិសោធន៍ និងចំណាប់អារម្មណ៍របស់ប្រជាជនមូលដ្ឋានលើ ការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធច្រើនបែបយ៉ាង ហើយឯកសារមួយទៀតពិនិត្យពីផលប៉ះពាល់ផ្នែកសង្គម និងយេនឌ័រនៃផែនការត្រូវតាំងលំនៅជាថ្មី ទៅលើសហគមន៍រងផលប៉ះពាល់។ គម្រោងនេះមានការចុះសិក្សាដល់កន្លែងនៅខេត្តស្ទឹងត្រែង និងការធ្វើសម្ភាសន៍អ្នកតំណាងស្ថាប័នសំខាន់ៗ មានជាអាទិ រដ្ឋអំណាចខេត្ត មន្ទីរជំនាញផ្សេងៗក្នុងខេត្ត ដូចជាខាង កិច្ចការនារី បរិស្ថាន រ៉ែនិងថាមពល ធនធានទឹកនិងឧតុនិយម ជាដើម។ ការវិភាគ និងលទ្ធផលរកឃើញជាដំបូងៗ បានយកទៅលើកបង្ហាញក្នុងសន្និសីទអន្តរជាតិស្ដីពីគោលនយោបាយសាធារណៈ នៅ សាលាគោលនយោបាយសាធារណៈ លី ក្វាន់យូ ប្រទេសសិង្ហបុរី កាលពីថ្ងៃទី២៧-៣០ មិថុនា។

ផ្នែកនេះក៏បានរៀបចំសិក្ខាសាលាបណ្ដុះបណ្ដាលពីរ គឺមួយស្ដីពី វិធីសាស្ត្រនិងរបៀបរបបផ្នែកជាតិពន្ធុសាស្ត្រក្នុងការសិក្សាពីអាស៊ីអាគ្នេយ៍ និងមួយទៀតស្ដីពី របៀបសរសេរ និងបកស្រាយបង្ហាញឯកសារសម្រាប់សន្និសីទអន្តរជាតិ។ សិក្ខាសាលាទាំងពីរនេះ សម្របសម្រួលដោយ បណ្ឌិត Duncan McCargo ជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយនៅ University of Leeds ប្រទេសអង់គ្លេស។ នៅចុងខែមិថុនា ផ្នែកនេះបានដំណើរការសិក្ខាសាលាស្រាវជ្រាវមួយ ជាមួយអ្នកសិក្សាស្រាវជ្រាវមកពី University of Bradford ប្រទេសអង់គ្លេស លើប្រធានបទកិច្ចសហការ ស្រាវជ្រាវជើង-ត្បូង ដោយមានការចូលរួមពីមន្ត្រីរាជការ អ្នកសិក្សាស្រាវជ្រាវ និងតំណាងម្ចាស់ជំនួយ។

## ផ្នែកសុខាភិបាល

ពិធីចុះហត្ថលេខាលើអនុស្សរណៈព្រមព្រៀង (MOU) រវាងវិទ្យាស្ថាន CDRI នឹង សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS) បានធ្វើឡើងនៅខែមិថុនា ក្នុងគោលដៅកសាង និងអនុវត្តកម្មវិធីរួមសហប្រតិបត្តិការធ្វើការស្រាវជ្រាវ សម្រាប់សកម្មភាពដែលត្រូវដោះស្រាយសំណួរ ស្រាវជ្រាវ ២ គឺ តើគ្រូពេទ្យល្អត្រូវមានគុណសម្បត្តិអ្វីខ្លះ? និង តើត្រូវជួយយ៉ាងណាឲ្យនិស្សិតពេទ្យក្លាយជាគ្រូពេទ្យល្អ? ឯកសារគោលគំនិតទី១ បានដាក់ជូនភ្លាមទៅឲ្យ ការិយាល័យស្រាវជ្រាវ នៃមហាវិទ្យាល័យវេជ្ជសាស្ត្រជួយពិនិត្យបន្ថែម ហើយក្រុមស្រាវជ្រាវផ្នែកសុខាភិបាល និងសមភាគីនៅ UHS ក៏បានជួបពិភាក្សាគ្នាជាច្រើនលើកអំពីសារៈតារ កម្មវត្ថុ គោលដៅចំណុច ការរចនារៀបចំ និងវិធីសាស្ត្រស្រាវជ្រាវ។ សេចក្ដីព្រាងសំណើស្រាវជ្រាវមួយស្ដីពី ក្រមវិជ្ជាជីវៈគ្រូពេទ្យនៅកម្ពុជា បានធ្វើបច្ចុប្បន្នភាពឡើងវិញ ហើយរហូតមកដល់ចុងខែមិថុនា ២០១៧ CDRI កំពុងរង់ចាំព័ត៌មានត្រឡប់ពីការិយាល័យស្រាវជ្រាវនៃ UHS។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

១៩-២១ មេសា ២០១៧ ក្រុង Tianjin ប្រទេសចិន

**ជំរុញ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ទៅមុខ៖** នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI និង ឯកឧត្តម បណ្ឌិត សុក ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI បានទៅបំពេញទស្សនកិច្ចនៅ សាកលវិទ្យាល័យវិទ្យាសាស្ត្រអនុវត្តចិន-អាឡឺម៉ង់នៃក្រុងតាន់យិន ( Tianjin Sino-German University of Applied Sciences ) ដែលនៅទីនោះ បណ្ឌិត សុក ស៊ីផាន់ណា បានទទួលការតែងតាំងជាសាស្ត្រាចារ្យគោចរ។ សាកលវិទ្យាល័យនេះកំពុងកសាងនៅក្នុង វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា នូវមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡាងសាង-មេគង្គ ដែលគ្រោងចាប់បើកដំណើរការនៅដើមឆ្នាំ២០១៨។ សាកលវិទ្យាល័យនេះក៏បានបញ្ជាក់ពីការយកចិត្តទុកដាក់ដើម្បី បន្តជំនួយគាំទ្រដល់ការបណ្តុះបណ្តាល TVET នៅកម្ពុជា និងរួមសហការជាមួយ CDRI ធ្វើការស្រាវជ្រាវលើការអភិវឌ្ឍគោលនយោបាយ TVET។

២៧ មេសា ២០១៧ ក្រុងភ្នំពេញ

**ទាញយកអត្ថប្រយោជន៍ឲ្យបានច្រើនបំផុត ពីចំណាកស្រុក៖** ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងអ្នកស្រាវជ្រាវនៃ CDRI បានចូលរួមក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ស្តីពី ទំនាក់ទំនងទៅវិញទៅមករវាងគោលនយោបាយសាធារណៈ ចំណាកស្រុក នឹងការអភិវឌ្ឍនៅកម្ពុជា។ របាយការណ៍នេះជាលទ្ធផលនៃគម្រោងរួមគ្នារវាងផ្នែកសេដ្ឋកិច្ចនៃ វិទ្យាស្ថាន CDRI នឹង មជ្ឈមណ្ឌលអភិវឌ្ឍន៍នៃអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ដោយមានការចូលរួមសហការពីក្រសួងមហាផ្ទៃ និងជំនួយគាំទ្រពីសហភាពអឺរ៉ុប។ របាយការណ៍នេះបង្ហាញពី កត្តាបីនៃចំណាកស្រុកដែលប៉ះពាល់ដល់ប្រព័ន្ធសេដ្ឋកិច្ចសង្គមកិច្ចនៃសង្គមកម្ពុជា ពោលគឺ ចំណាកស្រុកចេញ បញ្ញើមកផ្ទះ និង ការវិលត្រឡប់វិញ។ គម្រោងនេះមានគោលដៅផ្តល់ឲ្យអ្នកកសាងគោលនយោបាយនូវភស្តុតាងពីបែបបទដែលចំណាកស្រុកជះឥទ្ធិពលទៅលើ ទីផ្សារពលកម្ម កសិកម្ម ការអប់រំ វិនិយោគ និង សេវាហិរញ្ញវត្ថុ និងពីបែបបទដែលគោលនយោបាយតាមវិស័យ អាចជះឥទ្ធិពលទៅលើលំនាំនៃចំណាកស្រុក។

២ ឧសភា ២០១៧ ក្រុងភ្នំពេញ

**ការស្រាវជ្រាវកិច្ចសន្ទនាផ្នែកគោលនយោបាយនិងការកសាងសមត្ថភាពលើ TVET:** ផ្នែកអប់រំនៃ CDRI បានរៀបចំសិក្ខាសាលាចាប់ផ្តើមគម្រោងមួយនៅក្រុងភ្នំពេញ ដើម្បីចាប់អនុវត្ត គម្រោងស្រាវជ្រាវពី TVET មានរយៈពេលបីឆ្នាំដែលផ្តល់មូលនិធិដោយទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC)។ សិក្ខាសាលានេះ មានការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើនមកពីខាងរដ្ឋាភិបាល ស្ថាប័នសិក្សាអប់រំ និង វិស័យឯកជន ហើយមានគោលដៅស្វែងរកមតិយោបល់ និងកិច្ចសហការ ដើម្បីជំរុញកម្មវិធី TVET ទៅមុខ។

៣០ ឧសភា ២០១៧ ក្រុងបាងកក ប្រទេសថៃ

**វេទិកាវិទ្យាសាស្ត្រឆ្នាំ២០១៧ នៃវិទ្យាស្ថានបរិស្ថានក្រុងស្តុកខម (SEI) - វិទ្យាសាស្ត្រ និងគោលនយោបាយ ត្រូវប្រឈមមុខដោះស្រាយបញ្ហាចីរភាព៖** លោកនាយកប្រតិបត្តិបានតំណាង CDRI នៅក្នុង វេទិកាវិទ្យាសាស្ត្រ SEI ប្រចាំឆ្នាំដែល សាកលវិទ្យាល័យ Chulalongkorn បានចូលរួមរៀបចំឡើងនៅក្រុងបាងកក ប្រទេសថៃ។ វេទិកានេះពិនិត្យពីបែបបទ

*តទៅទំព័រ ២៥*

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី២១ លេខ២ ខែមិថុនា ឆ្នាំ២០១៧

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវការវាយតម្លៃឯករាជ្យពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ +៨៥៥២៣៨៨១៧០១/៨៨១៩១៦/៨៨៣៦០៣ 🖷 +៨៥៥២៣៨៨០៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសម្រួល: យូ សិទ្ធិរិទ្ធ
កែសម្រួលផលិតកម្ម: អ៊ុំ ចាន់ថា

សហគ្រាសបោះពុម្ព Invent Cambodia, រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៦ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh